ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ហ្គុនណា បឺយស្រ្តម : អ្វីៗគ្រាន់តែជាការរៀបចំរបស់ខ្មែរក្រហម
- ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មអំពីការបាត់សមាជិកគ្រួសារ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២០១ ខែកញ្ញា ឆ្នាំ២០១៦

# ស្វែងរកការពិត

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២០១ ខែកញ្ញា ឆ្នាំ២០១៦

## មាតិកា

◆ ហ៊ុនណា បឺយស្រ្តម ៖ អ្វីៗគ្រាន់តែជាការរៀបចំ ........................................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ ឈាង ភឿង ប្រធានរោងចក្រ ........................................២

◆ កម្មាត់សតិអារម្មណ៍កម្មសិទ្ធិបុគ្គលសួនតួ ........................................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ សង្រ្គាមធ្វើឲ្យខ្ញុំបែកពីគ្រួសារ ........................................១៦

◆ ការយល់ដឹងពីរបបខ្មែរក្រហមតាមរយៈអតីតយោធា ........................................១៧

◆ ជីវិតនៅអន្លង់វែងក្រោមការគ្រប់គ្រងរបស់ តាម៉ុក ........................................១៨

◆ ខ្ទាក់ភ្នែកទាំងគូប្រសើរជាងឃើញការសម្លាប់មនុស្ស ........................................២០

◆ ធ្លាក់ខ្លួនពិការដោយសារមីន ........................................២១

◆ សន្តិភាព ក្រោយបញ្ចប់សង្រ្គាម ........................................២២

◆ លើកដំបូងរបស់ខ្ញុំមកដល់អន្លង់វែង ........................................២៤

◆ ប្រវត្តិសាស្ត្ររបស់សហគមន៍អន្លង់វែង ........................................២៦

◆ ដំណើរជីវិតរបស់ ដុង លាង ក្នុងរបបខ្មែរក្រហម ........................................៣៣

◆ អៀច រឿន ៖ ការផ្សះផ្សានៅក្នុងសហគមន៍ គឺ ........................................៣៦

◆ អតីតយុទ្ធជនខ្មែរក្រហម ........................................៣៨

◆ ដៃ នន និងការបង្ខំឲ្យធ្វើជាយោធា ........................................៤០

**ផ្នែកច្បាប់**

◆ ដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់សក្ខីកម្មអំពីការបាត់បង់ ........................................៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ ប្រវត្តិសាស្ត្រអន្លង់វែង ៖ តម្លៃនៃសន្តិភាព ........................................៥៤

◆ រថភ្លើងរំឭកពីអតីតកាល ........................................៥៦

◆ អន្លង់វែង និងការផ្លាស់ប្តូរទស្សនៈអវិជ្ជមាន ........................................៥៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ នៅតែចងចាំ ........................................៦១



ហ៊ុនណា ធ្វើទស្សនកិច្ចនៅខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៧៧

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្រ្តីនិងរដ្ឋមន្រ្តីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ ៖*** *កែវ សុភី, នេត ផាត, ពេជ្រ សំណាង, អ៊ឹ សុីណាន, ពេញ សុចណ្ណារី, រដ្ឋ សុផល, លី រ៉ូចណៃ, ស្រេម ស្រីនិច, គ្រីស្តូហ្វ័រ ឌៀរីង, ឌី ខាំបូលី, ដួប ដានិត, ឌឿន ស្រីភ័ស្ត, សែម ដារ៉ែន, មាឃ គន្ធា, អាលីស មើហ្គើរ, អ៊ុន សុដារី, ប្រាក់ ជ័យវិបុល* ***អ្នកនិពន្ធនិងស្រាវជ្រាវ ៖*** *ទាវ សារៈមុនិន្ទ* ***អ្នកបកប្រែ ៖*** *សុភ័ក្ត្រ ភាណា* ***និពន្ធនាយកទូទៅ ៖*** *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក ៖*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ ៖*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ ៖*** *ឆេង វេង និង សន ល័ក្ខ* Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ហ្គុនណា បឺយស្រ្តម : អ្វីៗគ្រាន់តែជាការរៀបចំរបស់ខ្មែរក្រហម

ហ្គុនណា បឺយស្រ្តម បានវិលត្រឡប់មកប្រទេសកម្ពុជាជាលើកទីបី នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ ចាប់តាំងពីដំណើរទស្សនកិច្ចរបស់គាត់កាលពីសាមសិបប្រាំបីឆ្នាំមុន ។ នៅក្នុងឆ្នាំ ១៩៧៨ ហ្គុនណា បានស្នាក់នៅប្រទេសកម្ពុជាក្នុងរយៈពេល១៤ ថ្ងៃជាមួយនឹងតំណាងផ្សេងទៀតរបស់សមាគម មិត្តភាពស៊ុយអែត-កម្ពុជា នៅក្នុងដំណើរទស្សនកិច្ចការទូតមួយដែលខ្មែរក្រហមមានបំណងប្រើប្រាស់ ដើម្បីទាក់ទាញការគាំទ្រពីបណ្តាប្រទេសកុម្មុយនីស្តដទៃទៀត ។ នៅក្នុងអំឡុងការវិលត្រឡប់លើកទីបីនេះ ហ្គុនណា បានធ្វើបទបង្ហាញដល់ភ្ញៀវដែលចូលរួមនៅវិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកបានលើកឡើងថា នៅអំឡុងទស្សនកិច្ចនេះ គណៈប្រតិភូរបស់លោកត្រូវបានកម្មាភិបាលខ្មែរក្រហមនាំទស្សនាទីកន្លែង ជាច្រើននៅទីក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ចាម កំពង់ធំ សៀមរាប កំពត និងក្រុងកំពង់សោម ។


ហ្គុនណា ធ្វើបាឋកថាអំពីដំណើរទស្សនកិច្ចរបស់លោកមកប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៧ និងសម្តែងការសោកស្តាយ និងសុំទោសដល់ប្រជាជនកម្ពុជាចំពោះការគាំទ្ររបបខ្មែរក្រហមរបស់លោក

ហ្គុនណា បានទៅមើលមន្ទីរពេទ្យ រោងចក្រ សាលារៀន និងប្រជាជនកំពុងធ្វើការងារនៅតាមវាលស្រែ ការដ្ឋានជីកប្រឡាយ និងនៅកន្លែងផ្សេងៗទៀត ។ គាត់ថែមទាំងបានទទួលទានអាហារពេលល្ងាចជាមួយ ប៉ុល ពត និង អៀង សារី ដែលជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទៀតផង ។ ក្រោយពេលវិលត្រឡប់ទៅប្រទេសស៊ុយអែតវិញ គណៈប្រតិភូបានលើកសរសើរអំពីកម្ពុជាថាជាបដិវត្តន៍គំរូមួយ បើទោះបីជាទើបនឹងចាប់ផ្តើម និងមិនទាន់ល្អឥតខ្ចោះក៏ដោយ ។ ជាងនេះទៅទៀត គណៈប្រតិភូថែមទាំងបង្ហាញឲ្យឃើញជំនឿដ៏មុតមាំថារបបកុម្មុយនីស្តអាចជាជម្រើសដ៏ល្អបំផុតសម្រាប់ប្រជាជនកម្ពុជា ។

រហូតដល់ពេលដែលបានឃើញជនភៀសខ្លួនកម្ពុជារាប់ម៉ឺននាក់ភៀសខ្លួនចូលទៅក្នុងទឹកដីថៃ ទើបគណៈប្រតិភូដឹងថាខ្លួនបានយល់ខុសទាំងស្រុងចំពោះបដិវត្តន៍កម្ពុជា ។ លោកក៏បានលើកឡើងពីទំនាក់ទំនងយ៉ាងស៊ីជម្រៅរវាងកម្ពុជាប្រជាធិបតេយ្យជាមួយនឹងប្រទេសចិនទៀតផង ។

ហ្គុនណា បានសម្តែងការសោកស្តាយ និងសុំទោសដល់ប្រជាជនកម្ពុជាចំពោះការគាំទ្ររបស់គាត់ទៅលើការដឹកនាំរបស់ខ្មែរក្រហមនូវអ្វីដែលគាត់បានឃើញក្នុងអំឡុងពេលទស្សកិច្ចរបស់គាត់គឺគ្រាន់ជាការរៀបចំទុកជាស្រេចរបស់ខ្មែរក្រហម ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ចម្លើយសារភាពរបស់ ឈាង ភឿង ប្រធានរោងចក្រតម្បាញ

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D៥៩០២១*

ឈ្មោះ ឈាង ភឿង ហៅ រឿង មានអាយុ២១ ឆ្នាំ ភេទស្រី ជនជាតិខ្មែរ មានគ្រួសារហើយ ។ ភឿង មានស្រុកកំណើតនៅភូមិតាំង ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្ដាល (បច្ចុប្បន្ននេះនៅក្នុងភូមិភាគបស្ចិម) ។ មុនអង្គការចាប់ ភឿង មានតួនាទីជាប្រធានរោងចក្រត្បាញ ត-២ ក្រសួងឧស្សាហកម្ម ។

តាំងពីដឹងក្ដីមក ភឿង រស់នៅជាមួយឪពុកម្ដាយ រកស៊ីធ្វើស្រែ និងឡើងត្នោត ។ ខែឧសភា ឆ្នាំ១៩៧២ ភិន បាននាំ ភឿង ចូលបដិវត្តន៍ ។ មុនដំបូង ភឿង ធ្វើជានារីឃុំសំរោងលើ ដល់ខែមិថុនា ឆ្នាំ១៩៧២ ភិន បានផ្លាស់ ភឿង ទៅនៅមន្ទីរឃុំដំណាក់អំពិល ស្រុកអង្គស្នួល ។ ខែឧសភា ឆ្នាំ១៩៧៣ ចង យាន នាទីជាប្រធាននារីឃុំ ថាំង ប្រធាននារីឃុំដំណាក់អំពិល និង សាវ ជាប្រធានឃុំដំណាក់អំពិល បានអប់រំឈ្មោះ ណាត់ (នារី), អុល (នារី) និង ភឿង ។ មុនដំបូង យាន បានលើកឡើងថា យើងធ្វើបដិវត្តន៍មានការលំបាកណាស់ មិត្តឃើញហើយសូម្បីតែលុយក៏គ្មានចាយផង ហើយបាយក៏គ្មានហូបគ្រប់គ្រាន់ ធ្វើមួយថ្ងៃៗមិនដែលបានសម្រាកទេ នៅតែខ្វះបាយហូបទៀត ។ ដូចជារឿងដើរ គ្រាន់តែដើរបន្តិចបន្តួចក៏ស្ដីឲ្យថា សេរីភាពយ៉ាងនេះ សេរីភាពនោះ បើរឿងសិទ្ធិសេរីភាពអង្គការលើកឡើងថាស្មើគ្នាៗ តែបើពិនិត្យទៅដូចជារឿងរៀបគ្រួសារបិទសិទ្ធិសេរីភាពណាស់អត់ឲ្យរៀបទេ បើអ្នកណាហ៊ានរៀបចាប់បាញ់ចោល ឬដាក់នៅមន្ទីរអប់រំ ។ បើយើងមើលពីសង្គមចាស់ និងឥឡូវនេះខុសឆ្ងាយណាស់ លំបាកសព្វគ្រប់តាំងពីចូលបដិវត្តន៍ ធ្វើការរចង់ងាប់ចង់រស់ នៅតែគេស្ដីឲ្យទៀត ។ គាត់និយាយទៀតថា មិត្តឯងទាំងអស់ធ្វើតាម ភឿង ទៅបានផុតពីការគាបសង្កត់ កុំឲ្យលំបាកដូចសព្វថ្ងៃនេះ បើឈានទៅហូបបាយឯកជនវិញបានស្រួល ។ គាត់ថាឥឡូវយើងចូលសេ.អ៊ី.អា ធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ ដើម្បីឲ្យសប្បាយដូចពីមុនវិញ ហើយដល់ពេលពួកយើងឈ្នះចាំឲ្យ ភឿង ធ្វើការមានមុខនាទីខ្ពស់ជាងនេះទៀត ឥឡូវ ភឿង ឯងធ្វើអនុប្រធាននារីឃុំសិនទៅ ។ តែឥឡូវនេះយើងធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍សិនទៅ ឲ្យឈ្នះបដិវត្តន៍ ព្រោះគ្នាយើងនៅខាងលើមានស្រាប់ហើយ យើងកុំគិតគ្នាយើងសុទ្ធតែធ្វើធំទៀត ។ ដូចជា បង ផន ជាប្រធាន



អតីតមន្ទីរសន្តិសុខ ដែលមានទីតាំងនៅក្នុងខេត្តកណ្ដាល ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

នារីស្រុក, អ៊ុំ ឆាន់ ជាគណៈស្រុកអង្គស្នួល, សឿន ប្រធានសេដ្ឋកិច្ចតំបន់១៥ ។ យើងធ្វើយ៉ាងណាបំភាន់មាត៌ាបដិវត្តន៍មួងបន្តិចៗ យើងធ្វើគ្រប់រូបភាពទាំងអស់ដើម្បីប្រឆាំងបដិវត្តន៍ ដើម្បីយើងឈានទៅរបបសង្គមចាស់របស់យើងវិញ ។ យើងសប្បាយហើយចង់ធ្វើអីក៏បានដែរ ស្រេចតែយើងគ្មានអ្នកណាចាប់បង្ខំយើងហើយបានជួបជុំបងប្អូន ធ្វើការក៏អត់ដូចឥឡូវនេះដែរ ។ បន្ទាប់មកយាន និយាយថា ដើម្បីសកម្មភាពប្រឆាំងបដិវត្តន៍ មិត្តឯងទាំងអស់ធ្វើសកម្មភាពប្រឆាំងគ្រប់រូបភាពទាំងអស់ ដើម្បីកុំឲ្យបដិវត្តន៍ខ្លាំងក្លាបាននៅកន្លែងណា យើងធ្វើសកម្មភាពប្រឆាំងនៅកន្លែងនោះតាមការជាក់ស្តែង ។ ក្នុងនោះក៏បានលើកផែនការឡើងដូចតទៅៈ

**ទី១)** ត្រូវធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ បំផ្លាញកម្លាំងបដិវត្តន៍ដូចជាដាំបាយទៅសមរភូមិត្រូវដាក់ថ្នាំពុល ។

**ទី២)** ត្រូវបំផុសពីរឿងសីលធម៌នៅក្នុងមន្ទីរ និងក្នុងមូលដ្ឋានរបស់មិត្តធ្វើការ ។

**ទី៣)** ត្រូវបំផុសប្រជាជនឲ្យទំនាស់ជាមួយអង្គការក្នុងការរៀបចំសហករណ៍ ។

**ទី៤)** ត្រូវរៀបចំកម្លាំងបង្កប់តាមភូមិនីមួយៗ ដែលមិត្តបំផុសបានដើម្បីធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ ។

ឆ្នាំ១៩៧៣ ភឿង បានធ្វើសកម្មភាពដោយយកដីទៅដាក់ក្នុងអង្ករចេកក្នុងមន្ទីរឃុំសម្រាប់បើកឲ្យកងទ័ព ។ ក្រោយមកទៀត ភឿង, អុល និង ណាត បានទាក់ទងគ្នាធ្វើសកម្មភាពយកថ្នាំដេតេពីមន្ទីរឃុំ ទៅដាក់ក្នុងបាយ ហើយយកទៅឲ្យកងទ័ពនៅសមរភូមិ ។

ក្រោយមកបានប្រហែលជាខែ៣ ភឿង ត្រូវផ្លាស់ទៅនៅចម្ការលើដើម្បីធ្វើអង្ករចេក និងកាប់ដើមដំឡូងមី ។ ពេលនោះ ជន (ប្រធាននារីស្រុក) បានសរសេរសំបុត្រហៅ ភឿង មកជួបនៅមន្ទីរស្រុក ។ ពេលជួបជុំគ្នាហើយទើប ជន នាំកម្លាំងមួយក្រុមក្នុងនោះក៏មាន ភឿង ម្នាក់ដែរ ទៅប្រគល់ឲ្យឈ្មោះ សឿន នៅកន្លែងសេដ្ឋកិច្ចតំបន់១៥ ។ ពេលទៅដល់កន្លែងសេដ្ឋកិច្ចតំបន់ សឿន បានចាត់កម្លាំងទាំងអស់ឲ្យធ្វើការនៅភូមិ តាអុង ឃុំតាអុង ស្រុកចម្ការលើ និងចាត់តាំង ភឿង ឲ្យទទួលខុសត្រូវកម្លាំងធ្វើអង្ករចេកនៅចម្ការលើ ។ សឿន បានណែនាំ ភឿង ឲ្យខិតខំធ្វើសកម្មភាពបន្តទៀត ។ សឿន បានចាត់ ភឿង ឲ្យបំផ្លាញដើមដំឡូងមីអស់១០ឡាន ដោយគរចោលទុកឲ្យខូច និងបំផ្លាញអង្ករចេកអស់៥ឡាន ដោយដាក់ក្នុងឃ្លាំងធ្វើឲ្យត្រូវទឹកភ្លៀងខូចអស់ បំផុសរឿងសីលធម៌នៅកន្លែងធ្វើការ និងកសាងកម្លាំង សេ.អ៊ី.អា បន្តទៀត ។

ឆ្នាំ១៩៧៦ ភឿង បានធ្វើសកម្មភាពបំផ្លាញឧបករណ៍អស់មួយចំនួន ដូចជាយកស្លាបព្រា និងចានទៅទម្លាក់ចោលក្នុងទឹកទន្លេអស់ជាច្រើន ។ ក្រៅពីនេះទៅទៀត ក្រុមរបស់ ភឿង បានធ្វើសកម្មភាពបំផ្លាញសម្ភារនៅកន្លែងសេដ្ឋកិច្ច ដូចជា បន្លែ គឺយកមកទុកអោយរលួយចោល ។ ក្រោយមកទៀត ភឿង បានដាក់ថ្នាំដេតេទឹកដាក់ចូលក្នុងមី ដែលធ្វើឲ្យកម្មករហូប (កាលនោះកម្មករក្នុងរោងចក្រអត់មានហូបបាយទេ គឺហូបតែមី) ភឿង បានយកថ្នាំនេះទៅដាក់ក្នុងសម្ល ធ្វើឲ្យកុមារស្លាប់ម្នាក់ ក្រៅពីនេះកម្មករត្រូវពុលថ្នាំទាំងអស់ តែអត់ស្លាប់ទេ គ្រាន់តែរាកធ្វើការមិនកើត ។

ឆ្នាំ១៩៧៧ អ៊ុក អន បានហៅមនុស្សគ្រប់រោងចក្រទាំងអស់មកប្រជុំម្តងទៀតដើម្បីរម្លឹកអំពីបញ្ហាផែនការធ្វើរដ្ឋប្រហារ ។ ពេលប្រជុំនេះ គាត់បានលើកឡើងថា សមរភូមិទាំងអស់ត្រូវប្រុងប្រយ័ត្ន និងត្រូវលើកកម្ពស់ស្មារតីរបស់យើងឲ្យខ្ពស់ថែមទៀតក្នុងបញ្ហានេះកុំប្រហែសខ្វះឲ្យសោះ ។ ម្នាក់ៗត្រូវម្ចាស់ការក្នុងការលាក់ការណ៍ឲ្យជាប់គ្រប់មុខព្រួញទាំងអស់ កុំប្រហែសខ្វួន ពិសេសបំផុតពីរឿងលាក់ការណ៍របស់យើងអំពីផែនការក្នុងការធ្វើរដ្ឋប្រហារនេះ ។

សមរភូមិទាំងអស់ប្រយ័ត្នឆ្លាយមាត់និយាយប្រាប់អ្នកក្រៅពីគ្នាយើង ព្រោះមិត្តខ្លះ គេត្រូវជាមួយយើង ពេលដែលយើងល្អ តែពេលដែលយើងមានបញ្ហាបន្តិចបន្តួចគេអត់លាក់ការណ៍ឲ្យយើងទេ មុខតែគេនិយាយប្រាប់មិត្តផ្សេងៗទៀត ធ្វើផែនការរបស់យើងត្រូវបរាជ័យ ដូច្នេះសមរភូមិទាំងអស់ត្រូវប្រុងប្រយ័ត្នពីរឿងនេះជាមុន ព្រោះបញ្ហាជិតស្និទ្ធវាអាចធ្វើឲ្យទុកចិត្តគ្នា ។

ឆ្នាំ១៩៧៨ ពេលប្រជុំ អ៊ុក អន បានលើកឡើងដើម្បីរម្លឹកអំពីបញ្ហានេះឡើងវិញ ឲ្យរោងចក្រនីមួយៗ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នថែមទៀត ក្នុងការរៀបចំរដ្ឋប្រហារ ។ ក្រោយពីមកប្រជុំវិញនៅរោងចក្របានមួយរយៈ ភឿង មិនទាន់បានធ្វើសកម្មភាពអ្វីទេ ។ ដល់ខែវិច្ឆិកា ថ្ងៃទី២២ ភឿង ត្រូវអង្គការដកមកនៅចំការមនមួយរយៈ ដោយមានភារកិច្ចដាំបាយ ។ ដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨ ភឿង ត្រូវអង្គការចាប់ខ្លួនតែម្តង ។ **កែវ សុភី**

# កម្ចាត់សតិអារម្មណ៍កម្មសិទ្ធិបុគ្គលសួនតួ ឱ្យជ្រះស្រឡះ ដាច់ខាតហើយពង្រឹងជំហរអធនរបស់បក្ស ឱ្យខ្លាំងក្លាថែមទៀត

*(ដកស្រង់ចេញទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តន៍លេខ៧ ខែកក្កដា ឆ្នាំ១៩៧៥ ឯកសារ D២១៣៨១)*

ក្នុងរយៈកន្លងមក បក្សបានយកចិត្តទុកដាក់ ឃោសនាអប់រំ បំពាក់បំប៉ន និងពង្រឹងគោលជំហរវណ្ណៈអធន ឲ្យដល់យុវជនយុវនារីបដិវត្តន៍យើងជាប់ជានិច្ច ។ ដោយបានជ្រួតជ្រាប និងប្រកាន់ខ្ជាប់នូវគោលជំហរវណ្ណៈអធន យុទ្ធជនយុទ្ធនារីយើង ទាំងនៅសមរភូមិមុខ ទាំងនៅសមរភូមិក្រោយ ទាំងនៅតាមមន្ទីរ ក្រសួង និងការដ្ឋានបដិវត្តន៍នានា បានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីសម្រេចភារកិច្ចបដិវត្តន៍ដ៏ឧត្តុង្គឧត្តម ដែលបក្សប្រគល់ជូនរៀងៗខ្លួន មិនថាយប់ឬថ្ងៃ ក្ដៅឬរងារ ធ្ងន់ឬស្រាល លំបាកឬស្រួលឡើយ ។ មិត្តយើង បានលះបង់គ្រួសារ ឪពុកម្ដាយ បងប្អូន ផ្ទះសម្បែង ស្រែភ្លឺ មកចូលរួមក្នុងជួរបដិវត្តន៍ ដើម្បីវាយកម្ទេចសត្រូវមហាឈ្នានពាន ដ៏កំណាចឃោរឃៅហ្វាស៊ីស របស់ចក្រពត្តិអាមេរិក និងបរិវារ រំដោះប្រទេសជាតិ រំដោះប្រជាជន និងរំដោះខ្លួនទាំងស្រុង និងជាស្ថាពរ ។ ក្រៅពីនេះ បងប្អូននៅបានលះបង់កម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញាដែលខ្លួនមាន លះបង់ទាំងមនោសញ្ចេតនាដ៏ខ្ពង់ខ្ពស់ និងល្អបរិសុទ្ធរបស់ខ្លួនទៀត ហើយរហូតដល់ហ៊ានបូជាសាច់ឈាមខ្លួនប្រាណ បូជាយុវភាព និងអាយុជីវិតខ្លួនទៀត ដើម្បីបក្សបដិវត្តន៍ និងប្រជាជន ដោយគ្មានស្ដាយស្រណោះអាឡោះអាល័យ ឬជំពាក់ជំពិន និងបញ្ហាអ្វីបន្តិចសោះឡើយ ។

ដោយសារពលិកម្មដ៏ខ្ពង់ខ្ពស់ និងជំហរលះបង់ដាច់ខាត ឥតលក្ខខណ្ឌរបស់យុទ្ធជន យុទ្ធនារីយើងយ៉ាងនេះហើយ ទើបកងទ័ព



យុវនារីកម្មករបដិវត្តន៍ នៅរោងចក្រក្រុងភ្នំពេញ កំពុងប្រមូលទុកដាក់ផលស្រូវរបស់កងទ័ពបដិវត្តន៍ ដើម្បីឧបត្ថម្ភកងទ័ពនៅសមរភូមិមុខ

បដិវត្តន៍យើង និងប្រជាជនកម្ពុជាយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាអាចវាយឈ្នះចក្រពត្តិអាមេរិក និងបរិវារ ដែលជាមេក្លោងចក្រពត្តិធំជាងគេបង្អស់លើសកលលោក ។ ដោយសារជំហរអធន លះបង់ដាច់ខាត និងឥតលក្ខខណ្ឌរបស់យុទ្ធជន យុទ្ធនារីយើងយ៉ាងនេះហើយ ទើបអត្តភាព និងកិត្យានុភាពរបស់ប្រជាជាតិ និងប្រជាជនកម្ពុជាយើង ត្រូវបានលេចឡើងខ្ពស់ត្រដែតត្រដឹមនៅលើឆាកអន្តរជាតិ ធ្វើឲ្យប្រជាជនសកលលោកកោតសរសើរគោរពស្ញប់ស្ញែង ហើយយកប្រជាជាតិ ប្រជាជនកម្ពុជាយើងធ្វើជាគំរូ និងជានិមិត្តរូបនៃការតស៊ូយ៉ាងមោះមុតដាច់ខាត ឥតសម្រុះសម្រួល ឥតរាថយ ប្រឆាំងទល់នឹងការជ្រៀតជ្រែកឈ្លានពានរបស់ចក្រពត្តិអាណានិគមនិយមបែបថ្មី បែបចាស់គ្រប់ប្រភេទទាំងអស់ ។

នេះជាគុណសម្បត្តិជាមូលដ្ឋានរបស់យុវជន យុវនារីបដិវត្តន៍យើង ក្នុងសម័យសង្គ្រាមបដិវត្តន៍ វាយចក្រពត្តិអាមេរិក និងបរិវារ ដែលយុវជន យុវនារីយើងទាំងអស់គ្នា ត្រូវចងចាំកុំភ្លេច ហើយយកគុណសម្បត្តិរបស់យើងនេះ ទៅកសាងពង្រឹងពង្រីកគោលជំហរវណ្ណៈអធនរបស់បក្ស ឲ្យដល់ខ្លួនយើង ឲ្យកាន់តែរឹងប៉ឹងជួរជង់ថែមទៀត ដើម្បីជាកម្លាំងខ្លាំងក្លាបន្តសម្រេចភារកិច្ចការពារប្រទេស និងកសាងប្រទេសជាតិយើង ក្នុងយុគសម័យថ្មីនេះ ឲ្យបានជោគជ័យធំៗ ថ្មីៗ ទៀតជានិច្ច និងយ៉ាងឆាប់រហ័ស ។

ឥឡូវយើងឈានចូលក្នុងយុគសម័យថ្មី នៃបដិវត្តន៍ប្រជាធិបតេយ្យហើយ ។ យើងរំដោះទូទាំងប្រទេស ។ យើងកាន់កាប់រដ្ឋអំណាចទាំងអស់ទូទាំងប្រទេសហើយ ។ សង្គមកម្ពុជាបានក្លាយទៅជាសង្គមកម្ពុជាថ្មី ដែលគ្មានមនុស្សជិះជាន់មនុស្ស គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់ និងគ្មានវណ្ណៈដែលត្រូវគេជិះជាន់ទៀតឡើយ ។ ប្រជាជនកម្ពុជាទាំងអស់រស់នៅស្មើភាពគ្នាដោយធ្វើការផលិតកម្មបង្កបង្កើនផលទាំងអស់គ្នា ដើម្បីទ្រទ្រង់ជីវិត និងការពារកសាងប្រទេសជាតិទាំងអស់គ្នា ។ នេះជាលក្ខណៈនៃសង្គមកម្ពុជាថ្មី ។ តែទន្ទឹមនឹងនេះ យើងក៏ត្រូវមានទស្សនៈឲ្យច្បាស់លាស់ថា នៅក្នុងសង្គមកម្ពុជាថ្មីយើងនេះ ពិតមែនតែរបបចក្រពត្តិអាណានិគមនិយមថ្មីរបស់ចក្រពត្តិអាមេរិក ត្រូវរលំរលាយទៅហើយ វណ្ណៈសក្តិភូមិ នាយទុន ត្រូវវិនាសសាបសូន្យរលំរលាយទាំងវណ្ណៈ ទាំងរបបនយោបាយទាំងមូលដ្ឋានសេដ្ឋកិច្ចទៅហើយក្តី តែឥទ្ធិពលអាក្រក់របស់សង្គមនេះនៅជះឥទ្ធិពលមកក្នុងជួរបដិវត្តន៍ ក្នុងជួរយុវជន យុវនារីយើង និងក្នុងជួរប្រជាជនយើងនៅឡើយ ដែលអាចធ្វើឲ្យគោលជំហរយើងឃ្លេងឃ្លោងច្របូកច្របល់ ជំពាក់ជំពិន មិនជ្រះស្រឡះរវាងគោលជំហរសតិអារម្មណ៍កម្មសិទ្ធិបុគ្គលស្ទួនត្លួ និងគោលជំហរលះបង់ដាច់ខាតរបស់វណ្ណៈអធន ដើម្បីផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់បដិវត្តន៍ និងប្រជាជន ។

ដូច្នេះ ក្នុងដំណាក់ការថ្មីនៃការតស៊ូបដិវត្តន៍ប្រជាធិបតេយ្យនេះ ដែលការតស៊ូវណ្ណៈកាន់តែតឹងតែង ស្មុគស្មាញខ្លាំងថែមទៀត យុវជន យុវនារីបដិវត្តន៍យើងចាំបាច់ ត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ជានិច្ច កុំឲ្យជំពាក់ជំពិននឹងបញ្ហាកម្មសិទ្ធិ បុគ្គលស្ទួនត្លួអ្វីទាំងអស់ ហើយត្រូវខិតខំកសាងពង្រឹងនូវគោលជំហរលះបង់ដាច់ខាត និងដោយឥតលក្ខខណ្ឌរបស់វណ្ណៈអធន ឲ្យកាន់តែរឹងប៉ឹងស្រួចស្រាវថែមទៀត ដើម្បីធានាដល់ការបន្តវេនបដិវត្តន៍សង្គមនិយម និងកុម្មុយនីស្តនិយមបច្ចុប្បន្ន និងតទៅអនាគត កុំឲ្យប្រែពណ៌សម្បុរបានជារៀងរហូត ។

តាមពិសោធបដិវត្តន៍លើសកលលោក ក៏ដូចជាពិសោធក្នុងចលនាបដិវត្តន៍យើង ក្នុងសភាពដែលយើងរំដោះទូទាំងប្រទេស កាន់កាប់រដ្ឋអំណាចទាំងអស់ទូទាំងប្រទេស ជីវភាព សម្ភារ ក៏កាន់តែឡើងជាងមុន ទោះចង់ឬមិនចង់ច្រើនក្តី តិចក្តី វាតែងមានដុះឡើងនូវគំនិតកម្មសិទ្ធិឯកជនរបស់វណ្ណៈផ្សេងៗ នៅក្នុងជួរយើង ក៏ដូចនៅក្នុងខ្លួនយើងម្នាក់ៗ ។

ឧទាហរណ៍ៈ ពេលដែលយើងរំដោះទីក្រុងភ្នំពេញ និងទូទាំងប្រទេសភ្លាម យុទ្ធជន យុទ្ធនារី និងកម្មាភិបាលយើង ត្រូវចូលមកកាន់កាប់ទីក្រុងខ្លាំងភ្លាម ។ ដូច្នេះ គឺយើងចូលមករស់នៅក្នុងបរិយាកាសសក្តិភូមិ នាយទុន ដែលមានសម្ភារប្រណិតៗ សម្បូរបែបគ្រប់បែបយ៉ាង ដែលពេលមុនយើងមិនដែលមាន មិនដែលស្គាល់ និងមិនដែលជួបប្រទះឡើយ ។ ដូចជាផ្ទះថ្មទឹកម៉ាស៊ីន ភ្លើងអគ្គិសនីឆេះឯងឡាន ម៉ូតូ ទូទឹកកក ស្រាប្រណិតៗ វិទ្យុ នាឡិកាដៃ ដងប៉ាកាប្អូមប្រណិតៗ ទឹកអប់ម្សៅ សាប៊ូក្រអូប ក្រណាត់ និងខោអាវ នីឡុងតេតារ៉ុង គ្រប់បែបយ៉ាង ។ល ។ របស់ទាំងនេះ សម្បូរហូរហៀរពាសពេញគ្រប់ទីកន្លែង ។ ម្ល៉ោះហើយ បើប្រសិនជាយើងមិនបាន

ប្រុងប្រយ័ត្ន បំពាក់បំប៉ន និងពង្រឹងឲ្យដល់ខ្លួនយើងនូវគោលជំហរអធនរបស់បក្សទេ បរិយាកាស សក្តិភូមិ នាយទុននេះ វានឹងស្រូបយើងភ្លាម ។ របស់របរប្រណិតៗទាំងនេះ វាវាយគោលជំហរអធន គោលជំហរបដិវត្តន៍យុទ្ធជន យុទ្ធនារី និងកម្មាភិបាលយើងបានទៀត ។

ដូច្នេះហើយ បានជាកន្លងមក ពេលដែលយើងរំដោះទីក្រុងភ្នំពេញ និងទូទាំងប្រទេសភ្លាម ពេលដែលយើងចូលដល់ទីក្រុងភ្នំពេញ និងទីរួមខេត្តនានាភ្លាម មិត្តយើងមួយចំនួន (ច្រើនដែរ) ដែលភ្លើតភ្លើន សប្បាយរក់រីតែនឹងជ័យជម្នះ ខ្វះស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ ភ្លេចគោលជំហរអធនរបស់បក្ស ក៏ធ្លាក់ខ្លួនទៅក្នុងបរិយាកាសសក្តិភូមិ នាយទុនយ៉ាងឆាប់ភ្លាមមួយរំពេច ។ មិត្តយើងភ្លេចគិតដល់សន្តិសុខរបស់ខ្លួន និងអង្គភាពខ្លួន ភ្លេចគិតការពារកម្លាំងបដិវត្តន៍ ពោលគឺភ្លេចគិតអស់នូវឧបាយកលខ្មាំង ដែលមានផែនការកម្ទេច និងបំផ្លិចបំផ្លាញកម្លាំងបដិវត្តន៍យើងគ្រប់ពេលវេលា ។ មិត្តយើងឃើញតែជ័យជម្នះ ឃើញតែសន្តិភាព ។ ម៉្លោះហើយ ម្នាក់ៗគិតតែបើកឡាន បើកម៉ូតូដើរលេងខ្វាត់ខ្វែង រហូតដល់បណ្តាលឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតអសារឥតការអស់ជាច្រើននាក់ទៀតផង ។ អ្នកខ្លះទៀតគិតតែពីរត់តាមសម្ភារ ដើរប្រមូលយកវិទ្យុ នាឡិកា ដងប៉ាកា ម៉ាស៊ីនថត ។ល ។ តែចំពោះជ័យភណ្ឌដែលមានសារសំខាន់ជាយុទ្ធសាស្ត្រ ដូចជាកាំភ្លើងធំ កាំភ្លើងតូច កាំភ្លើងខ្លី កាំភ្លើងវែង គ្រាប់រំសេវគ្រប់បែបយ៉ាង និងគ្រឿងម៉ាស៊ីនសំខាន់ផ្សេងៗជាច្រើនទៀត នៅរាត់រាយចោលពាសពេញដី គ្មានអ្នកណាយកភ្នែករមិលមើល ឬប្រមែប្រមូលយកទុកដាក់ឡើយ ។

បើជាយុទ្ធនារីវិញ មានខ្លះលបលួចស្លៀកពាក់លខោអាវខ្មាំង លបលួចលាក់ទឹកអប់ ផាត់ម្សៅ ផាត់ក្រែម ឆ្លុះកញ្ចក់នៅក្នុងបន្ទប់ ភ្លេចអស់ការប្រុងប្រយ័ត្នបដិវត្តន៍ ខាងទស្សនៈគោលជំហរ ភ្លេចអស់ភារកិច្ចដែលបក្សប្រគល់ឲ្យមកការពារ និងសម្អាតទីក្រុង គឺសម្អាតទាំងភក់ជ្រាំ សំរាម សម្អាតទាំងឥទ្ធិពលអាក្រក់ និងមនោគមវិជ្ជារបស់ខ្មាំង ។ ក្នុងសភាពភ្លើតភ្លើន ហ៊ឺហា គគ្រឹកគគ្រេង បាត់ម្ចាស់ការ ភ្លេចគោលជំហរបដិវត្តន៍យ៉ាងនេះ បើប្រសិនជាបក្សគ្មានវិធានការជម្លៀសប្រជាជន ឲ្យចេញអស់ពីទីក្រុងភ្នំពេញ និងទីរួមខេត្តនានាទេនោះ ប្រហែលជាខ្មាំងនឹងវាយសង្គ្រប់យើងពីក្រោយទៅវិញ កម្ទេចកម្លាំងបដិវត្តន៍យើងខ្ទេចខ្ទីអស់ ឬយ៉ាងហោចណាស់ ក៏ខ្មាំងស៊ីរូងខាងគោលជំហរបដិវត្តន៍យើង ធ្វើឲ្យផ្ទៃក្នុងជួរបដិវត្តន៍ច្របូកច្របល់ ឥតអង្គការវិន័យ បែកបាក់សាមគ្គី សាបរលាបខាងគោលជំហរបដិវត្តន៍ ។ ដូច្នោះ ខ្មាំងអាចវាយកម្ទេចយើងថ្ងៃណាមួយក៏បាន ។ ដូច្នោះមហាជ័យជម្នះជាប្រវត្តិសាស្ត្រនាថ្ងៃ១៧ មេសារបស់យើង ក៏នឹងត្រូវរលាយខ្យល់ទៅវិញពុំខានឡើយ ។

ទាំងនៅទីក្រុង ទាំងនៅខាងមូលដ្ឋានជនបទ ក្រោយដែលយើងរំដោះទូទាំងប្រទេសភ្លាម ក៏មានដុះចេញសតិអារម្មណ៍ កម្មសិទ្ធិបុគ្គលសួនតួ ទាំងខាងសម្ភារ ទាំងខាងទស្សនៈ គោលជំហរ ទាំងខាងមនោសញ្ចេតនា ដែលស្តែងចេញឡើងជាបាតុភាពសេរី ក្នុងការប្រមូលយករបស់របរជាជ័យភណ្ឌរបស់បក្សសេរីក្នុងការបាញ់រះលេងទាំងយប់ ទាំងថ្ងៃតាមចិត្ត សេរីក្នុងការបំពេញភារកិច្ច មិនសកម្មប្រយុទ្ធ មិនវាយសម្រុក មានសតិអារម្មណ៍ស្ទុកស្ទាញ មិនចង់ធ្វើការនៅជនបទ ចង់ទៅទីក្រុង មានសតិអារម្មណ៍ស្ទុកស្ទាញ ចង់ទៅលេងផ្ទះ ចង់ជួបជុំគ្រួសារ ម៉ែ បងប្អូន សេរីក្នុងការដើរហើរទាក់ទងនារី បុរស និយាយស្តីគ្មានក្របខណ្ឌ គ្មានអង្គការវិន័យ សេរីក្នុងការរស់នៅ ស៊ីចុក ស្លៀកពាក់ ប្រើប្រាស់របស់របររួម មិនគោរពលាក់ការណ៍ របៀបរបបដែលបក្សកំណត់ មានសតិអារម្មណ៍មុខមាត់បុណ្យស័ក្តិ កេរ្តិ៍ឈ្មោះ ស្នាដៃផ្ទាល់ខ្លួន ភ្លេចអស់បក្សដឹកនាំ ភ្លេចអស់កម្លាំងមហាជន ។ ដូច្នេះ ក៏ធ្លាក់ទៅជាអំនួតអួតអាង មិនសុភាពរាបសា មិនប្រុងប្រយ័ត្នបដិវត្តន៍ ។ល ។

ទាំងអស់នេះ ជាបាតុភាពខុសឆ្គងរបស់យើងកន្លងមក ដែលបណ្តាលមកពីសតិអារម្មណ៍ កម្មសិទ្ធិបុគ្គលសួនតួ វាដុះចេញឡើងក្រោយពេលរំដោះទូទាំងប្រទេសភ្លាម ។ ការខុសឆ្គងទាំងនេះរបស់យើង ធ្វើឲ្យប៉ះពាល់ដល់ឥទ្ធិពលដឹកនាំរបស់បក្ស ដល់អត្តភាព និងកិត្យានុភាពនៃចលនាបដិវត្តន៍យើង ប៉ះពាល់ដល់គោលជំហរបដិវត្តន៍យើងដែលល្អបរិសុទ្ធផូរផង់ ខូចខាតដល់កម្លាំងបដិវត្តន៍អស់មួយចំនួន ខូចខាត បាត់បង់ អន្តរាយអស់ទាំងសម្ភារ និងទ្រព្យសម្បត្តិរួមរបស់បក្សជាច្រើនទៀត ។ ដូច្នេះ បើប្រសិនជាបក្សគ្មានវិធានការទប់ទល់ អប់រំ បំពាក់បំប៉ន និងពង្រឹងនូវគោលជំហរលះបង់នៃវណ្ណៈអធនឲ្យទាន់ពេលវេលាទេ គំនិតកម្មសិទ្ធិបុគ្គលសួនតួនេះ វានឹងចេះតែរីករាលដាលធំឡើងៗ ហើយវានឹងអាចនាំចលនា

បដិវត្តន៍យើង នាំយុវជន យុវនារីបដិវត្តន៍យើង ទៅកាន់ក្ដីមហន្តរាយពុំខានឡើយ ។

យុវជន យុវនារី យើង ត្រូវឈឺចាប់ សោកស្ដាយជាទីបំផុតចំពោះការខុសឆ្គងរបស់យើងកន្លងមកនេះ ហើយយកវាជាបទពិសោធខុស ដើម្បីរៀនសូត្រពង្រឹងនូវគោលជំហរអធនរបស់បក្សឲ្យបានកាន់តែរឹងប៉ឹងស្រួចស្រាវថែមទៀត ដើម្បីបន្ដវាយសម្រុកសម្រេចភារកិច្ចបដិវត្តន៍ថ្មីគឺការពារប្រទេស ស្ដារសេដ្ឋកិច្ច និងកសាងប្រទេសកម្ពុជាយើងឲ្យបានខ្លាំងក្លា និងសម្បូរសប្បាយថ្កុំថ្កើងរុងរឿង ក្នុងពេលដ៏ឆាប់ខាងមុខនេះ ។

កន្លងមក យុវជន យុវនារីយើង បានធ្វើពលិកម្មកម្រិតខ្ពស់ លះបង់សព្វបែបយ៉ាង លះបង់តាំងពីឪពុកម្ដាយ គ្រួសារ បងប្អូន លះបង់ផ្ទះសម្បែង ស្រែចម្ការ គោក្របី លះបង់ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត និងកម្លាំងបញ្ញា លះបង់ទាំងមនោសញ្ចេតនា និងយុវភាពរបស់ខ្លួនដែលកំពុងតែរីកស្រស់បំព្រង ប្រៀបបីដូចជាបុប្ផារីកស្គុសស្គាយ ក្រោមទឹកសន្សើមពេលព្រលឹម រហូតដល់ហ៊ានលះបង់សាច់ឈាម ខ្លួនប្រាណ និងអាយុជីវិតខ្លួនទៀត ដើម្បីបក្សបដិវត្តន៍ និងប្រជាជន រហូតដល់ដណ្ដើមបានមហាជោគជ័យទាំងស្រុង និងជាស្ថាពរសព្វថ្ងៃនេះ ។ ដូច្នេះ យុវជន យុវនារីយើង គ្មានហេតុផលអ្វីទៅស្ដាយស្រណោះ អាឡោះអាល័យ ឬជំពាក់ជំពិន នឹងកម្មសិទ្ធិបុគ្គល ស្វនត្ថ កំប៉ិកកំប៉ុកទៀតឡើយ ។ ទោះជាកម្មសិទ្ធិខាងសម្ភារ ឡាន ម៉ូតូ នាឡិកាដៃ វិទ្យុ ឬរបស់របរប្រើប្រាស់ផ្សេងទៀតក្ដី ទោះជាកម្មសិទ្ធិខាងអំណាច នាទីតំណែង មុខមាត់បុណ្យស័ក្ដិ ទោះជាកម្មសិទ្ធិខាងមនោសញ្ចេតនាក្ដី សុទ្ធតែមិនអាចយកមកប្រៀបផ្ទឹមនឹងអាយុជីវិតយើងដែលបានប្ដេជ្ញាបូជាជូនបក្សបដិវត្តន៍ និងប្រជាជនទៅហើយនោះទេ ហើយក៏រឹតតែមិនអាចយកមកប្រៀបផ្ទឹម និងកិត្តិយសបដិវត្តន៍ដ៏រុងរឿង ថ្លៃថ្លា របស់យើងបានទៀត ។

កន្លងមក មិត្តយើងបានពុះពារជម្នះឧបសគ្គច្រើនរាប់មិនអស់ ទាំងឧបសគ្គក្នុងធម្មជាតិ ទាំងឧបសគ្គខ្មាំង ទាំងឧបសគ្គអត្តនោម័តិក្នុងខ្លួនយើងម្នាក់ៗ ឆ្លងកាត់ការលំបាកវេទនាសព្វបែបយ៉ាង លំបាកទាំងខាងផ្លូវកាយ អត់ឃ្លាន នឿយហត់ ខ្វះសម្លៀកបំពាក់ ខ្វះថ្នាំសង្កូវគ្រាប់រំសេវ ខ្វះសព្វខ្វះគ្រប់ តែមិត្តយើងប្រយុទ្ធដាច់ខាត គ្មានរួញរាស្ទាក់ស្ទើរឡើយ ប្រយុទ្ធកសាងគោលជំហរសតិអារម្មណ៍បដិវត្តន៍ឲ្យក្រហមឆ្អិនឆ្អៅជានិច្ច ប្រយុទ្ធបំពាក់គោលជំហរវណ្ណៈអធនរបស់បក្សឲ្យកាន់តែរឹងប៉ឹង កាន់តែផ្ទូរផង់ល្អបរិសុទ្ធឡើងជានិច្ច ប្រយុទ្ធ



កម្មករបដិវត្តន៍នៅឃ្លាំងរដ្ឋ កំពុងដឹកជញ្ជូនដីរក្រែបចេញពីកប៉ាល់ យកទៅដាក់នៅក្នុងឃ្លាំង សម្រាប់នាំចេញទៅលក់នៅក្រៅប្រទេស

សម្រេចភារកិច្ចតូច ធំ ទាំងឡាយដែលបក្សប្រគល់ឲ្យ និងប្រយុទ្ធវាយកម្ទេចសង្គ្រាមឈ្លានពានដ៏កំណាចឃោរឃៅ ហ្វាស៊ីស អស្ចារ្យរបស់ចក្រពត្តិអាមេរិក និងបរិវារ រហូតដល់ដណ្តើមបានមហាជ័យជម្នះទាំងស្រុង និងជាស្ថាពរ ។

ចុះឥឡូវ យើងមានសុខសន្តិភាព យើងមានរដ្ឋអំណាច យើងមានសេដ្ឋកិច្ចនៅក្នុងដៃ ទោះបីយ៉ាងណាក៏យើងមិនលំបាកវេទនាដូចកាលសម័យសង្គ្រាមដែរ ។ ម្យ៉ាងទៀត បក្សក៏យកចិត្តទុកដាក់ឧបត្ថម្ភផ្គត់ផ្គង់ ការស៊ីចុក ស្លៀកពាក់ និងថ្នាំសង្កូវដល់មិត្តយើងល្មមគ្រប់គ្រាន់និងរស់នៅ ធ្វើការងារបានហើយ ។ដូច្នេះ យើងមិនត្រូវបណ្តែតបណ្តោយឲ្យសម្ភារកំប៉ិកកំប៉ុកទាំងអស់នេះ វាវាយគោលជំហរបដិវត្តន៍យើងដួលឡើយ ។ ឥឡូវ មានមិត្តយុទ្ធជន យុទ្ធនារី និងកម្មាភិបាលយើងមួយចំនួនច្រើន មានភារកិច្ចមកធ្វើការងារនៅក្នុងក្រុង ។ ពិតមែនហើយ រស់នៅក្នុងទីក្រុង គឺយើងស្ថិតនៅក្នុងបរិយាកាសសក្តិភូមិ នាយទុន តែយើងជឿជាក់ថា មិត្តយុទ្ធជន យុទ្ធនារី និងកម្មាភិបាលយើងដែលធ្លាប់វាយឈ្នះចក្រពត្តិអាមេរិក និងបរិវារ ធ្លាប់វាយឈ្នះសក្តិភូមិ នាយទុន ពិតជានិងវាយឈ្នះ


យុវនារីសហករណ៍កំពុងជ្រើសរើសស្រូវល្អៗ ទុកសម្រាប់ធ្វើពូជ

ហើយនឹងវាយកម្ទេចនូវសតិអារម្មណ៍កម្មសិទ្ធិបុគ្គលស្វ័នត្ត ដែលជាសតិអារម្មណ៍ និងមនោគមវិជ្ជារបស់វា មិនឲ្យវាចាប់ប៉ិចពន្លក នៅក្នុងខ្លួនយើងឡើយ ។ ព្រមជាមួយនេះ មិត្តយើងពិតជានឹងខិតខំរក្សាការពារ គោលជំហរវណ្ណៈអធនរបស់បក្ស ឲ្យនៅតែក្រហមឆ្អិនឆ្អៅតទៅទៀត ហើយប្តេជ្ញាបំពាក់បំប៉នឲ្យខ្លួននូវគោលជំហរវណ្ណៈអធនរបស់បក្សនេះ ឲ្យកាន់តែរឹងប៉ឹងល្អផូរផង់ឡើងថែមទៀត ដើម្បីសម្រេចភារកិច្ចបដិវត្តន៍ឲ្យបានជោគជ័យទាំងស្រុង គឺភារកិច្ចការពារប្រទេសជាតិ និងភារកិច្ចកសាងប្រទេសជាតិ ។

ជាវិធានការជាក់ស្តែង ដើម្បីពង្រឹងគោលជំហរវណ្ណៈអធនរបស់បក្សឲ្យបាន១០០ភាគរយដាច់ខាត មិត្តយុវជន យុវនារីយើងត្រូវ ៖

១) ប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ច ខាងទស្សនៈគោលជំហរ ក្នុងពេលដែលយើងដណ្តើមបានមហាជ័យជម្នះ មានរដ្ឋអំណាចទូទាំងប្រទេស មានសេដ្ឋកិច្ចស្តុកស្តម្ភនៅក្នុងដៃយ៉ាងនេះ និងក្នុងពេលដែលយើងរស់នៅក្នុងបរិយាកាសសក្តិភូមិ នាយទុនដូចសព្វថ្ងៃនេះ កុំភ្លើតភ្លើន កុំរំភើប ហ៊ឺហា គគ្រឹកគគ្រេង ។

២) រស់នៅសមរម្យតាមបែបបក្សកំណត់ឲ្យ គឺគ្មានកម្មសិទ្ធិឯកជន ស្វ័នត្តអ្វីទាំងអស់ ។ យើងប្រកបការងារដែលជាភារកិច្ចបដិវត្តន៍ ដោយអស់ពីកម្លាំងចិត្ត កម្លាំងកាយ និងកម្លាំងបញ្ញារបស់ខ្លួន និងដោយប្រើប្រាស់មធ្យោបាយឧបករណ៍ និងរបស់របរប្រើប្រាស់ផ្សេងៗ ដែលជាកម្មសិទ្ធិរួមរបស់បក្ស ដោយសន្សំសំចៃខ្ពស់បំផុត ដោយទ្រាំទ្រលំបាកវេទនា ស្មុគស្មាញខ្ពស់បំផុត និងពុះពារឧបសគ្គតូច ធំ គ្រប់បែបយ៉ាង ។ ពុះពារទ្រាំទ្រការលំបាកទាំងខាងសម្ភារ ពុះពារទ្រាំទ្រទាំងខាងសតិអារម្មណ៍ ។ ក្នុងពេលជួបឧបសគ្គដំណើរការងារមិនបានសម្រេច បានខ្លះ មិនបានខ្លះ ខ្វះខាតខ្លះ យើងត្រូវទ្រាំទ្រលំបាកឆ្លងបញ្ហានេះឲ្យបាន ពុះពារឆ្លងកាត់ឲ្យបាន ។

ម្យ៉ាងទៀត ពេលដែលយើងរំដោះទូទាំងប្រទេសហើយ ក៏យើងនៅតែមិនទាន់បានជួបជុំគ្រួសារ ឪពុកម្តាយ បងប្អូន នៅតែអនុការវិន័យ នៅតែលាក់ការណ៍សម្ងាត់ នៅតែប្រយុទ្ធបំពេញភារកិច្ចតូច ធំ តទៅទៀត តែយើងក៏មិនធុញទ្រាន់ ត្អូញត្អែរ ឬតូចចិត្តទោមនស្សអ្វីឡើយ ។ នេះហើយហៅថា "អធនលើ" ។

**ឆេង ទ៉េង**

# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសារ ចាប់ពីខែមេសា ដល់ ខែធ្នូ ឆ្នាំ២០១៦
















កាលបរិច្ឆេទបញ្ចាំង៖ រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង១០ ៖ ០០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល

ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

លោក ម៉ែន ពិចិត្រ
មជ្ឈមណ្ឌលឯកសារកម្ពុជា
ទូរស័ព្ទលេខ ០២៣ ២១៤ ០០៩
អ៊ីម៉ែល: truthmpechet@dccam.org
គេហទំព័រ: www.dccam.org l www.cambodiasri.org

**ខែមេសា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែមេសា វេលាម៉ោង ១ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "គុកឥតជញ្ជាំង" ដោយទូរទស្សន៍ ជាតិកម្ពុជា (៩៥ នាទី)

◆ ថ្ងៃទី៨ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ការងារសម្ងាត់នៅមន្ទីរស-២១" ដោយ ដេវីត អូកូហ្វូណា (David Okuefuna) (៣០ នាទី)

◆ ថ្ងៃទី២២ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ឋាននរក៩ជាន់" ដោយ Cinema Dept. FPD ក្នុងឆ្នាំ១៩៨៧ (១៣១.២៨នាទី)

◆ ថ្ងៃទី២៩ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ប្រាសាទអង្គរវត្តដែលកំបាំង" ដោយ Discover Magazine ក្នុងឆ្នាំ១៩៩៩ (៣០.១៥ នាទី)

**ខែឧសភា ឆ្នាំ២០១៦**

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "កម្ពុជា : ការស្លាប់ និង ការចាប់កំណើត" ដោយ Germany ក្នុងឆ្នាំ១៩៨០ (៩០ នាទី)

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "អគ្គការ" ដោយ Germany ក្នុងឆ្នាំ ១៩៨១ (៩០ នាទី)

**ខែមិថុនា ឆ្នាំ២០១៦**

◆ ថ្ងៃទី៣ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "សង្គ្រាមក្នុងព្រៃ" ដោយ Germany ក្នុងឆ្នាំ ១៩៨៣ (៩០ នាទី)

◆ ថ្ងៃទី១០ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "រវាងសន្តិភាព និងយុត្តិធម៌ : រឿងកន្ទួលហួសទៅសូមឲ្យកន្ទួលហួសទៅចុះ" ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) ក្នុងឆ្នាំ១៩៩៩ (៣៧នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ជីវិ២ (ជីវិជនភៀសខ្លួន)" ដោយ រិទ្ធី ប៉ាន់ ក្នុងឆ្នាំ១៩៨៩ (៦០ នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលា ម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ប៉ុល ពត : ការសម្លាប់" ដោយ ភីធើ ហើខំ (Peter Hercombe) (៥១ នាទី)

***ខែកក្កដា ឆ្នាំ២០១៦***

◆ *ថ្ងៃទី១ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «សាក្សីកម្ពុជា» បណ្ណសាររបស់ ដេវីត ហក (David Hawk Archives) (១១១.២នាទី)*

◆ *ថ្ងៃទី៨ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «សកម្មភាពគោរពវិញ្ញាណក្ខន្ធនៅបូជនីយដ្ឋានជើងឯក» ដោយ FPD ក្នុងឆ្នាំ១៩៩៨*

◆ *ថ្ងៃទី១៥ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ព្រះអាទិទេពចុងក្រោយ» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១១៨នាទី)*

◆ *ថ្ងៃទី២២ ខែកក្កដា វេលាម៉ោង១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «តំបន់អន្ទង់វែង (តាម៉ុក)» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១៧៤.៥៧នាទី)*

◆ *ថ្ងៃទី២៩ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «កម្ពុជា ៣បូក៤ ឆ្នាំទីសូន្យ និងឆ្នាំទី១» ក្នុងឆ្នាំ១៩៧៩ (១៥៦នាទី)*

***ខែសីហា ឆ្នាំ២០១៦***

◆ *ថ្ងៃទី៥ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ស្រមោលអតីតកាល : រឿងចំនួនបួនដែលនិយាយអំពីការផ្សះផ្សា» ដោយ Express TV (១២០នាទី)*

◆ *ថ្ងៃទី១២ ខែសីហា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ :១៥ រសៀល បញ្ចាំងរឿង «ស្រមោលរបស់ ប៉ុល ពត» ដោយ អាមេនដា ផែក (Amanda Pike) ក្នុងឆ្នាំ២០០២ (២៥នាទី)*

◆ *ថ្ងៃទី១៩ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ក្ដីសង្ឃឹមដ៏តិចតួចចេញពីវាលពិឃាត» ដោយ ធារ៉ា ដេលហ្កាដូ (Tiara Delgado) (៣៨នាទី)*

◆ *ថ្ងៃទី២៦ ខែសីហា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ទម្លាយភាពស្ងប់ស្ងាត់» ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា (៦៩នាទី)*

***ខែកញ្ញា ឆ្នាំ២០១៦***

◆ *ថ្ងៃទី២ ខែកញ្ញា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «បទសម្ភាសន៍ជាមួយ ប៉ុល ពត» ដោយ ភីធើ ហ្វ្រូបឺក (Peter Froberg) ក្នុងឆ្នាំ២០០៤ (៥១នាទី)*

◆ *ថ្ងៃទី៩ ខែកញ្ញា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ប៉ុល ពត : ដំណើរទៅកាន់វាលពិឃាត» ដោយ ជេន ចនស្តុន (Jane Johnston) (៥០នាទី)*

◆ *ថ្ងៃទី១៦ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «យុត្តិធម៌ដែលបានពន្យាពេល និងយុត្តិធម៌ដែលបានបដិសេធ (ការកាត់ទោសមេដឹកនាំខ្មែរក្រហម)» ក្នុងឆ្នាំ២០០៥ (៥៤.២៤នាទី)*

◆ *ថ្ងៃទី២៣ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «រឿងរ៉ាវពីទឹកដីកម្ពុជាក្រោម» (៧០នាទី)*

**ខែតុលា ឆ្នាំ២០១៦**

◆ ថ្ងៃទី៧ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល បញ្ចាំងរឿង "នៅក្រោយជញ្ជាំងមន្ទីរស-២១" ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៧ (៣០នាទី)

◆ ថ្ងៃទី១៨ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល បញ្ចាំងរឿង "ដំណើរទៅកាន់វាលពិឃាត" ដោយ ជេន ចនស្តុន (Jane Jonhston) (៥០នាទី)

◆ ថ្ងៃទី២១ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៖ ១៥រសៀល បញ្ចាំងរឿង "ដល់ពេលស្វែងរកយុត្តិធម៌" ដោយ KMF Films ក្នុងឆ្នាំ២០០៧ (៤០នាទី)

◆ ថ្ងៃទី២៨ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល បញ្ចាំងរឿង "មើលទៅមុខ មើលទៅក្រោយ" ដោយ DMC ក្នុងឆ្នាំ២០០៧ (៥២.៣០នាទី)

**ខែវិច្ឆិកា ឆ្នាំ២០១៦**

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល បញ្ចាំងរឿង "ការរាំទៅរកការស្លាប់ ៖ សត្វស្វា មន្តអាគម និងភាពរីលវល់របស់កម្ពុជា" ដោយ ចេនេត ហ្គាតនើ (Janet Gardner) ក្នុងឆ្នាំ២០១០ (៥៦នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល បញ្ចាំងរឿង "ការកាត់ទោស ប៉ុល ពត នៅអន្លង់វែង នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧" ដោយ ឡុង សារិន ក្នុងឆ្នាំ ១៩៩៧ (៤៣.៣០នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង "៣ឆ្នាំ ៨ខែ ២០ថ្ងៃ" ដោយ រ៉ូសេន សេដណាតា (Roshane Saidnattar) ក្នុងឆ្នាំ២០០៩ (៩៨.០៦នាទី)

◆ ថ្ងៃទី២៥ ខែវិច្ឆិកា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល បញ្ចាំងរឿង "ក្មេងសម្រាប់ដាក់លក់" ដោយ NBC TV ក្នុងឆ្នាំ២០០៤ (៤៣នាទី)

**ខែធ្នូ ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែធ្នូ វេលាម៉ោង១០ ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល បញ្ចាំងរឿង "វិប្បដិសារី" ក្នុងឆ្នាំ២០០៨ (Royal Archives)

◆ ថ្ងៃទី៩ ខែធ្នូ វេលាម៉ោង១០ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល បញ្ចាំងរឿង "កងទ័ពខ្មែរក្រហម" ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) និង សេន មេត្តា (Sien Meta) ក្នុងឆ្នាំ ២០០៧ (៩៥នាទី)

◆ ថ្ងៃទី១៦ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ ៖ ១៥ រសៀល បញ្ចាំងរឿង "ពេលព្រះអាទិត្យអស្តង្គត" ដោយ ព្រះបាទ នរោត្តម សីហនុ

◆ ថ្ងៃទី២៣ ខែធ្នូ វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង "កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់" ដោយ ចន ពីរ៉ូស៊ី (Jonh Pirozzi) (១០៧នាទី)

◆ ថ្ងៃទី៣០ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង "ក្បង់ទឹកទន្លេ" ដោយ កល្យាណី ម៉ម ក្នុងឆ្នាំ២០១២ (៨៣នាទី)

# ការិយាល័យព័ត៌មានសាធារណៈ

*«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ឆេង វ៉េង តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthveng.c@dccam.org ។*





















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យ សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthmpechet@dccam.org ។

**◆ទីកន្លែង : អគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# គេហទំព័រទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរ
# www.truthcambodia.com

ទស្សនាវដ្ដីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។

គេហរទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្ដីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។

អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើងដោយស្ទេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតទ្បើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្ដល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្ដិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យ ដើម្បីសេចក្ដីសុខក្នុងខ្លួនជាអមតៈដែរ ។

សរុបសេចក្ដីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ធ្វើសេចក្ដីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទ មុនការចេញផ្សាយ ។

គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។

# សង្គ្រាមធ្វើឱ្យខ្ញុំបែកពីគ្រួសារ

សោម វ៉ែន មានស្រុកកំណើតនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ គាត់ជាកូន ប្រុសច្បងក្នុងចំណោមបងប្អូនប្រុសស្រីបីនាក់ នៅក្នុងគ្រួសារកសិករមួយ ។

វ៉ែន បានរៀបការនៅអាយុ១៩ឆ្នាំ ជាមួយប្រពន្ធឈ្មោះ ភក្តី និងមានកូនបីនាក់ ។ នៅឆ្នាំ១៩៧៤ ដោយសារតែភូមិស្រុករបស់ វ៉ែន ស្ថិតក្នុងតំបន់រំដោះ ទើបគាត់ស្ម័គ្រចិត្តចូលធ្វើជាយោធាខ្មែរក្រហម ធ្វើការតស៊ូប្រឆាំងជាមួយរដ្ឋាភិបាល លន់ នល់ ។ ចាប់តាំងពីពេលដែល វ៉ែន ចូលធ្វើយោធា គាត់បានបែកពីប្រពន្ធកូន និងគ្រួសាររហូត ព្រោះថ្នាក់លើបានចាត់តាំងគាត់ឲ្យមកចូលរួមវាយនៅសមរភូមិខាងភ្នំពេញ ។

នៅឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះទូទាំងប្រទេសនាថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការបានចាត់តាំងកងរបស់ វ៉ែន មកឈរជើងនៅខេត្តរតនគិរី ។ វ៉ែនក៏ ដូចជាសមាជិកក្នុងកងរបស់ខ្លួនមានតួនាទីល្បាតតាមខ្សែបន្ទាត់ព្រំដែន ។ វ៉ែន បានឲ្យដឹងថា ចំពោះទ័ពការពារព្រំដែន ការហូបចុក គឺមិនសូវខ្វះខាតទេ ។ ទោះបីជាមិនមានការខ្វះខាតអ្វីក៏ដោយ ក្នុងចិត្តរបស់ វ៉ែនមិនដែលរីករាយម្តងណាទេ ។ មួយថ្ងៃៗ គាត់នៅតែជាមួយកាំភ្លើង និងរស់នៅដោយភាពភ័យខ្លាចជានិច្ច ។ គាត់មិនដែលបានទៅជួបប្រពន្ធ កូន និងគ្រួសារ ហើយក៏មិនដឹងថាអ្នកទាំងអស់គ្នាសុខទុក្ខ ឬរស់នៅទីណានោះទេ ។


ទំនប់ថ្មីត្រូវបានកសាងឡើងក្នុងអំឡុងពេល តាម៉ុក គ្រប់គ្រងអន្លង់វែង ។ ទំនប់នេះត្រូវបានប្រើប្រាស់សម្រាប់ស្តុកទឹកនារដូវប្រាំង ។

វ៉ែន ឈរជើងការពារនៅខេត្តរតនគិរីរហូតដល់ថ្ងៃដែលរបបខ្មែរក្រហមដួលរលំ ទើបភៀសខ្លួនជាមួយនឹងក្រុមរបស់ខ្លួនមកអន្លង់វែង ។ វ៉ែន បានឲ្យដឹងថា នៅតំបន់អន្លង់វែងនេះ ស្ថានភាពប្រជាជន មានភាពល្អប្រសើរ ពេលស្ថិតក្រោមការគ្រប់គ្រងរបស់ តាម៉ុក ។ គាត់មិនដែលឃើញ តាម៉ុក ផ្ទាល់ទេ គាត់បានត្រឹមតែដឹងថា តាម៉ុក ពេលនោះ មិនមែនជា តាម៉ុក ដែលជាមនុស្សកាចសាហាវសម្លាប់ប្រជាជន ដូចពីមុនឡើយ ។ តាម៉ុក មានការយកចិត្តទុកដាក់ចំពោះសុខទុក្ខ និងការរស់នៅរបស់ប្រជាជនជានិច្ច ។ គាត់តែងតែផ្តល់ស្បៀងអាហារ និងសម្ភារផ្សេងៗដល់ប្រជាជន ជាពិសេសគាត់បានសាងសង់ស្ពានអូរជីក ទំនប់ មន្ទីរពេទ្យ សាលារៀន ផ្លូវសម្រាប់ប្រជាជននៅតំបន់អន្លង់វែងនេះប្រើប្រាស់ទៀតផង ។

ក្រោយថ្ងៃធ្វើសមាហរណកម្មឆ្នាំ១៩៩៨ តំបន់អន្លង់វែងបានក្លាយជាតំបន់សន្តិភាព ហើយប្រជាជនរស់នៅដោយសុខសាន្តលែងភ័យខ្លាចនឹងការប្រយុទ្ធទៀត ។ នៅពេលសង្គ្រាមរវាងខ្មែរក្រហម និងរដ្ឋាភិបាលបានបញ្ចប់ វ៉ែន នៅបន្តការងារជាយោធាការពារព្រំដែនដែលរហូតដល់ថ្ងៃដែលគាត់ចូលនិវត្តន៍ ។

ទោះបីជា ប្រជាជនរស់នៅដោយក្តីរីករាយក៏ដោយ សម្រាប់ វ៉ែន នៅតែមានអារម្មណ៍ឈឺចាប់ ព្រោះមិនបានជួបជុំប្រពន្ធកូន និងគ្រួសារដូចអ្នកឯទៀត ។ ព្រោះតែសង្គ្រាម បានធ្វើឲ្យ វ៉ែន ចាកឆ្ងាយពីផ្ទះសម្បែង បែកបាក់ ប្រពន្ធកូន និងក្រុមគ្រួសារ ។ ក្រោយសង្គ្រាមផុតរលត់ វ៉ែន គ្មានសល់អ្វីទាំងអស់ ក្រៅពីជីវិតដែលរួចផុតពីសេចក្តីស្លាប់ ។

ដោយបាត់ដំណឹង និងរកគ្រួសារមិនឃើញ ទើប វ៉ែនសម្រេចចិត្តរៀបគ្រួសារថ្មីនៅអន្លង់វែង ជាមួយនារីឈ្មោះ ប៉ិច និងមានកូនបួននាក់(ប្រុសពីរ និងស្រីពីរនាក់) ។ បច្ចុប្បន្ន បន្ទាប់ពីចូលនិវត្តន៍ពីការងារជាយោធាការពារព្រំដែន វ៉ែន ប្រកបរបរជាកសិករ ។

**ឆេត ផាត**

# ការយល់ដឹងពីរបបខ្មែរក្រហមតាមរយៈអតីតយោធាខ្មែរក្រហម នៅតំបន់អន្លង់វែង

អន្លង់វែងជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម ប្រឆាំងរដ្ឋាភិបាល ។ ប្រជាជននៅក្នុងតំបន់នេះស្ទើរគ្រប់វ័យ បានចូលបម្រើចលនាខ្មែរក្រហមតាមរយៈការឃោសនា និងការចាត់តាំង ។ ប្រជាជនដែលបានចូលចលនានេះ ត្រូវបានបែងចែកទៅតាមមន្ទីរអគ្គភាពទ័ពការពារព្រំដែន អគ្គភាពដឹកជញ្ជូន ឬក្រុមយាមឃ្លាំងសម្ភារ ។ ជាក់ស្តែងខ្ញុំបានជួបអ៊ំ សោម ភាព អាយុ៦០ឆ្នាំ មានទីលំនៅឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ គាត់មានប្រសាសន៍ថា គាត់បានចូលធ្វើយោធាតាំងពីឆ្នាំ១៩៧២ មកម្ល៉េះ ដោយមិនបានរៀនសូត្រទេ ។

ពេលចូលដំបូង ខ្មែរក្រហមឲ្យគាត់ចូលរៀនផ្នែកនយោបាយ និងប្រវត្តិសាស្ត្រ ដោយខ្មែរក្រហមជាអ្នកឧទ្ទេសនាម ចំណែកគាត់ចាំតែស្តាប់ប៉ុណ្ណោះ ។ នៅអំឡុងពេលនោះ វិន័យតឹងរ៉ឹង ម៉ឺងម៉ាត់ និងហ្មត់ចត់ណាស់ ហើយការងារទាំងឡាយដែលបានចាត់តាំងដោយអង្គការ គ្មាននរណាម្នាក់ហ៊ានជំទាស់ឡើយ ។ ទាហានម្នាក់ៗចាំប្រវត្តិសាស្ត្រ និងភូមិសាស្ត្រយ៉ាងច្បាស់លាស់ ។ ទោះយ៉ាងណាគាត់មិនបានហ្វឹកហាត់យុទ្ធសាស្ត្រយោធាច្រើនដែរ គឺត្រូវទៅឈរជើងការពារនៅសមរភូមិ ។

រហូតដល់ឆ្នាំ១៩៧៩ ឪពុកម្តាយក្មេកគាត់ ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយមិនដឹងមូលហេតុ ធ្វើឲ្យគាត់មានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំង ព្រោះពេលនោះគាត់នៅជាយុទ្ធជនគ្មានសិទ្ធិអំណាចទេ ។ គាត់បានរងរបួសពិការជើងស្តាំ ពេលដែលគាត់ឈរជើងការពារតាមព្រំដែនខេត្តព្រះវិហារនៅឆ្នាំ១៩៨២ ។ បន្ទាប់មកទើបគាត់ចេញពីខេត្តព្រះវិហារមករស់នៅតំបន់អន្លង់វែង ខេត្តឧត្តរមានជ័យជាមួយ តាម៉ុក វិញ ។ ចាប់តាំងពីខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាលក្នុងឆ្នាំ១៩៩៨ គាត់ក៏សម្រេចចិត្តលាឈប់ពីយោធា ។

ទោះបីយ៉ាងណា គាត់មិនដែលបាននិយាយរឿងរ៉ាវរបស់គាត់ប្រាប់ទៅកូនចៅទេ ដោយគាត់គិតថា ហេតុការណ៍នេះបានកន្លងហួសទៅហើយ ហើយការឈឺចាប់ក៏បានបាត់បង់ទៅហើយដែរ ។ គាត់មិនចង់រំឭករឿងរ៉ាវនេះឡើងវិញទេ ។

រឿងរ៉ាវរបស់ ភាព ដែលបានចូលរួមតស៊ូជាមួយខ្មែរក្រហមរហូតធ្លាក់ខ្លួនពិការ និងចុងក្រោយមករស់នៅអន្លង់វែង ក៏មិនខុសពីអតីតខ្មែរក្រហមផ្សេងទៀតដែលភៀសខ្លួនមករស់នៅតំបន់នេះដែរ ។ សម្រាប់ខ្ញុំ នៅថ្ងៃខាងមុខ ខ្ញុំចង់ឲ្យតំបន់អន្លង់វែងដែលជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមបានដឹងឮដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈពីហេតុការណ៍ជូរចត់របស់ប្រជាជនក្នុងតំបន់នេះ ។

ខ្ញុំក៏ចង់ឲ្យប្រជាជន និងអាជ្ញាធរទាំងឡាយនៅក្នុងស្រុកអន្លង់វែង ចូលរួមអភិរក្សតំបន់នេះឲ្យក្លាយទៅជាតំបន់មួយដែលមានការដឹងឮជាសកល ហើយសូមឲ្យរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងទេសចរណ៍យកចិត្តទុកដាក់ការពារ និងរៀបចំតំបន់នេះឲ្យមានសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរណ៍ដែលចូលមកទស្សនា ដូចជា ផ្នូរប៉ុល ពត ទីបញ្ជាការ និង ផ្ទះតាម៉ុក ជាដើម ។

បន្ថែមលើនេះ ខ្ញុំសំណូមពរឲ្យក្រសួងអប់រំគួរតែដាក់បញ្ចូលតំបន់ប្រវត្តិសាស្ត្រអន្លង់វែងក្នុងកម្មវិធីសិក្សាដើម្បីឲ្យសិស្សានុសិស្សបានស្គាល់ពីជីវិតរបស់អតីតខ្មែរក្រហមដែលឃ្លាតពីស្រុកកំណើតមករស់នៅតំបន់នេះដែរ ។ **ពេជ្រ សំណាង**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ជីវិតនៅអន្លង់វែង ក្រោមការគ្រប់គ្រងរបស់ តាម៉ុក

របបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ និងបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ទោះបីរបបកម្ពុជាប្រជាធិបតេយ្យធ្លាក់ពីអំណាចក៏ដោយ ប៉ុន្តែនៅតំបន់មួយចំនួន ដូចជាអន្លង់វែងបានបន្តការវាយប្រយុទ្ធរហូតដល់ឆ្នាំ១៩៩៨ ។ ដោយសារតែសង្គ្រាមបានធ្វើប្រជាជនកម្ពុជារួមទាំងយោធាខ្មែរក្រហម បាត់បង់ជីវិត និងត្រូវរស់នៅបែកពីបងប្អូន ឪពុកម្តាយ និងស្រុកកំណើត ក្នុងចំណោមនោះក៏មាន កាន់ ស្មី ម្នាក់ដែរ ។

កាន់ ស្មី មានអាយុ៦៣ឆ្នាំ មានស្រុកកំណើតនៅស្រុកស្នួល ខេត្តក្រចេះ ។ គាត់មានបងប្អូន៥ នាក់ ស្រី៣នាក់ ប្រុសពីរនាក់ ។ នៅក្នុងឆ្នាំ១៩៧២ ពេលមានអាយុ១៨ឆ្នាំ ស្មី បានស្ម័គ្រចិត្តចូលយោធា ដោយសារតែទឹកចិត្តស្នេហាជាតិមាតុភូមិ តែពុំមានការគាំទ្រពីគ្រួសាររបស់គាត់ឡើយ ។ នៅពេល ស្មី ចូលបម្រើកងទ័ព គាត់ត្រូវរស់នៅបែកពីគ្រួសារ ។ ស្មី បានឈរជើងនៅសមរភូមិ ក្នុងស្រុកស្នួល ខេត្តក្រចេះ ។

នៅអង្គភាពកងទ័ព គាត់បានជួបការលំបាកជាច្រើន ហើយត្រូវប្រយុទ្ធនៅក្នុងសមរភូមិទៀត ។ គាត់ត្រូវអនុវត្តតាមវិន័យរបស់កងទ័ពរួមមាន ៖ ១) បម្រើការពារជាតិមាតុភូមិ និងបម្រើប្រជាជន ២) មិនធ្វើអ្វីដែលប៉ះពាល់ដល់ប្រជាជន ៣) ថែទាំសុខភាព ៤) មិនលួចទ្រព្យសម្បត្តិប្រជាជន ៥) មិនផឹកស្រា ៦) បើធ្វើអ្វីដែលប៉ះពាល់ដល់ប្រជាជនត្រូវសុំទោស ៧) មិនក្បត់ជាតិ និង ៨) ជួយបម្រើការងារប្រជាជន ។

មកដល់ឆ្នាំ១៩៧៥ ពេលខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញ ក្នុងខេត្តក្រចេះ ខ្មែរក្រហមបានស្រង់ឈ្មោះកងទ័ពណាដែលមានឪពុកម្តាយជាអតីតទាហាន លន់ នល់ ឲ្យមកធ្វើជាកសិករធម្មតាវិញ ។ ក្នុងចំណោមយោធាដែលត្រូវដកនោះ ក៏មាន ស្មី ដែរ ទោះការចូលបម្រើបដិវត្តន៍ពុំទទួលប្រាក់បៀវត្សរ៍ និងការឧបត្ថម្ភក៏ដោយ ។

ស្មី ត្រូវអង្គការជ្រើសរើសឲ្យធ្វើជាអ្នកគ្រប់គ្រងកងចល័តនារី ។ គាត់មានទំនាក់ទំនងល្អជាមួយប្រជាជននៅក្នុងសហករណ៍ ដោយអនុវត្តតាមផែនការដែលអង្គការដាក់ឲ្យគ្រប់ចំនួន ចំណែករបបអាហារ ប្រជាជនបានហូបចុកគ្រប់គ្រាន់ គឺបីពេលក្នុងមួយថ្ងៃ តែអាហារទាំងនេះអាស្រ័យទៅលើចុងភៅ ។ ទោះយ៉ាងណា ប្រជាជនក៏ត្រូវធ្វើការងារទាំងយប់ទាំងថ្ងៃដែរ ព្រោះវាជាបទបញ្ជាដើម្បីអភិវឌ្ឍភូមិ និងសហករណ៍របស់ខ្លួន ។ ចំពោះច្បាប់នៅពេលនោះ គឺហាមមិនឲ្យប៉ះពាល់នារី ហើយប្រសិនបើអ្នកណាម្នាក់ប្រព្រឹត្តខុស អង្គការនឹងហៅទៅកសាង ឬណែនាំ ប៉ុន្តែបើនៅតែធ្វើខុស អង្គការនឹងដាក់ទណ្ឌកម្មធ្ងន់ជាងនេះ ហើយតំបន់ខ្លះអាចយកទៅសម្លាប់ទៀតផង ។ ស្មី បានលើកឡើងថា តំបន់គាត់គ្រប់គ្រងគ្មានការកាប់សម្លាប់មនុស្សទេ តែមានស្លាប់ដោយសារជំងឺ ។

រហូតដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានជម្លៀស ស្មី ចេញពីខេត្តក្រចេះឲ្យមករស់នៅតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។ ស្មី បានមករស់នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក និងបានជួប តាម៉ុក ស្ទើររាល់ថ្ងៃ ។ កាលពីដំបូង ស្មី មានការលំបាកខ្លាំងដោយសារមានការផ្លាស់ប្តូរទីលំនៅច្រើនកន្លែង ។ ស្មី បានរៀបរាប់អំពី តាម៉ុក ថា ជាកសិករចូលចិត្តនិយាយត្រង់ និងចែករំលែកការហូបចុក ។ តាម៉ុក មានទំនាក់ទំនងល្អជាមួយប្រជាជន ហើយគាត់មិនកាប់សម្លាប់ និងឃុំឃាំងមនុស្សនោះទេ ដោយ ស្មី អះអាងថា ចំពោះបន្ទប់ងងឹតនៅផ្ទះតាម៉ុក មិនមែនជាគុកនោះទេ គឺជាកន្លែងដែលដាក់អាវុធ និងគ្រឿងឧបភោគបរិភោគតែប៉ុណ្ណោះ ចំណែកទ្រុងដែកនៅខាងក្រៅគឺទ្រុងសម្រាប់ដាក់ឆ្កែរបស់គាត់ ។ តាម៉ុក ជេរស្តីឲ្យកូនចៅនៅពេលដែលកូនចៅរបស់គាត់ខ្ជិលជាការធម្មតា ប៉ុន្តែគាត់ស្រឡាញ់កូនចៅណាស់ ។ តាម៉ុក បានការពារព្រៃឈើ និងកសាងហេដ្ឋារចនាសម្ព័ន្ធ តែមិនមែនធំដំនោះទេព្រោះស្ថិតក្នុងសម័យសង្គ្រាម ។

រាល់ការសាងសង់ដូចជាស្ពាន តាម៉ុក មិនបានធ្វើបាបប្រជាជនទេ គឺគាត់គ្រាន់តែឲ្យប្រជាជនជួយរើសដំថ្ម ឬឧបករណ៍ដែល




ស្ពានអូរជីក បានកសាងឡើងដោយ តាម៉ុក ក្នុងអំឡុងពេលតស៊ូប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជា នៅទសវត្សរ៍ឆ្នាំ៩០ ។ តាម៉ុក កសាងស្ពាននេះឡើងដើម្បីជួយសម្រួលដល់ការឆ្លងកាត់របស់ប្រជាជន កងទ័ព និងរថយន្តដឹកសម្ភារ គ្រាប់រំសេវ និង ស្បៀង ទៅសមរភូមិ

ត្រូវប្រើយកទៅដាក់ក្នុងឃ្លាំងជិតផ្សារ តែការងារស៊ើរតែទាំងអស់ គាត់បានជួលជនជាតិថៃមកធ្វើ ។ ពេលមកដល់តំបន់អន្លង់វែងដំបូង មិនមានមនុស្សស្លាប់នោះទេ គឺអ្នកស្លាប់ភាគច្រើនគឺស្លាប់ដោយសារជំងឺ ប៉ុណ្ណោះ ។

ទោះយ៉ាងណា ស្ទី ទទួលស្គាល់ថា ពីមុននៅតាមសហករណ៍នីមួយៗ គឺពិតជាមានការធ្វើបាប ខ្វះអាហារ ធ្វើការលើសដែនការជាដើម ។ តែជាក់ស្តែង នៅពេលគាត់បានជួប ខៀវ សំផន និង ប៉ុល ពត អ្នកទាំងពីរមិនបញ្ជាឲ្យធ្វើដូច្នេះទេ ហើយក៏មិនបានបង្គាប់ឲ្យសម្លាប់ដែរ គឺអ្នកដែលគ្រប់គ្រងនៅសហករណ៍ជាអ្នកបញ្ជា ។

រហូតដល់ឆ្នាំ១៩៨៥ ស្ទី បានចូលធ្វើពេទ្យទាហាន ហើយ លែងរស់នៅជាសហករណ៍ដូចកាលពីមុនទៀតដែរ តែពេលខ្លះតម្រូវឲ្យគាត់ទាំងពីរនាក់ប្តីប្រពន្ធរស់នៅដាច់ដោយឡែកពីគ្នា គឺប្រពន្ធនៅលើភ្នំ ចំណែកគាត់ចុះធ្វើការនៅខាងក្រោម ។

ពេលបំពេញការងារ ស្ទី នៅតែមានទំនាក់ទំនងល្អជាមួយប្រជាជនក៏ដូចជាយោធាដែរ ។ ស្ទី បានចុះតាមមូលដ្ឋានដើម្បីចែកថ្នាំដល់ប្រជាជន ។ គាត់បានបញ្ជាក់ថា ថ្នាំដែលចែកជូនប្រជាជនក្នុងមូលដ្ឋានជាជំនួយរបស់ចិន ហើយគាត់សង្កេតឃើញថា ទាំងកងទ័ពនិងប្រជាជនភាគច្រើនមានជំងឺគ្រុនចាញ់ ។

ស្ទី បានបន្ថែមថា ប្រជាជនដែលរស់នៅតំបន់អន្លង់វែងជំនាន់តាម៉ុក ភាគច្រើនប្រកបរបរកសិកម្ម និងចិញ្ចឹមសត្វ ដើម្បីផ្គត់ផ្គង់ខ្លួនឯង ប៉ុន្តែក៏មានជំនួយពីរដ្ឋដែរ ដូចជា ត្រីខកំប៉ុង ។ គាត់បានបន្តទៀតថា នៅសម័យនោះ មិនមានអ្នកណាជិះជាន់អ្នកណាទេ គឺប្រជាជនរស់នៅស្មើភាពគ្នា និងមានជីវភាពសមរម្យ ។ រហូតដល់ខ្មែរក្រហមធ្វើសមាហរណកម្មឆ្នាំ១៩៩៨ គាត់មានតំណែងនៅក្នុងរាជរដ្ឋាភិបាលដដែល ដោយរក្សាងារជាពេទ្យទាហាន ប៉ុន្តែគាត់បានចូលនិវត្តន៍២ឆ្នាំហើយមកដល់សព្វថ្ងៃ ។

បច្ចុប្បន្ន គាត់មិនមានគំនិតចង់ទៅរស់នៅស្រុកកំណើតនោះទេ ដោយសារគាត់មានប្រពន្ធកូននៅអន្លង់វែងហើយ ចំណែកឯនៅស្រុកកំណើតក៏គាត់មិនមានដីធ្លីសម្រាប់ធ្វើស្រែចម្ការដែរ ។ គាត់ក៏បានបែកបាក់ពីក្រុមគ្រួសារ បងប្អូន សាច់ញាតិ និងជួបការលំបាកច្រើនមកហើយដែរ ។

ស្ទី បានលើកឡើងថា គ្រប់កម្មាភិបាលទាំងអស់ពុំមែនសុទ្ធតែអាក្រក់នោះទេ គឺមានអ្នកល្អខ្លះដែរ គាត់បន្តថា នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ទាំងប្រជាជន ទាំងយោធាខ្មែរក្រហមបានជួបការលំបាកវេទនា ការព្រាត់ប្រាស់គ្រួសារ មនុស្សជាទីស្រលាញ់បាត់បង់ឪពុកម្តាយដូចគ្នា ។ គាត់ចង់ឲ្យក្មេងៗជំនាន់ក្រោយយល់ការលំបាក ការតស៊ូ ដើម្បីជៀសវាងនូវកំហុសឆ្គងច្រំដែលៗចំពោះប្រវត្តិសាស្ត្រ ។ **អ៊ំ ស៊ីណាន**

# ខ្វាក់ភ្នែកទាំងគូប្រសើរជាងឃើញការសម្លាប់មនុស្សនឹងភ្នែក


ម៉ុក គឹមឡាយ

ម៉ុក គឹមឡាយ មានស្រុកកំណើតនៅភូមិដូនលាវ ឃុំប្រាសាទ អណ្តែត បច្ចុប្បន្នឃុំចន្ទស ស្រុកសូត្រនិគម ខេត្តសៀមរាប ។ គឹមឡាយ ជាកូនដែលកើតក្នុងគ្រួសារកសិករ និងមានបងប្អូនប្រុសស្រី ៩នាក់ ។ គាត់បានរៀនសូត្រត្រឹមថ្នាក់ទី៧ (សង្គមចាស់) អាចសរសេរ និងអានបាន ។

ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ភូមិស្រុកដែល គឹមឡាយ រស់នៅត្រូវបានខ្មែរក្រហមគ្រប់គ្រង ។ ខ្មែរក្រហមបានប្រមូលយុវជនយុវនារីក្នុងភូមិឲ្យចូលធ្វើទ័ព ប៉ុន្តែដោយសារតែគឹមឡាយ ចេះអក្សរខ្លះ ខ្មែរក្រហមបានចាត់គាត់ឲ្យបង្រៀនក្មេងៗនៅក្នុងភូមិ ។ គាត់បានបង្រៀនអស់រយៈពេលជាងមួយឆ្នាំ ទើបខ្មែរក្រហមចាត់គាត់ឲ្យធ្វើជាឈ្លបភូមិ និងជាអ្នកដឹកជញ្ជូនស្បៀងឲ្យកងទ័ពនៅសមរភូមិវិញ ។

ក្រោយជ័យជម្នះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការបានផ្លាស់គាត់ឲ្យទៅឈរជើងការពារនៅខេត្តរតនគិរី ។ គឹមឡាយ បានឲ្យដឹងថា កងទ័ពដែលឈរជើងនៅព្រំដែនជួរមុខគឺរបបអាហារមានហូបចុកគ្រប់គ្រាន់ ហើយចំណែកកងទ័ពនៅជួរក្រោយ មិនមានគ្រប់គ្រាន់ទេ គឺមានអីហូបហ្នឹង បើខ្វះខាត ត្រូវចេញទៅរកបន្ថែមខ្លួនឯងដូចជាបរបាញ់ជាដើម ។

នៅអំឡុងឆ្នាំ១៩៧៧ គឹមឡាយ ត្រូវបានអង្គការផ្លាស់ពីកងទ័ពឲ្យមកជួយការងារខាងពេទ្យវិញ ។ ទន្ទឹមនឹងនោះ គាត់បានឲ្យដឹងថា មេទ័ពមួយចំនួនត្រូវបានអង្គការហៅមកភ្នំពេញ ហើយក៏មិនដែលបានឮដំណឹងពីអ្នកទាំងនោះដែរ ។ មិនត្រឹមតែមានការកោះហៅមេៗប៉ុណ្ណោះទេ សូម្បីតែសមាជិកក្នុងកង ក៏មានការបាត់ខ្លួនជាបន្តបន្ទាប់ដែរ ។ គឹមឡាយ បន្តប្រាប់ខ្ញុំដោយលាយឡំនឹងសំណើចថា «ពិតជាសំណាងហើយ ដែលអង្គការផ្លាស់ឲ្យមកធ្វើការខាងពេទ្យ បើមិនអ៊ីចឹងខ្ញុំក៏ជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលបាត់ខ្លួនទាំងនោះដែរ» ។

នៅចុងឆ្នាំ១៩៧៨ នៅពេលកំពុងព្យាបាលអ្នករបួស គ្រាប់ផ្លោងមួយគ្រាប់បានធ្លាក់ចំកន្លែង គឹមឡាយ ធ្វើការ ។ គាត់បានត្រូវរបួសធ្ងន់ និងបញ្ជូនមកព្យាបាលនៅភ្នំពេញ ។ បីខែក្រោយ បន្ទាប់ពីគាត់បានធូរស្រាលបន្តិច ក៏ត្រឡប់មកខេត្តរតនគិរីវិញ ។ មកដល់មិនបានប៉ុន្មានផង កងទ័ពវៀតណាម ក៏វាយចូលមកដល់ គឹមឡាយ និងសមាជិក១០នាក់ផ្សេងទៀត បានរត់គេចខ្លួនចូលព្រៃ ។ គឹមឡាយ នៅក្នុងព្រៃរហូតដល់ឆ្នាំ១៩៨០ ទើបធ្វើដំណើរមកដល់អន្លង់វែង ។

នៅឆ្នាំដដែល គាត់បានរៀបការ និងមានកូនពីរនាក់ ។ ជារឿងអកុសល គាត់បានបាត់បង់ភ្នែកទាំងពីររបស់គាត់ ដោយសារអម្បែងគ្រាប់មីនខ្ទាតត្រូវ ។ គាត់បាននិយាយមកកាន់ខ្ញុំដោយម៉ឺងម៉ាត់ថា «គាត់មិនមានការសោកស្តាយដែលបាត់បង់ភ្នែកមួយគូនេះទេ ព្រោះវាបានឃើញការស្លាប់របស់មនុស្សជាច្រើន ហើយក៏អាចចាត់ទុកជាសំណាងរបស់ខ្ញុំហើយ ដែលនៅមានជីវិតរស់» ។

ដោយសារតែជីវភាពរបស់ គឹមឡាយ មានការខ្វះខាត ហេតុនេះ កូនៗរបស់គាត់មិនបានរៀនសូត្រទេ ។ គ្រួសាររបស់គាត់ប្រកបរបរធ្វើស្រែចម្ការ ។ ទោះជាយ៉ាងណាក៏ដោយ គឹមឡាយ នៅតែមានចិត្តរីករាយដោយសារប្រទេសមានសន្តិភាព ។ ទោះបីជាជីវភាពគាត់មានការលំបាក តែគាត់អាចរស់នៅជួបជុំគ្រួសារ និងរស់នៅដោយសុខសាន្ត គ្មានភាពភ័យខ្លាចដូចមុនឡើយ ។

**ពេញ សុចណ្ណារី**

# ធ្លាក់ខ្លួនពិការដោយសារមីន

ទីត វែក បានចំណាយពេលស្ទើរពេញមួយជីវិតរបស់ខ្លួនក្នុងសង្គ្រាម ។ គាត់បានឆ្លងកាត់ និងប្រយុទ្ធនៅសមរភូមិជាច្រើន រហូតដល់ធ្លាក់ខ្លួនពិការជើងម្ខាងដោយសារជាន់មីននៅអំឡុងពេលប្រយុទ្ធជាមួយកងទ័ពវៀតណាម ។



ទីត វែក អតីតយោធាខ្មែរក្រហម ដែលបានចូលរួមប្រយុទ្ធជាច្រើនសមរភូមិ ។ វែក បាត់បង់ជើងស្តាំក្នុងអំឡុងពេលប្រយុទ្ធលើសមរភូមិចុងក្រោយ ព្រៃស្អាក ។

វែក ជាក្មេងដែលកើតក្នុងគ្រួកូលកសិករ មានបងប្អូនប្រុសស្រី៥នាក់រស់នៅស្រុកស្ទោង ខេត្តកំពង់ធំ ។ ដោយសារតែគ្រួសារជាកសិករមានជីវភាពលំបាករកព្រឹកខ្វះល្ងាច វែក មិនបានរៀនសូត្រនោះទេ ។ វែក បានជួយធ្វើស្រែឪពុកម្តាយរហូតដល់ឆ្នាំ១៩៦៦ ទើបគាត់បានទៅបួសជាសង្ឃនៅវត្តមួយ ក្នុងខេត្តកំពង់ធំ ។ បួសរៀនបានបីវស្សា នៅឆ្នាំ១៩៧២ វែក បានសឹកវិញដោយសារតែពេលនោះប្រទេសកំពុងតែវឹកវរ ។ ស្ថិតក្នុងវ័យ១៩ វែក បានស្ម័គ្រចិត្តចូលធ្វើយោធាក្នុងចលនាតស៊ូរបស់ខ្មែរក្រហម ។

បន្ទាប់ពីចូលធ្វើយោធា វែក បានចូលរួមប្រយុទ្ធជាមួយនឹងកងទ័ពសាធារណរដ្ឋលន់ នល់ ជាច្រើនលើក ។ វែក បានប្រយុទ្ធនៅសមរភូមិកំពង់ធំពីរឆ្នាំ បន្ទាប់មកគាត់បានផ្លាស់ទៅសមរភូមិកំពង់ឆ្នាំង និងកំពង់ចាម ។ បន្ទាប់ពីថ្ងៃជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៥ វែក ត្រូវបានអង្គការផ្លាស់ទៅឈរជើងការពារនៅខេត្តមណ្ឌលគីរី រហូតដល់របបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ ។ ទោះបីជារបបខ្មែរក្រហមដួលរលំក៏ដោយ ក៏ វែក នៅតែបន្តរស់នៅមណ្ឌលគីរី និងបានរៀបការនៅឆ្នាំ១៩៨២ ។ នៅឆ្នាំ១៩៩១ វែក និងគ្រួសារបានចាកចេញពីមណ្ឌលគីរី មកស្រុកអន្លង់វែង ហើយមានទាទីជាយោធាដដែល ។ នៅមុនពេលធ្វើសមាហរណកម្មឆ្នាំ១៩៩៨ វែក បានមកឈរជើងនៅម្តុំព្រៃស្អាក និងបានធ្វើការប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាម រហូតបាត់បង់ជើងម្ខាង ដោយសារតែជាន់មីន ។ បន្ទាប់ពីធ្លាក់ខ្លួនពិការ វែក ត្រូវបានថ្នាក់លើឲ្យមកសម្រាកនៅផ្ទះជួបជុំប្រពន្ធកូននៅអន្លង់វែង រហូតដល់ពេលយោធាក្នុងតំបន់អន្លង់វែងនេះ ធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ។

សព្វថ្ងៃ វែក គឺជាយោធិនចូលនិវត្តន៍ និងប្រកបរបរជាកសិករ ។ វែក មានប្រពន្ធ និងកូនប្រុសស្រីបួននាក់ ។

វែក បានឲ្យដឹងថា ក្រោយសង្គ្រាមបានបញ្ចប់ មិនបានផ្តល់ផលល្អសម្រាប់គាត់នោះទេ ក្រៅពីធ្វើឲ្យគាត់បែកបាក់ក្រុមគ្រួសារ និងធ្លាក់ខ្លួនពិការ ។

**រដ្ឋ សុផល**

# សន្តិភាព ក្រោយបញ្ចប់សង្គ្រាម

ក្រោយរបបខ្មែរក្រហមបានបញ្ចប់ ប្រជាជនម្នាក់ៗ រាប់ទាំងអតីតកម្មាភិបាលខ្មែរក្រហមផង បានធ្វើដំណើរត្រឡប់ទៅភូមិកំណើត ដើម្បីស្វែងរក និងជួបជុំគ្រួសារវិញ ។ ក្នុងនោះដែរ ក៏មានអតីតខ្មែរក្រហមមួយចំនួនបាប សម្រេចចិត្តមិនត្រឡប់ទៅស្រុកកំណើតវិញ ក៏ព្រោះតែអតីតភាពរបស់ខ្លួន ។

ជាក់ស្តែង អ៊ុំស្រី មឿង ម៉ៃ មានស្រុកកំណើតនៅស្រុកសម្បូរ ខេត្តក្រចេះ សម្រេចចិត្តមិនវិលត្រឡប់ទៅស្រុកកំណើតវិញទេ ដោយបន្តរស់នៅស្រុកអន្លង់វែងរហូតដល់បច្ចុប្បន្ន ។ ម៉ៃ មិនត្រឡប់ទៅវិញ ដោយខ្លាចពីអតីតភាពរបស់គាត់ដែលជាខ្មែរក្រហម ខ្លាចអ្នករស់នៅសហគមន៍មានការរើសអើងចំពោះគាត់ ។ គាត់បានរៀបរាប់ប្រាប់ពីអតីតកាលរបស់គាត់ មកកាន់ខ្ញុំទាំងទឹកមុខក្រៀមក្រំថា មុនរបបខ្មែរក្រហម គាត់ជាក្មេងម្នាក់ដែលមានឪពុកម្តាយជាកសិករនៅស្រុកសម្បូរ ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ ខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិស្រុកដែលគាត់រស់នៅ ។ ខ្មែរក្រហមបានកេណ្ឌយុវជន យុវនារី ឲ្យចូលធ្វើទ័ព ។ ម៉ៃ បានរួចផុតពីការកេណ្ឌទ័ព ដោយសារតែគាត់មានអាយុទើបជាង១០ឆ្នាំ ។

នៅឆ្នាំ១៩៧៤ ម៉ៃ មានអាយុ១៦ សមល្មមនឹងទៅធ្វើទ័ព បានហេតុនេះ ខ្មែរក្រហមបានចាត់គាត់ឲ្យចូលធ្វើនៅកងចល័តនារី ។ ឈោងយកក្រមាមកជូតមុខរួចបន្តប្រាប់ខ្ញុំថា ការដែលគាត់ចូលរួមចលនាបដិវត្តន៍នេះ មិនបានស្ម័គ្រចិត្តចូលទេ គឺដោយសារខ្លាចការគំរាមរបស់ខ្មែរក្រហមតែប៉ុណ្ណោះ ។ ខ្មែរក្រហមបានគំរាមថា បើមិនចូលរួមតាមការស្នើនេះទេ ខ្មែរក្រហមនឹងសម្លាប់គាត់ និងគ្រួសារមិនខាន ។

ក្រោយជ័យជម្នះទូទាំងប្រទេសរបស់ខ្មែរក្រហមថ្ងៃ១៧ មេសា ១៩៧៥ និងបន្ទាប់ពីចូលធ្វើជាកងចល័តនារី ម៉ៃ ត្រូវផ្លាស់



អតីតផ្ទះរបស់ តាម៉ុក បច្ចុប្បន្នត្រូវបានប្រែក្លាយទៅជាសារមន្ទីរសម្រាប់ភ្ញៀវចូលមកទស្សនា និងសិស្ស-និស្សិតមកសិក្សាស្រាវជ្រាវ



ផ្នូររបស់ ប៉ុល ពត នៅលើភ្នំដងរែក

ប្តូរពីកន្លែងមួយទៅកន្លែងមួយ ។ ដោយមានវ័យក្មេងពេក គាត់មិនចាំថា ធ្វើការនៅកន្លែងណាខ្លះ ឬស្រុកណាឡើយ ។ ការងារដែល ម៉ៃ ធ្វើនៅពេលនោះ គឺ លើកទំនប់ ជីកប្រឡាយ និងធ្វើស្រែចម្ការ ។ គាត់បានបញ្ជាក់ថា ការងារធ្វើច្រើនណាស់ តែរបបដែលទទួលបានមិនគ្រប់គ្រាន់ឡើយ ។ របបដែលទទួលបានមានតែបបររាវៗ ឬពេលខ្លះដាំលាយនឹងពោតទៀតផង ។ កងរបស់ ម៉ៃ ត្រូវធ្វើការពីម៉ោង៧ព្រឹកដល់ម៉ោង១១ ទើបសម្រាក ហើយបន្តពីម៉ោង១រសៀលដល់ម៉ោង៥ល្ងាច ។ ជារៀងរាល់សប្តាហ៍ គឺមានការប្រជុំស៊័យទិះតៀនក្នុងក្រុម ដើម្បីរកភាពខ្វះចន្លោះ និងអប់រំឲ្យអ្នកទាំងអស់គ្នាមានភាពស្មោះត្រង់ គិតប្រយោជន៍សមូហភាពជាធំជាងប្រយោជន៍ផ្ទាល់ខ្លួន ។ ក្រោយមក កងរបស់ ម៉ៃ ត្រូវបានអង្គការផ្លាស់ឲ្យទៅចល័តការពារតាមព្រំដែនវិញ ។ ម៉ៃ បានឲ្យដឹងថា នៅឈរជើងការពារព្រំដែន គឺមិនសូវលំបាកដូចនៅចល័តទេ សម្រាប់ការហូបចុក ព្រោះបានអ្នកគ្រប់គ្រង ជាមនុស្សស្រួល និងគិតសុខទុក្ខកូនចៅ ។

នៅឆ្នាំ១៩៧៩ របបខ្មែរក្រហមបានដួលរលំ ប៉ុន្តែកម្លាំងខ្មែរក្រហមមួយចំនួននៅបន្តប្រយុទ្ធប្រឆាំងជាមួយកងទ័ពរំដោះដែលគាំទ្រដោយវៀតណាមនៅឡើយ ។ ការចរចា និងការប្រយុទ្ធរវាងភាគីទាំងពីរ នៅតែបន្តរហូតដល់ឆ្នាំ១៩៩៨ ទើបបានធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ហើយការប្រយុទ្ធក៏ត្រូវបានបញ្ចប់ដែរ ។

ក្រោយប្រទេសមានសន្តិភាព អតីតខ្មែរក្រហមមួយចំនួនបានចាកចេញពីតំបន់អន្លង់វែងទៅស្រុកកំណើតវិញ ដើម្បីស្វែងរកក្រុមគ្រួសារ ។ ដោយឡែក ម៉ៃ មិនបានត្រឡប់ទៅស្រុកកំណើតវិញទេ ក៏ព្រោះតែខ្លាចការរើសអើងអំពីអតីតភាពជាខ្មែរក្រហមរបស់គាត់ ។ គាត់ក៏សម្រេចចិត្តបន្តរស់នៅអន្លង់វែងរហូតដល់បច្ចុប្បន្ន ។ ទោះបីជាយ៉ាងណា ការរើសអើងចំពោះអតីតខ្មែរក្រហមនៅតែមាន ។ ម៉ៃ បានរម្លឹកថា កាលពីដំបូងអ្នកចំណូលថ្មីដែលមករស់នៅអន្លង់វែងមានការរើសអើងចំពោះអតីតខ្មែរក្រហមណាស់ ដោយអ្នកទាំងនោះរស់នៅជាសហគមន៍ជាមួយអ្នកចំណូលថ្មីដូចគ្នា ហើយក៏មិនសូវទំនាក់ទំនងជាមួយអ្នករស់នៅចាស់ដែរ ។ ប៉ុន្តែបច្ចុប្បន្ន ការរើសអើងទាំងនោះ គឺមិនមានទៀតទេ ប្រជាជនម្នាក់ៗ មិនថាអ្នករស់នៅចាស់ឬថ្មីទេរស់នៅជាមួយគ្នាដោយរីករាយ និងសុខសន្តិភាព ។

ម៉ៃ ពិតជារីករាយនឹងជីវិតរស់នៅបច្ចុប្បន្ននេះណាស់ ព្រោះថាគាត់រស់នៅដោយរីករាយ ស្ងប់ចិត្ត មិនដូចកាលពីជំនាន់សង្គ្រាមដែលរស់នៅដោយភាពភ័យខ្លាចគ្រប់ពេលវេលានៅក្នុងព្រៃ គេចពីគ្រាប់ផ្លោង និងមិនហ៊ានដេកនៅពេលយប់ជាដើម ។

សំណួរចុងក្រោយរបស់ខ្ញុំសួរទៅកាន់ ម៉ៃ "បើមានគេសួរថា តើអ៊ំជាអតីតខ្មែរក្រហមមែនទេ? តើអ៊ំមានអារម្មណ៍យ៉ាងណា? ម៉ៃ ឆ្លើយតបមកខ្ញុំថា "ដំបូងមានការអន់ចិត្តដែរ ប៉ុន្តែក្រោយមកមិនអីទេ ព្រោះវាជាការពិត ហើយជាពិសេស បច្ចុប្បន្នក៏មិនមានការរើសអើងចំពោះអតីតខ្មែរក្រហមទៀតដែរ ។ កូនៗបានចូលរៀនដូចកូនអ្នកដទៃ ហើយអ្នកភូមិក៏មានទំនាក់ទំនងល្អជាមួយគ្នា មិនប្រកាន់អ្នកចាស់ អ្នកចំណូលថ្មី ។ កូនចៅក៏មិនមានការរើសអើងពីមិត្តភក្តិ ឬមជ្ឈដ្ឋានជុំវិញដែរ ។

**លី ឌួចណៃ**

# លើកដំបូងរបស់ខ្ញុំមកដល់ស្រុកអន្លង់វែងៈ អ្វីៗមិនដូចការគិត

កាលពីសប្តាហ៍មុន ខ្ញុំ និងនិស្សិតមួយចំនួនទៀត បានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាមួយទៅកាន់ស្រុកអន្លង់វែង ក្រោមការរៀបចំរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ ខ្ញុំពិតជាចាប់អារម្មណ៍ចំពោះអន្លង់វែង ព្រោះខ្ញុំមិនធ្លាប់បានទៅតំបន់នេះពីមុនមកទេ ។ ខ្ញុំគ្រាន់តែឮតាមចាស់ទុំ ឪពុកម្តាយដំណាលប្រាប់ប៉ុណ្ណោះថា អន្លង់វែងជាតំបន់ដែលមានខ្មែរក្រហមរស់នៅច្រើន ។

ក្នុងដំណើរផ្លូវដ៏វែងឆ្ងាយ យើងទាំងអស់គ្នាបានមកដល់ទីរួមស្រុកអន្លង់វែង ដែលមានមនុស្សម្នាអ៊ូអរ មានផ្សារលក់ដូររបស់របរគ្រប់ប្រភេទ ។ ទិដ្ឋភាពទាំងនេះ គឺផ្ទុយស្រឡះពីអ្វីដែលខ្ញុំបានគិតមុននឹងមកអន្លង់វែង ព្រោះខ្ញុំគិតថា តំបន់នេះ ជាកន្លែងដាច់ស្រយាល និងមិនមានមនុស្សម្នារស់នៅច្រើនទេ ។ យើងបានទៅទស្សនាតំបន់ប្រវត្តិសាស្រ្តមួយចំនួននៅតំបន់អន្លង់វែងដូចជា ផ្នូរប៉ុល ពត កន្លែងកាត់ទោសប៉ុល ពត ផ្ទះតាម៉ុក និងជាពិសេស បានទៅទស្សនាសាលារៀនមួយដែលបានសាងសង់ឡើងកាលពីជំនាន់តាម៉ុក គ្រប់គ្រង ហើយសាលារៀនមួយនេះ នៅបន្តប្រើប្រាស់រហូតមកដល់បច្ចុប្បន្ន ។

លើសពីនេះទៅទៀត ខ្ញុំបានធ្វើដំណើរទៅដល់អតីតទីបញ្ជាការរបស់ តាម៉ុក នៅលើកំពូលភ្នំដងរែក ។ ទីបញ្ជាការនោះ គឺជាផ្ទះថ្មចាស់មួយខ្នងផ្ទាល់ដី ដែលត្រូវបានរៀបចំកែលម្អជាថ្មី និងធ្វើជាការិយាល័យផ្តល់ព័ត៌មានរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ ក្រៅពីការទស្សនាតំបន់ប្រវត្តិសាស្រ្ត យើងជានិស្សិតទាំងអស់ ក៏មានឱកាសចុះធ្វើការសម្ភាសផ្ទាល់ជាមួយអតីតខ្មែរក្រហមកំពុងរស់នៅតំបន់នេះ ។ ការសម្ភាសនេះ ក៏ជាឱកាសឲ្យយើងដែលជាក្មេងជំនាន់ក្រោយ សួរនាំស្វែងយល់ពីបទពិសោធជីវិតរបស់អ្នកទាំងនោះ



ទីរួមស្រុកអន្លង់វែងក្នុងពេលបច្ចុប្បន្ន



កសិករនៅស្រុកអន្លង់វែងកំពុងហាលដំឡូងមី

ដែលធ្លាប់បានឆ្លងកាត់ និងថាតើគាត់ទាំងអស់គ្នាបានជួបប្រទះនូវរឿងរ៉ាវអ្វីខ្លះ? ហើយហេតុអ្វីបានជាគាត់ចូលរួមចលនារបស់ខ្មែរក្រហមនៅពេលនោះ?

ជាលើកដំបូងដែលខ្ញុំបានសម្ភាសផ្ទាល់ជាមួយអតីតខ្មែរក្រហម ហើយមានអារម្មណ៍ភ័យខ្លាចខ្លះ ព្រោះធ្លាប់តែឮឪពុកម្ដាយប្រាប់ថា អន្លង់វែងនេះជាតំបន់របស់ខ្មែរក្រហម ហើយខ្មែរក្រហមគឺ សាហាវ និងគួរឲ្យខ្លាចណាស់ ។ ប៉ុន្តែ ពេលដែលខ្ញុំបានជួបផ្ទាល់គឺមិនដូចអ្វីដែលឪពុកម្ដាយ ឬអ្នកឯទៀតប្រាប់ទាំងស្រុងនោះទេ ។ ខ្ញុំមើលទៅអ្នករស់នៅទីនេះ មានភាពរស់រាយរាក់ទាក់ចំពោះអ្នកដំណើរ ទោះបីជាយើងមិនដែលស្គាល់គ្នាក៏ដោយ ក៏គាត់ទាំងអស់គ្នាតែងតែញញឹមមករកយើងជានិច្ច ។

បន្ទាប់ពីបែងចែកជាក្រុមដើម្បីសម្ភាស ខ្ញុំក៏បានចូលទៅសំណេះសំណាលជាមួយអ៊ំប្រុសម្នាក់ ដែលគាត់កំពុងសម្រាកលើគ្រែក្រោមផ្ទះ ។ ទទួលស្វាគមន៍ខ្ញុំដោយរាក់ទាក់ គាត់ឈ្មោះ ជា ឃឹម ហៅ ម៉ម រ៉េត ហើយប្រពន្ធរបស់គាត់ឈ្មោះ គីម ស៊ី ។ អ្នកទាំងពីររៀបការនៅឆ្នាំ១៩៨៣ និងមានកូនប្រុសស្រីបីនាក់ ។ ឃឹម បានធ្លាក់ខ្លួនពិពិការជើងស្ដាំដោយសារជាន់មីន ក្នុងអំឡុងសង្គ្រាមឆ្នាំ១៩៨៨ រវាងកងទ័ព តាម៉ុក និងកងទ័ពរដ្ឋាភិបាល ។ ឃឹម នៅពេលនោះ គឺមាននាទីធ្វើចម្រូង ។ បន្ទាប់ពីធ្លាក់ខ្លួនពិការថ្នាក់លើបានឲ្យគាត់រស់នៅជាមួយគ្រួសារក្នុងភូមិវិញ ។ គាត់ហាក់ដូចជាពិបាកក្នុងការរៀបរាប់ពីដំណើរជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហមប្រាប់មកកាន់ខ្ញុំ ។ គាត់គ្រាន់តែលើកឡើងថា ទោះបីជាគាត់ជាអតីតមនុស្សម្នាក់ ដែលបានចូលរួមក្នុងចលនាតស៊ូរបស់ខ្មែរក្រហមក៏ដោយ ក៏គាត់នៅតែខឹងនឹងថ្នាក់ដឹកនាំខ្មែរក្រហម ដែលបានធ្វើឲ្យប្រជាជនស្លូតត្រង់ស្លាប់ជាច្រើន ជាពិសេស គាត់ក៏បាត់បង់សមាជិកគ្រួសារក្នុងរបបនោះដែរ ។

ក្រោយសមាហរណកម្ម អន្លង់វែង មានសុខសន្តិភាពពេញលេញ ហើយ ឃឹម និងគ្រួសារ ក៏ឈប់រស់នៅក្នុងភាពភ័យខ្លាចដូចមុនទៀតដែរ ។ ឃឹម ក៏ដូចជាប្រជាជនដទៃទៀត បានចាប់ផ្ដើមជីវិតជាថ្មីនៅលើអតីតទឹកដីដែលជាតំបន់ដែលរស់នៅពោរពេញដោយភាពភ័យខ្លាច ដោយសារសង្គ្រាម ។ ឃឹម មិនចង់ត្រឡប់ទៅស្រុកកំណើត ខេត្តសៀមរាបវិញទេ ព្រោះគិតថា គាត់រស់នៅអន្លង់វែងនេះបានសុខស្រួល ហើយអន្លង់វែងនេះ គឺគាត់មានអនុស្សាវរីយ៍ជាច្រើនសម្រាប់គាត់ និងគ្រួសារ ។ **ស្រេម ស្រីនិច**



# ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង
## តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម

## ប្រវត្តិសាស្ត្រដំបូងនៃតំបន់អន្លង់វែង

តំបន់អន្លង់វែងត្រូវបានបង្កើតឡើងតាំងពីយូរអង្វែងណាស់មកហើយ មុនពេលដែលតំបន់នេះក្លាយទៅជាតំបន់កាន់កាប់ចុងក្រោយដ៏ល្បីល្បាញរបស់ចលនាកុម្មុយនីស្តខ្មែរក្រហម ។ នៅឆ្នាំ១៩០៥ តំបន់អន្លង់វែង ត្រូវបានទទួលស្គាល់ដោយអ្នកគូរផែនទីជនជាតិបារាំង នៅពេលដែលអ្នកគូរផែនទីទាំងនេះកំពុងបង្កើតខ្សែបន្ទាត់ព្រំដែនកម្ពុជាជាមួយនឹងប្រទេសជិតខាងភាគខាងជើង ។ ដូចសហគមន៍ដទៃៗទៀត ដែលត្រូវបានបង្កើតឡើងនៅតាមបណ្តោយព្រំដែនខាងទឹកដីថៃដែរ តំបន់អន្លង់វែងត្រូវបានតាំងទីលំនៅដោយជនជាតិខ្មែរ ដែលបានធ្វើចំណាកស្រុកមកពីភាគខាងត្បូងនៃទឹកដីសៀម ដែលបច្ចុប្បន្នស្ថិតនៅក្នុងខេត្តស៊ីសាកេតប្រទេសថៃ ។

## រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល

តំបន់អន្លង់វែងមានប្រវត្តិផ្លាស់ប្តូរច្រើនដងរវាងការគ្រប់គ្រងដោយកម្ពុជា និងការគ្រប់គ្រងដោយថៃ ។ មុនឆ្នាំ១៨៦៧ អន្លង់វែងស្ថិតនៅក្នុងទឹកដីកម្ពុជា ។ រវាងឆ្នាំ១៨៦៧ និងឆ្នាំ១៩០៧ អន្លង់វែងស្ថិតនៅក្នុងអតីតខេត្តថៃមួយ ដែលមានឈ្មោះសៀមណាខន ។ នៅឆ្នាំ១៨៦៣ ប្រទេសកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំង ។ ដោយមានការដាក់សម្ពាធពីបារាំង សៀមបានប្រគល់ខេត្តបាត់ដំបង និងសៀមរាបមកឲ្យកម្ពុជាវិញនៅឆ្នាំ១៩០៧ ។

នៅឆ្នាំ១៩៤១ តំបន់អន្លង់វែងនេះបានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ថៃជាថ្មីម្តងទៀត បន្ទាប់ពីមានជម្លោះមួយរយៈពេលខ្លីរវាងថៃ និងបារាំង ។ នៅចន្លោះឆ្នាំ១៩៤១ និងឆ្នាំ១៩៤៦ អន្លង់វែងត្រូវបានបញ្ចូលទៅក្នុងខេត្តរបស់ថៃ ដែលមានឈ្មោះថា ប្លែកភីប៊ុនសង់ក្រាម ដែលជាឈ្មោះរបស់អតីតនាយករដ្ឋមន្ត្រីថៃនាពេលនោះ ។ នៅក្នុងដំណាក់កាលនេះ ថៃបានគ្រប់គ្រងខេត្តសៀមរាប និងខេត្តបាត់ដំបងរបស់ខ្មែររហូតដល់ឆ្នាំ១៩៤៦ នៅពេលដែលបារាំង និងថៃចុះកិច្ចព្រមព្រៀងលើសន្ធិសញ្ញាព្រំដែន ដែលបានប្រគល់ខេត្តទាំងពីរមកឲ្យកម្ពុជាវិញ ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ខេត្តឧត្តរមានជ័យត្រូវបានបង្កើតឡើង ដោយកាត់ចេញពីខេត្តសៀមរាប ។ ទោះជាយ៉ាងនេះក្តី ក្រោយឆ្នាំ១៩៧០ តំបន់អន្លង់វែងក្លាយទៅជា«ដែនដីមួយដែលមិនមានរដ្ឋបាលគ្រប់គ្រងដែលនៅឆ្លាស់គ្នាក្រោមខេត្ត ឬជាស្រុកទៅតាមរបបដឹកនាំក្រោយៗមកទៀត ។ នៅឆ្នាំ១៩៩៩ ខេត្តឧត្តរមានជ័យ ត្រូវបានបង្កើតឡើងវិញ ហើយតំបន់អន្លង់វែងដែលធ្លាប់ជាភូមិមួយបានក្លាយទៅជាស្រុកមួយដែលស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ រហូតដល់សព្វថ្ងៃ ។

## តំបន់អន្លង់វែង និងតំបន់ជុំវិញនៅមុនឆ្នាំ១៩៨០

ស្ថិតនៅចម្ងាយប្រមាណ១២៥គីឡូម៉ែត្រ ពីទីរួមខេត្តសៀមរាប និងចម្ងាយប្រហែល១២គីឡូម៉ែត្រពីជួរភ្នំដងរែក អន្លង់វែងមានប្រវត្តិជាតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ។ នៅក្នុងរជ្ជកាលព្រះបាទ សម្តេចព្រះ នរោត្តម (១៨៦០-១៩០៤) និងនៅក្នុងស្ទើរមួយរយៈកាលនៃរបបអាណានិគមនិយមបារាំង (១៨៦៣-១៩៥៣) រដ្ឋបាលរបស់ប្រទេសកម្ពុជាមិនសូវមានការយកចិត្តទុកដាក់ទៅលើតំបន់ជនបទ ហើយរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនេះ ស្ទើរតែគ្មានវត្តមាននៅតាមតំបន់ដាច់ស្រយាលទាំងឡាយនៃព្រះរាជាណាចក្រ ។

ដោយសារតែមានការខ្វះខាតផ្លូវថ្នល់ ប្រព័ន្ធទំនាក់ទំនង និងហេដ្ឋារចនាសម្ព័ន្ធតំបន់អន្លង់វែងមិនទទួលឥទ្ធិពលពីរដ្ឋាភិបាលសៀម និងរដ្ឋាភិបាលកម្ពុជាទេ ។ ជាងនេះទៅទៀត ស្ថានភាពនៅតំបន់អន្លង់វែង ហាក់មិនមានការប្រែប្រួលទេ ទោះបីជាបារាំងបានចូលមកគ្រប់គ្រងប្រទេសកម្ពុជាក៏ដោយ ។

នៅក្នុងរយៈកាលដ៏រុងរឿងនៃអារ្យធម៌អង្គរ អាណាចក្រខ្មែរលាតសន្ធឹងទៅភាគខាងជើងរហូតដល់ប្រទេសចិន ដែលរាប់បញ្ចូលស្ទើរតែទាំងអស់នៃទឹកដីថៃនាពេលបច្ចុប្បន្ននេះ ។ ប៉ុន្តែដោយសារមូលហេតុមួយចំនួន ដែលនៅតែជាប្រធានបទនៃការជជែកដេញដោលគ្នារហូតមកដល់សព្វថ្ងៃនេះ អាណាចក្រអង្គរបានធ្លាក់ចុះយ៉ាងលឿននៅសតវត្សរ៍ទី១៤ នៅពេលដែលប្រទេសជិតខាងកម្ពុជាបានបង្កើនអំណាចរបស់ខ្លួនឡើងជាលំដាប់ ។ រហូតមកដល់សតវត្សរ៍ទី១៨ ដោយសារតែសង្គ្រាម ភាពចលាចលនៅក្នុងសង្គម និងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចកម្ពុជាធ្លាក់ចូលទៅក្នុងភាពទន់ខ្សោយ ដែលងាយនឹងទទួលរងការឆក់ប្លន់ និងការបាត់បង់ទឹកដី ទៅអ្នកជិតខាងដ៏មានអំណាចរបស់ខ្លួន គឺប្រទេសអាណាម និងសៀម (ដែលជាប្រទេសវៀតណាម និងប្រទេសថៃនាពេលបច្ចុប្បន្ន) ។ ដោយបាត់បង់អធិបតេយ្យភាពទៅប្រទេសជិតខាង ព្រះបាទសម្តេចព្រះអង្គឌួង

(១៨៤១-១៨៦០) បានស្វែងរកការការពារពីបារាំង ដែលនៅទីបំផុត បង្កើតបាននូវសន្ធិសញ្ញាឆ្នាំ១៨៦៣ រវាងព្រះរាជបុត្ររបស់ព្រះអង្គ គឺព្រះបាទ នរោត្តម និងបារាំង ។

សន្ធិសញ្ញាឆ្នាំ១៨៦៣ បានបង្កើតអាណាព្យាបាលបារាំងមកលើប្រទេសកម្ពុជា ដែលសន្ធិសញ្ញានេះបានផ្តល់សិទ្ធិដល់បារាំងក្នុងការគ្រប់គ្រងទៅលើផ្នែកពាណិជ្ជកម្មដែនដី និងសាសនា ។ ចំណែកឯព្រះបាទ នរោត្តម នៅបន្តដឹកនាំកិច្ចការនយោបាយ និងរដ្ឋបាលផ្ទៃក្នុង ។ ក្រោយៗមកទៀត ជាពិសេសបន្ទាប់ពីឆ្នាំ១៨៨៤ កិច្ចការទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរបារាំង ។

ស្ថាប័នសង្គម និងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចរបស់កម្ពុជា ហាក់មានការផ្លាស់ប្តូរតិចតួចណាស់ នៅចន្លោះឆ្នាំ១៨៦៣ ដល់ចុងសតវត្សរ៍ទី១៩ ។ ដោយផ្ទុយគ្នាទៅនឹងរបៀបដែនជីវិតរបស់រាជវង្សានុវង្ស និងក្រុមគ្រួសារអភិជនប្រជាជនកម្ពុជាភាគច្រើនមានកម្មសិទ្ធិតិចតួចណាស់ក្រៅពីសម្លៀកបំពាក់សម្ភារផ្ទះបាយនិងសម្ភារធ្វើស្រែចម្ការ ។ "ប្រជាជនទាំងនោះរស់នៅតាមទម្លាប់ដែលដូនតារបស់ខ្លួនបានអនុវត្តអស់រយៈពេលជាច្រើនពាន់ឆ្នាំ នៅក្នុងផ្ទះខ្ទមប្រក់ស្លឹកត្នោតសង់ខ្ពស់ផុតពីដី ដើម្បីឲ្យមានខ្យល់ចេញចូល និងការពារពីទឹកជំនន់សត្វពស់ និងសត្វល្អិតផ្សេងៗ ។" ព្រះពុទ្ធសាសនាគឺជាមូលដ្ឋានគ្រឹះនៃជីវិតរបស់អ្នកភូមិ ដែលបានផ្សារភ្ជាប់ទំនាក់ទំនងក្នុងចំណោមអ្នករស់នៅក្បែរខាងគ្នា ក៏ដូចជាសហគមន៍ទាំងមូល ។ ការដោះដូរផ្នែកសេដ្ឋកិច្ច និងសង្គមត្រូវបានកំណត់ដោយលក្ខខណ្ឌភូមិសាស្ត្រមិនអំណោយផល ហើយនៅតំបន់ដាច់ស្រយាលដូចជាតំបន់អន្លង់វែងភូមិទាំងឡាយហាក់ដូចជាកោះនៅក្នុងសមុទ្រព្រៃដ៏ក្រាស់ ។ យើងអាចស្រមៃឃើញថា មន្ត្រីបារាំងដែលបានធ្វើដំណើរស្វែងយល់តាមបណ្តោយព្រំដែនកម្ពុជា-សៀម នៅឆ្នាំ១៩០៥ ប្រហែលជាបានប្រទះឃើញស្ថានភាពប្រហាក់ប្រហែលគ្នានេះ ។ ដូចដែលប្រវត្តិវិទូមួយរូបបានលើកឡើង "ទោះបីជាពីរដ្ឋកាលមួយទៅរដ្ឋកាលមួយមានការធ្លាក់ចុះ ស្ថានភាពនៅតាមភូមិស្រុកនៅតែដដែល ។"

តំបន់អន្លង់វែងហាក់ដូចជាមិនមានការប្រែប្រួលច្រើនទេ ទោះបីជាតំបន់នេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរ ឬសៀម ។ សៀមហាក់ដូចជាមិនជំទាស់ក្នុងការអនុញ្ញាតឲ្យប្រជាជនខ្មែរបន្តប្រតិបត្តិទំនៀមទម្លាប់ចាស់របស់ខ្លួន នៅក្នុងខេត្តទាំងឡាយដែលសៀមបានកាត់យក ។ សម្រាប់តំបន់ដាច់ស្រយាល ដូចជាអន្លង់វែង និងតំបន់ដែលស្ថិតនៅភាគខាងជើងជួរភ្នំដងរែកក្នុងទឹកដីសៀម ប្រជាជនខ្មែរនៅតែបន្តអនុវត្តរបស់ខ្លួន ដូចដែលខ្លួនធ្លាប់បានអនុវត្តអស់ជាច្រើនសតវត្សរ៍កន្លងមក ។ ជនជាតិថៃម្នាក់ដែលធ្លាប់រស់នៅអន្លង់វែងក្នុងទសវត្សរ៍ឆ្នាំ១៩៥០ បានរៀបរាប់ថា ភាសាខ្មែរគឺជាភាសាដែលប្រជាជនភាគច្រើននិយាយទាំងនៅលើទឹកដីថៃ និងទឹកដីខ្មែររហូតដល់ពាក់កណ្តាលសតវត្សរ៍ទី២០ ។ "ប្រជាជនស្ទើរតែមួយរយភាគរយនិយាយភាសាខ្មែរនៅទីនោះ ។ ប៉ុន្តែបច្ចុប្បន្នប្រជាជននៅទីនេះ សំដៅទៅលើប្រជាជន ដែលរស់នៅក្នុងខេត្តស៊ីសាកេត (ប្រទេសថៃ) ស្ទើរតែមួយរយភាគរយនិយាយភាសាថៃ ។"

## រឿងរ៉ាវរបស់ចោរប្លន់ម្នាក់

នៅខែវិច្ឆិកា ឆ្នាំ១៩០៧ អាជ្ញាធរកម្ពុជាបានចាប់ខ្លួនចោរប្លន់ម្នាក់ដែលមានឈ្មោះថា អាឃួន ដែលបានចូលរួមប្រព្រឹត្តអំពើឆក់ប្លន់នៅក្នុងតំបន់ ។ អាឃួន បានរត់គេចខ្លួនពីរបីថ្ងៃបន្ទាប់ពីជាប់ឃុំឃាំង ។ ប៉ុន្តែ មុនពេលគេចខ្លួន អាឃួន បានប្រាប់រឿងមួយចំនួនទាក់ទងទៅនឹងក្រុមចោរប្លន់ ដែលធ្វើឲ្យអាជ្ញាធរបារាំងដឹងកាន់តែច្បាស់អំពីការសង្ស័យរបស់ខ្លួន អំពីអំពើសមគំនិតរបស់មន្ត្រីរាជការស៊ីវិលសៀម នៅក្នុងអំពីឆក់ប្លន់នោះ ។ អាឃួនគឺជាជនជាតិខ្មែរម្នាក់ដែលរស់នៅក្នុងភូមិធ្នង់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យបច្ចុប្បន្ន ។ នៅដើមខែតុលា ឆ្នាំ១៩០៨ ក្រុមចោរដែលមានគ្នាប្រហែល៦០នាក់ ប្រដាប់ដោយកាំភ្លើង និងដាវ បានចូលមកក្នុងភូមិរបស់ អាឃួន ។ មេចោរបានចាត់គ្នារបស់ខ្លួនប្រហែល៣០នាក់ ឲ្យដើរប្រមូលអ្នកភូមិ និងចាប់បញ្ជូនអ្នកភូមិទាំងនោះទៅឃុំគោលខេត្តសង់គៀក ប្រទេសសៀម ។ អាឃួន ស្ថិតនៅក្នុងអ្នកភូមិដែលក្រុមចោរបានកៀរយកទៅ ។ ក្រុមចោរបានប្រមូលបណ្ណបង់ពន្ធទាំងអស់របស់អ្នកភូមិ ហើយកម្ទេចចោលដោយបាននិយាយថា ខ្លួននឹងមិនអនុញ្ញាតឲ្យអ្នកភូមិទាំងអស់ជាប់ពាក់ព័ន្ធជាមួយនឹងបារាំងទៀតទេ ។ មិនតែប៉ុណ្ណោះ ក្រុមចោរទាំងនោះបានដើរប្រមូលសត្វគោ និងសត្វចិញ្ចឹមផ្សេងៗទៅជាមួយ ប៉ុន្តែបានបោះបង់ចោលទៅវិញ ដើម្បីកុំឲ្យយឺតដំណើររបស់ខ្លួន ។ ក្រុមចោរបានបង្ខំ អាឃួន ឲ្យធ្វើជាអ្នកនាំផ្លូវនៅក្នុងការចូលទៅឆក់ប្លន់ភូមិផ្សេងៗទៀតនៅក្នុង

ទឹកដីខ្មែរ ។ ក្រុមចោរបានបញ្ឆោឲ្យ អាឃួន នាំពួកខ្លួនទៅភូមិដូនលក ភូមិទង ក្នុងខេត្តចុងកាល់ ។ នៅក្នុងភូមិទាំងពីរ ក្រុមចោរបានចាត់ឲ្យកម្លាំងរបស់ខ្លួន ដើរប្រមូលអ្នកភូមិ ហើយនាំយកទៅប្រទេសសៀម ។ សមាជិកក្រុមដែលនៅសេសសល់បានបន្តទៅប្លន់នៅអន្លង់វែង ។ ប៉ុន្តែដោយសារតែភ្លៀងធ្លាក់ខ្លាំងក្រុមចោរទាំងអស់នោះមិនអាចធ្វើដំណើរទៅដល់តំបន់អន្លង់វែងនោះបានទេ ។ ដោយសារសមាជិកភាគច្រើនមិនចេះហែលទឹក ក្រុមចោរទាំងអស់នោះបានសម្រេចចិត្តវិលត្រឡប់ទៅប្រទេសសៀមវិញ ។

**អំពើឆក់ប្លន់**

យើងអាចធ្វើការប៉ាន់ស្មានបានថា ដោយសារតំបន់អន្លង់វែងស្ថិតនៅឆ្ងាយពីការគ្រប់គ្រងរបស់រដ្ឋាភិបាល យើងមិនអាចដឹងអំពីប្រវត្តិដើមរបស់ប្រជាជន ដែលបានមកតាំងទីនៅក្នុងតំបន់នេះដំបូងបង្អស់បានទេ ។ នៅក្រោមការជិះជាន់របស់ក្រុមអភិជន និងមន្ត្រីរាជការក្នុងតំបន់ ប្រជាជនសាមញ្ញជាញឹកញាប់ទទួលរងការចាប់កំណែនកងទ័ព ការបង្ខំឲ្យធ្វើការងារធ្ងន់ និងការបង់ពន្ធ ។ ដោយពុំមានមធ្យោបាយក្នុងការការពារខ្លួន ប្រជាជនភាគច្រើនយល់ឃើញថា មានតែតំបន់ព្រៃភ្នំ និងតំបន់តាមព្រំដែនទេជាតំបន់មានសេរីភាព ផុតពីកណ្តាប់ដៃរបស់អាជ្ញាធរ ។ ប៉ុន្តែនេះមិនមែនមានន័យថា ប្រជាជនទាំងនេះសុទ្ធតែភៀសខ្លួនចេញពីការធ្វើទុក្ខបុកម្នេញនោះទេ ។ ការឆក់ប្លន់នៅតាមភូមិកើតមានឡើងនៅក្នុងប្រទេសកម្ពុជាជាច្រើនសតវត្សរ៍មកហើយ ហើយអំពើនេះភាគច្រើនកើតឡើងនៅ«ទីតាំងដែលមានលក្ខខណ្ឌភូមិសាស្ត្រអំណោយផលដែលអាចឲ្យក្រុមចោរប្លន់រត់គេចខ្លួនចូលទៅក្នុងព្រៃភ្នំ ឬរត់ឆ្លងព្រំដែន ។»

ប៉ុក គៀក អ្នកភូមិម្នាក់នៅអន្លង់វែងបានរំឭករឿងរ៉ាវដែលចាស់ៗ នៅក្នុងភូមិធ្លាប់តំណាលប្រាប់គាត់អំពីតំបន់អន្លង់វែងក្នុងសតវត្សរ៍ទី២០ ។ «អន្លង់វែងត្រូវបានហៅថា ជាភូមិចោរ ពីព្រោះប្រជាជននៅក្នុងតំបន់នេះ បានចូលលួចគោពីខេត្តសៀមរាបទៅលក់នៅប្រទេសថៃ ។ នៅពេលនោះ ប្រជាជននៅអន្លង់វែងពុំមានការងារឬអាជីវកម្មពិតប្រាកដទេ ។» ទោះបីជាតាមការពិតអន្លង់វែងប្រហែលជាមិនមែនជា«ភូមិចោរ»ក្តី ក៏យើងអាចសន្និដ្ឋានបានថា លក្ខខណ្ឌភូមិសាស្ត្រតំបន់អន្លង់វែងបានអូសទាញក្រុមចោរជាច្រើនឲ្យមកតាំងទីលំនៅជាមួយនឹងប្រជាជនទូទៅដែរ ។

មកត្រឹមឆ្នាំ១៨៩២ រដ្ឋាភិបាលអាណានិគមបារាំងបានគ្រប់គ្រងលើការប្រមូលយកពន្ធដារស្ទើរតែទាំងអស់ ហើយក្រោយមកបារាំងបានគ្រប់គ្រងមកលើរដ្ឋបាលខ្មែរស្ទើរតែគ្រប់ផ្នែក ។ ការយាងសោយព្រះទិវង្គតរបស់ព្រះបាទ នរោត្តម និងការឡើងគ្រងរាជ្យរបស់ព្រះអនុជរបស់ព្រះអង្គគឺ ព្រះបាទ ស៊ីសុវត្ថិ នៅឆ្នាំ១៩០៤ បង្កើតបាននូវរដូវកាលថ្មីមួយនៃការប្រមូលផ្តុំអំណាចរដ្ឋបាលកាន់តែខ្លាំងជាងមុន និងការប្រមូលពន្ធដារកាន់តែច្រើនឡើងពីសំណាក់បារាំង ដែលប្រការទាំងនេះបានបង្កឲ្យមានវិបត្តិសង្គមកាន់តែខ្លាំងឡើង ។ ខណៈពេលដែលបារាំងបង្កើនការគ្រប់គ្រងទៅលើរដ្ឋបាល ការប្រមូលពន្ធ និងកាតព្វកិច្ចផ្សេងៗទៀតកាន់តែខ្លាំងឡើង ប្រជាជនបានរត់ចូលកាន់តែជ្រៅទៅរស់នៅក្នុងព្រៃ និងតាមតំបន់ព្រំដែន ។ នៅពេលដែលតំបន់ព្រៃទាំងនោះក៏ត្រូវបានគ្រប់គ្រងកាន់តែខ្លាំងឡើងប្រជាជនមួយចំនួនបានចាប់ផ្តើមផ្លាស់ទីលំនៅទៅកាន់ប្រទេសសៀម ឬប្រទេសលាវក្នុងអំឡុងពេលនៃការប្រមូលពន្ធ និងវិលត្រឡប់មកវិញ នៅពេលដែលអាជ្ញាធរចាកចេញទៅវិញ ។

តំបន់ព្រំដែនបានក្លាយទៅជាផ្លូវសម្រាប់ជនដែលរត់គេចចេញពីការបង់ពន្ធ និងជាតំបន់ជម្លោះ ។ នៅឆ្នាំ១៩០៧ បារាំងបានចរចាឲ្យថៃប្រគល់ខេត្តបាត់ដំបង និងខេត្តសៀមរាប មកឲ្យកម្ពុជាវិញ ។ ទោះបីជាសៀមត្រូវបានបង្ខំយ៉ាងណាក៏ដោយ ក៏សៀមមិនសុខចិត្តប្រគល់ខេត្តទាំងពីរនេះ មកឲ្យកម្ពុជាវិញដោយសន្តិវិធីដែរ ។

នៅក្នុងឆ្នាំដដែលនោះដែរ នៅពេលដែលកម្ពុជាទាមទារមកវិញនូវទឹកដីភាគខាងជើង និងភាគខាងលិចពីសៀម កម្ពុជាក៏ទទួលរងការវាយប្រហារយ៉ាងខ្លាំងជាបន្តបន្ទាប់ពីសំណាក់ក្រុមចោរប្លន់នៅក្នុងខេត្តបាត់ដំបង និងតំបន់អន្លង់វែង ។

នៅឆ្នាំ១៩០៧ របាយការណ៍សំខាន់ៗជាច្រើនបានរៀបរាប់អំពីក្រុមចោរប្លន់ដែលបានធ្វើប្រតិបត្តិការនៅលើទឹកដីភាគខាងជើង និងខាងលិចនៃប្រទេសកម្ពុជា ។ ប្រជាជននៅក្នុងភូមិបានរាយការណ៍ទៅមន្ត្រីបារាំងថា ក្រុមចោរប្លន់ប្រហែលពី៦០ទៅ៩០នាក់មកពីសៀមបានចូលមកក្នុងភូមិជាច្រើននៅអន្លង់វែង និងតំបន់មួយចំនួននៅក្នុងខេត្តបាត់ដំបង ដោយបានបង្ខំប្រជាជនឲ្យទៅប្រទេសសៀមជាមួយខ្លួន ដោយបានគំរាមសម្លាប់ ។ អ្នកភូមិជាច្រើនមានការភ័យខ្លាច ហើយបានរត់ភៀសខ្លួនទៅកាន់ភូមិមួយចំនួនរបស់

សៀម ដូចជាភូមិសង់គា បាសាន ឬចូលជ្រៅទៅក្នុងប្រទេសថៃនាពេលបច្ចុប្បន្ន ។ បន្ទាប់ពីក្រុមចោរប្លន់បានចាកចេញ អាជ្ញាធរបារាំងបានធ្វើដំណើរទៅកាន់តំបន់ទាំងនោះ ដើម្បីធ្វើការស៊ើបអង្កេត គឺគ្រាន់តែទៅមើលគ្រួសារសេសសល់មួយចំនួនតូចប៉ុណ្ណោះ ។

ដោយទទួលស្គាល់ពីការគំរាមកំហែងក្នុងទ្រង់ទ្រាយធំបែបនេះ អាជ្ញាធរបារាំងបានចាត់តាំងកម្លាំងឈ្លបប្រហែល១៥នាក់ឲ្យធ្វើដំណើរទៅកាន់ព្រំដែនក្នុងតំបន់អន្លង់វែង ដើម្បីសង្កេតមើល ។

ជីវិតនៅអន្លង់វែង នៅក្នុងរយៈកាលនោះ មានភាពឯកោ និងលំបាក ។ មានទំនាក់ទំនងតិចតួចណាស់ទៅកាន់ពិភពខាងក្រៅ ។ ដូច្នេះ កម្លាំងប៉ូលិសណាដែលត្រូវបានចាត់តាំងឲ្យទៅប្រចាំការនៅតំបន់ទាំងនោះត្រូវពឹងផ្អែកទាំងស្រុងទៅលើធនធាននៅក្នុងតំបន់ទាំងនោះ ។ ដោយយល់ឃើញពីស្ថានភាពលំបាកនៅតំបន់ទាំងនោះ អាជ្ញាធរបារាំងបានសម្រេចផ្លាស់ប្តូរកម្លាំងនគរបាលរបស់ខ្លួនរៀងរាល់៣ខែម្តង ។

ទោះបីជាអាជ្ញាធរបារាំងមិនអាចរកភស្តុតាងបញ្ជាក់បានថា រដ្ឋាភិបាលសៀមមានការសមគំនិតជាមួយនឹងសកម្មភាពឆក់ប្លន់ខាងលើក៏ដោយ ក៏បារាំងបានសន្និដ្ឋានថា សកម្មភាពឆក់ប្លន់នោះទទួលបានការជំរុញលើកទឹកចិត្តពីអាជ្ញាធរសៀម ។ ភស្តុតាងនៃសម្ព័ន្ធភាពនេះ យោងទៅលើយុទ្ធសាស្ត្រជាបន្តរបស់ក្រុមចោរប្លន់ ក្នុងការបោសសម្អាតភូមិមិនឲ្យមានមនុស្សរស់នៅ ដែលផ្ទុយនឹងផលប្រយោជន៍នៃអំពើឆក់ប្លន់ ។ អាជ្ញាធរបារាំងសង្ស័យថា មន្ត្រីសៀមបានប្រាប់ក្រុមចោរទាំងអស់នោះឲ្យធ្វើការឆក់ប្លន់ភូមិរបស់ខ្មែរតាមតែអាចធ្វើបាន និងប្រមូលប្រជាជនខ្មែរមកប្រទេសសៀម បើមិនដូច្នោះទេ ក្រុមចោរទាំងនោះនឹងត្រូវអាជ្ញាធរសៀមដាក់ទោស ។ អាជ្ញាធរបារាំងសង្ស័យថា សមាជិកមួយចំនួនរបស់ក្រុមចោរ គឺជាជនជាតិខ្មែរ ដែលត្រូវបានកៀរ និងបង្ខំឲ្យចូលរួមនៅក្នុងសកម្មភាពឆក់ប្លន់ទាំងនោះ ។

## ជីវិតរស់នៅក្នុងតំបន់អន្លង់វែងៈ ១៩០៨-១៩៧០

មិនខុសពីប្រទេសអាណានិគមដទៃទៀតទេ អាណានិគមបារាំងក៏ត្រូវបានជំរុញឲ្យកេងប្រវ័ញ្ចទៅលើប្រភពធនធានរបស់កម្ពុជា និងបង្កើនពាណិជ្ជកម្មដើម្បីផលប្រយោជន៍របស់ខ្លួន ។ ទន្ទឹមនឹងផលប្រយោជន៍សេដ្ឋកិច្ច និងផលប្រយោជន៍ផ្នែកភូមិសាស្ត្រជាយុទ្ធសាស្ត្រ ប្រទេសអាណានិគមក៏បានស្វែងរកការផ្សព្វផ្សាយវប្បធម៌របស់ខ្លួន និងនៅក្នុងកម្រិតកំណត់ណាមួយដើម្បីធ្វើឲ្យប្រសើរឡើងដល់ជីវិត និងសហគមន៍របស់ប្រទេសដែលស្ថិតនៅក្រោមអាណានិគម ។ ការចាប់អារម្មណ៍របស់បារាំង នៅក្នុងការអភិវឌ្ឍវិស័យវប្បធម៌ និងសេដ្ឋកិច្ចសង្គម ដែលត្រូវបានស្គាល់ថា «បេសកកម្មពង្រីកអារ្យធម៌ខ្ពង់ខ្ពស់» គឺជាផ្នែកមួយដ៏សំខាន់របស់អាណានិគមនិយមបារាំងនៅក្នុងប្រទេសកម្ពុជា ។

បារាំងបានធ្វើកំណាយសិក្សា និងជួសជុលប្រាសាទដែលកសាងឡើងនៅសម័យអង្គរ និងរូបចម្លាក់ជាច្រើន ដែលភ្ញៀវទេសចរណ៍បានឃើញនាពេលបច្ចុប្បន្ន ។ បារាំងក៏បានសាងសង់ផ្លូវថ្នល់ ផ្លូវរថភ្លើង និងខ្សែកាបទូរសារ ។ ជាងនេះទៅទៀត បារាំងបានរៀបចំ និងធ្វើមជ្ឈការឡើងវិញនូវការប្រមូលពន្ធដារ និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ព្រមទាំងបានបង្កើតកម្មវិធីកិច្ចការសាធារណៈក្នុងទ្រង់ទ្រាយធំ ។

ប៉ុន្តែនៅពេលដែលបារាំងបានចំណាយពេលវេលា និងធនធានយ៉ាងច្រើនទៅលើការពង្រឹងការអភិវឌ្ឍរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល និងសេដ្ឋកិច្ចសង្គមរបស់កម្ពុជាទាំងមូល ការពង្រីកវិស័យអប់រំ សុខាភិបាល និងជីវភាពរស់នៅជាទូទៅរបស់ប្រជាជននៅតាមទីជនបទនៅមានភាពខ្វះខាត ។ មិនខុសពីតំបន់ដាច់ស្រយាលដទៃទៀតនៅក្នុងប្រទេសកម្ពុជា នៅដើមសតវត្សរ៍ទី២០ តំបន់អន្លង់វែងមានការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធគ្រឿងបរិក្ខារពេទ្យ បុគ្គលិកពេទ្យដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងថ្នាំសង្កូវ ។ ហេតុដូច្នេះ ជំងឺនៅតែបន្តជាបញ្ហាគ្រោះថ្នាក់ដល់ប្រជាជននៅក្នុងតំបន់ជាពិសេស គឺជំងឺឆ្លង ។

ជាក់ស្តែង មិនថាប្រជាជនកើតនៅក្នុងសតវត្សរ៍ណាទេ ភាពលំបាកវេទនានៅក្នុងជីវភាពរស់នៅ និងភាពមិនទៀងទាត់ក្នុងការរស់រានមានជីវិតជាមនុស្ស បានក្លាយទៅជាផ្នែកមួយនៃជីវិតរបស់ប្រជាជន ដែលរស់នៅតាមតំបន់ជនបទដាច់ស្រយាល និងតាមបណ្តោយព្រំដែន ។

ភូមិសាង៉ាំ បារាំង ហៅភូមិនេះថា (ភូមិស្រង៉ាំ) ស្ថិតនៅចម្ងាយប្រហែល១២គីឡូម៉ែត្រពីតំបន់អន្លង់វែង ដែលជាចំណុចប្រសព្វរវាងព្រំដែនកម្ពុជា និងថៃបច្ចុប្បន្ន ។ យោងតាមចាស់ទុំជនជាតិថៃ

ភូមិនេះស្ថិតនៅលើទីតាំងនៃច្រកព្រំដែនជាំសាង៉ាំសព្វថ្ងៃ ។ ដូចគ្នាទៅនឹងតំបន់អន្លង់វែងដែរ ភូមិនេះត្រូវបានអ្នកគូរផែនទីបារាំងទទួលស្គាល់នៅពេលធ្វើគំនូសបែងចែកព្រំដែន កម្ពុជា-សៀម នៅចន្លោះឆ្នាំ១៩០៧-១៩០៩ ។

ភូមិសាង៉ាំ ត្រូវបានដាក់ឈ្មោះតាមដើមឈើធំមួយប្រភេទដែលដុះនៅក្នុងភូមិ ។ ចាស់ៗជនជាតិថៃបានពិពណ៌នាថា ភូមិនេះគឺជាភូមិដែលជនជាតិសៀម និងខ្មែរបានមកតាំងទីរស់នៅជាមួយគ្នា ។ ដូចគ្នាជាមួយនឹងភូមិផ្សេងៗទៀតនៅក្នុងតំបន់នេះ ប្រជាជនភាគច្រើននៅក្នុងភូមិនិយាយភាសាខ្មែរ ។

នៅឆ្នាំ១៩៤៨ ប្រជាជននៅក្នុងភូមិនេះបានទទួលរងគ្រោះពីជំងឺរាតត្បាត ។ ប៉ុន្តែ រឿងរ៉ាវលម្អិតអំពីជំងឺនេះហាក់នៅមានភាពស្រពេចស្រពិលនៅឡើយ ។ បើយោងតាមចាស់ៗជនជាតិថៃមួយចំនួន ភូមិសាង៉ាំ ត្រូវបានបំផ្លាញដោយសារជំងឺអាសន្នរោគ ។ ភូមិសាង៉ាំ នៅតែជាតំបន់ពាណិជ្ជកម្មក្នុងតំបន់មួយនាពេលបច្ចុប្បន្ននេះ ។

ការផ្ទុះឡើងនៃជំងឺអាសន្នរោគនៅទសវត្សរ៍ឆ្នាំ១៩៤០ បានបណ្តាលឲ្យប្រជាជនជាច្រើនភូមិបាត់បង់ជីវិត ។ ទោះបីជាពុំមានទិន្នន័យច្បាស់លាស់ដើម្បីបញ្ជាក់អំពីរឿងនេះក្តី ក៏ជំងឺនេះត្រូវបានជឿជាក់ថា មានប្រភពចេញមកពីភូមិរឿនដី ប្រទេសសៀម ដែលស្ថិតនៅចម្ងាយប្រមាណ១០គីឡូម៉ែត្រពីភូមិសាង៉ាំ ។ ជំងឺនេះបានរាលដាលដល់ភូមិសាង៉ាំ ដែលបានបណ្តាលឲ្យប្រជាជនស្ទើរគ្រប់គ្នាឆ្លងជំងឺនេះ ។ អ្នកដែលអាចគេចផុតពីជំងឺនេះ បានចាកចេញពីភូមិ ហើយភូមិទាំងមូលត្រូវបានបោះបង់ចោល ។

នៅក្នុងប្រទេសថៃសព្វថ្ងៃនេះ មានតែចាស់ៗជនជាតិថៃម្នាក់ ឬពីរនាក់ប៉ុណ្ណោះដែលរួចរស់ជីវិត នៅពេលជំងឺអាសន្នរោគបានរាតត្បាត ។ ប៉ុន្តែ រឿងរ៉ាវអំពីជំងឺអាសន្នរោគដែលបានបង្កជាគ្រោះមហន្តរាយដ៏ធ្ងន់នេះ ត្រូវបានជនជាតិថៃនៅតាមតំបន់ព្រំដែននិយាយប្រាប់គ្នាពីជំនាន់មួយទៅជំនាន់មួយរហូតដល់សព្វថ្ងៃ ។

យើងមិនបានដឹងច្បាស់ទេថា តើតំបន់អន្លង់វែង ឬភូមិខ្មែរនៅក្បែរនោះទទួលរងគ្រោះពីជំងឺអាសន្នរោគនោះដែរឬយ៉ាងណានោះទេ ។ ទោះជាយ៉ាងនេះក្តី បើពិនិត្យទៅតាមទីតាំងភូមិសាស្ត្រនៃភូមិសាង៉ាំ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីភូមិថៃ ដែលអាចដើរដល់ក្នុងរយៈពេលមួយថ្ងៃ យើងអាចសន្និដ្ឋានបានថា ជំងឺអាសន្នរោគដែលមានប្រភពចេញពីប្រទេសថៃ នៅចុងទសវត្សរ៍ឆ្នាំ១៩៤០ អាចរាលដាលដល់ភូមិមួយចំនួននៅជុំវិញតំបន់អន្លង់វែង ។ សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើឡើងដោយសារតែតំបន់នេះ ជាតំបន់ដែលមានប្រជាជនធ្វើដំណើរចេញចូលរវាងប្រទេសកម្ពុជា និងថៃ ព្រមទាំងភាពប្រហាក់ប្រហែលគ្នានៃស្ថានភាពសេដ្ឋកិច្ច និងសង្គមនៅតាមតំបន់ដែលស្ថិតនៅតាមបណ្តោយព្រំដែន ។ រហូតមកដល់ទសវត្សរ៍ឆ្នាំ១៩៩០ សេវាសុខាភិបាលសាធារណៈផ្លូវគមនាគមន៍ និងប្រព័ន្ធអប់រំនៅមានកម្រិតទាបខ្លាំងនៅឡើយ (ឬស្ទើរតែមិនមានទាល់តែសោះ) នៅក្នុងតំបន់អន្លង់វែង ។

មី ឆេង បានរំឭកថា នៅទសវត្សរ៍ឆ្នាំ១៩៥០ តំបន់អន្លង់វែងមានសាលារៀនតែមួយប៉ុណ្ណោះ ។ ភូមិរំចេកដែលជាភូមិចាស់នៅតំបន់អន្លង់វែង មានប្រជាជនជាង៥០គ្រួសារពុំមានសាលារៀនទេ ។ ដូចគ្នាដែរ ភូមិតាដេវ និងភូមិខ្នុរក៏មិនមានសាលារៀនដែរ ។ ដូចដែលធីន ប៊ិន បានលើកឡើង «កុមារតូចៗមិនបានទៅសាលារៀនទេ ។ ពួកគេធំដឹងក្តីដោយមិនចេះអក្សរ» ។ ឈិតធី យល់ស្របដោយបាននិយាយថា «មិនបានទៅសាលារៀននោះទេ ដោយសារតែត្រូវជួយក្រុមគ្រួសាររបស់ខ្លួនក្នុងការរកស៊ីចិញ្ចឹមជីវិត» ។

ចាន់ បៃ ដែលជាអ្នកភូមិមួយរូបនៅតំបន់អន្លង់វែងបានរៀបរាប់អំពីជីវិតរស់នៅ ក្នុងភូមិខ្នុរ កាលពីមុនឆ្នាំ១៩៧៥ថា ៖

នៅពេលនោះ នៅក្នុងភូមិនេះមានប្រជាជនរស់នៅតែ៦គ្រួសារប៉ុណ្ណោះ ។ កុមារតូចៗ មិនបានទៅសាលារៀននោះទេ ។ ប្រជាជនដីកក្តួច និងដំឡូងព្រៃសម្រាប់បរិភោគ ហើយមិនដែលពាក់អាវ ឬសម្លៀកបំពាក់ស្អាតៗដូចសព្វថ្ងៃនេះទេ ។ ជាទូទៅយើងស្លៀកសម្លៀកបំពាក់ប្រឡាក់ ។ យើងមិនមានលុយទិញប៊ីចេងទេ ។ យើងបរិភោគតែបាយជាមួយអំបិលដែលទិញមកពីភូមិខ្វារ ប្រទេសថៃ ។ នៅទីនេះពុំមានផ្សារ ឬផ្លូវថ្នល់នៅឡើយទេ ។ យើងត្រូវចំណាយពេល១០ថ្ងៃធ្វើដំណើរដោយថ្មើរជើងឆ្លងកាត់ភ្នំដើម្បីទៅដល់តំបន់ប្រជុំជននៅក្នុងទឹកដីកម្ពុជា ។ ប៉ុន្តែប្រសិនបើយើងចង់ទិញអំបិល យើងគ្រាន់តែធ្វើដំណើរទៅថៃ ស្នាក់នៅទីនោះមួយយប់ ហើយត្រឡប់មកភូមិវិញនៅថ្ងៃបន្ទាប់ ។

ការកំណត់អាយុចូលរៀនក៏ត្រូវបានគណនាខុសពីបច្ចុប្បន្នដែរ ។ ដោយសារតែថ្ងៃ ខែឆ្នាំកំណើត និងអាយុមិនត្រូវបានប្រជា

ជនចង់ចាំបុកត់ត្រាទុក ប្រជាជនបានប្រើប្រាស់វិធីប្រកបដោយភាពច្នៃប្រឌិតនៅពេលកុមារធំដឹងក្តីល្មមអាចចូលសាលារៀនបាន ។

នៅពេលខ្ញុំចូលរៀននៅខេត្តតាកែវ នៅដើមទសវត្សរ៍ឆ្នាំ១៩៦០ អាយុចូលរៀននៅពេលនោះ មានភាពខុសគ្នាពីអាយុចូលរៀនបច្ចុប្បន្នច្រើនណាស់ ។ នៅពេលដែលខ្ញុំនៅជាកុមារ យើងត្រូវយកដៃរបស់យើងដាក់លើក្បាល ហើយព្យាយាមប៉ះត្រចៀកម្ខាងទៀត ។ ប្រសិនបើដៃរបស់យើងមិនអាចប៉ះត្រចៀកម្ខាងទៀតបានទេ យើងនឹងមិនត្រូវបានអនុញ្ញាតឲ្យចុះឈ្មោះចូលរៀនទេ ។ ជាទូទៅកុមារភាគច្រើនមានអាយុ១០ឆ្នាំ ទើបបានចូលរៀន ។

សេដ្ឋកិច្ចតំបន់អន្លង់វែង ពឹងផ្អែកទាំងស្រុងទៅលើការដាំដុះ និងភោគផលផ្សេងៗ ដែលអាចប្រមូលបាននៅលើដី ។ ដោយសារតែពុំមានរូបិយបណ្ណ ប្រជាជនប្រើមធ្យោបាយដោះដូរដើម្បីទិញទំនិញ ។ “យើងពុំមានក្រដាសប្រាក់ ឬប្រាក់កាក់នោះទេ ។ ដូច្នេះ យើងបានយកកន្ទេល និងផ្តៅទៅដូរអំបិលជាមួយថៃ ។” ប្រជាជននៅក្នុងតំបន់ក៏ធ្វើស្រែ និងដាំផ្លែឈើដូចជា ស្វាយ និងដើមឈើហូបផ្លែដទៃទៀតអាស្រ័យទៅនឹងលក្ខខណ្ឌដី ។

មធ្យោបាយដឹកជញ្ជូនមានចំនួនតិចតួចណាស់ ដោយសារតែពុំមានផ្លូវសម្រាប់ធ្វើដំណើរ ។ មិនមានប្រជាជនណាម្នាក់មានរថយន្ត ឬម៉ូតូនោះទេ ។ តាមពិតទៅ ស្ទើរតែគ្មានប្រជាជនណាម្នាក់មានកង់ជិះនោះទេ ។

មនុស្សគ្រប់គ្នាធ្វើដំណើរដោយថ្មើរជើង ។ យើងចំណាយពេលមួយថ្ងៃ ដើម្បីធ្វើដំណើរពីអន្លង់វែងទៅរំចេក ។ យើងទៅដល់រំចេកនៅពេលថ្ងៃត្រង់ ។ ប្រជាជនមួយចំនួនជិះរទេះ ។ ប៉ុន្តែដោយសារគ្រួសារខ្ញុំមិនមានរទេះ យើងត្រូវដើរ និងឈប់សម្រាកតាមផ្លូវ ប្រសិនបើយើងចង់ធ្វើដំណើរទៅតំបន់ឆ្ងាយ ដូចជា ស្រែណូយ ។

ដោយសារតែកង្វះមធ្យោបាយធ្វើដំណើរ និងផ្លូវថ្នល់ វាមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលទេ ដែលប្រជាជនកម្រនឹងចាកចេញពីភូមិណាស់ ។ ឈិត ធី បានរៀបរាប់អំពីជីវិតរបស់គាត់នៅក្នុងរជ្ជកាលព្រះបាទនរោត្តម សីហនុ (១៩៤១-១៩៥៥)ថា “ប្រជាជនកម្រមានទំនាក់ទំនងជាមួយគ្នាណាស់ ។ អ្នកភូមិរស់នៅ ធ្វើការងារ និងប្រកបរបររកស៊ីតែនៅក្នុងភូមិរៀងៗខ្លួន” ។ ចាន់ បៃ បានលើកឡើងថា “ខ្ញុំមិនដែលបានចាកចេញពីភូមិរបស់ខ្ញុំនោះឡើយ ក្នុងមួយយុវវ័យរបស់ខ្ញុំ” ។

ដោយសារតែខ្វះការផ្លាស់ប្តូរ និងភាពក្រីក្រនៅក្នុងតំបន់ ការផ្គត់ផ្គង់សម្លៀកបំពាក់នៅមានកម្រិតតិចតួចណាស់ ។

ប្រជាជននៅភូមិរំចេកភាគច្រើនជាអ្នកក្រ ។ ជាទូទៅ គាត់គ្រាន់តែរុំក្រណាត់ ដើម្បីគ្រាន់តែបិទបាំងរាងកាយតែប៉ុណ្ណោះ ។ បុរសភាគច្រើនមិនមានអាវពាក់ទេ ហើយបុរសមួយចំនួនទៀតមិនមានខោស្លៀកទេ ។ មិនមានកន្លែងលក់សម្លៀកបំពាក់ច្រើនទេ ។ ជនជាតិថៃធ្វើដំណើរមកដល់ទីនេះរៀងរាល់១០ខែម្តង ដើម្បីធ្វើជំនួញ ។

ទំនៀមទម្លាប់ និងពិធីបុណ្យនៅក្នុងភូមិក៏មានលក្ខណៈខុសពីពិធីនាពេលបច្ចុប្បន្នដែរ ។ បើយោងតាម ចាន់ បៃ “នៅក្នុងពិធីរៀបមង្គលការពុំមានការលេងភ្លេង ឬគោះស្គរទេ ។ ប្រជាជនគ្រាន់តែសម្លាប់ជ្រូកមួយ ហើយចាស់ៗនៅក្នុងភូមិបីបួននាក់ ធ្វើជាអធិបតីនៅក្នុងពិធី ដើម្បីជាការគោរពទៅដល់ព្រលឹងដូនតាតែប៉ុណ្ណោះ ។” រហូតដល់ទសវត្សរ៍ឆ្នាំ១៩៨០ តំបន់អន្លង់វែងនៅតែសំបូរទៅដោយសត្វព្រៃជាច្រើន ។ “ដំរីតែងតែចូលមកក្នុងភូមិតាដេវ ។” តំបន់នេះក៏មានសត្វគោព្រៃ ក្របីព្រៃ និងសត្វខ្លា ។ ជារឿយៗ អ្នកគ្រប់គ្រងបារាំងប្រចាំខេត្តស្ទឹងត្រែង (មានឋានៈស្មើអភិបាលខេត្ត) បានមកកត់ត្រាតារាងតម្លៃនៅលើទីផ្សារ ចំពោះស្បែកសត្វដំរី ស្បែកសត្វរមាស ថ្គាមខ្លា ភ្លុក និងស្រកាពង្រូល ។

សត្វព្រៃត្រូវបានមើលឃើញថាជាប្រភពចំណូលផង និងជាគ្រោះថ្នាក់ផង ។ ដូចដែល មី ឆេង បានលើកឡើង “យើងប្រើប្រាស់កាំភ្លើង ដើម្បីការពារភូមិរបស់យើង ពីការទន្ទ្រានរបស់សត្វដំរី ដែលបានចូលមកស៊ីស្រូវរបស់យើង ។” ធីន ប៊ិន ក៏បានរំឭកដែរថា សត្វខ្លា គឺជាការព្រួយបារម្ភរបស់ប្រជាជននៅក្នុងភូមិ ដោយសារតែសត្វខ្លា បានចូលមកក្នុងភូមិនៅពេលយប់ និងបានសម្លាប់សត្វឆ្កែ ។ ធីន ប៊ិន បានបន្ថែមថា “កាលពីដើម យើងហូបសាច់សត្វក្តាន់ ទន្សាយ ឈ្លុស អណ្តើក តឹកកែ បង្គួយ និងសត្វព្រៃផ្សេងៗទៀត ។ ប៉ុន្តែ សត្វទាំងអស់នោះ បានបាត់បង់អស់ហើយសព្វថ្ងៃនេះ ។

**(នៅមានត)**

**គ្រីស្តូហ្វ័រ ឌៀរីង និង ឌី ខាំបូលី**

# ដំណើរជីវិតរបស់ ជុង លាង ក្នុងរបបខ្មែរក្រហម

នាងខ្ញុំ ជួប ដានិត ជានិស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ នាងខ្ញុំបានចុះមកទស្សនកិច្ចរយៈពេលបីថ្ងៃនៅតំបន់អន្លង់វែង ដែលជាសមរភូមិចុងក្រោយរបស់ខ្មែរក្រហម ។ ជិះក្នុងចម្ងាយផ្លូវដ៏វែងពីភ្នំពេញមកអន្លង់វែង បានធ្វើឲ្យខ្ញុំគិត និងចង់ដឹងពីការតស៊ូ ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់នេះ និងរឿងរ៉ាវផ្សេងៗក្នុងរបបខ្មែរក្រហម ។ នៅថ្ងៃទីពីរ ខ្ញុំបានទៅដល់ភូមិមួយដែលមានសភាពស្ងប់ស្ងាត់ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីជើងភ្នំដងរែក ។ ភូមិនោះអ្នកស្រុកហៅថា ភូមិថ្លាត ស្ថិតនៅក្នុងឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ខ្ញុំបានចូលទៅផ្ទះលោកយាយ ជុង លាង អាយុ៦៥ឆ្នាំ និងតា ហេង ហៀង ។ គាត់ទាំងពីរមានកូនចំនួន១៣នាក់ មានស្រុកកំណើតនៅខេត្តកំពង់ចាម ។ យាយលាង បានផ្លាស់មករស់នៅស្រុកអន្លង់វែងក្រោយពេលខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ១៩៩៩ ។ ទោះបីយាយលាង មិនធ្លាប់រត់ភៀសខ្លួនពីសង្គ្រាមដូចអតីតយោធា និងកម្មាភិបាលខ្មែរក្រហមក្នុងតំបន់នេះក៏ដោយ តែគាត់ធ្លាប់បានឆ្លងកាត់ការឈឺចាប់ជាច្រើនក្នុងរបបបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃរបស់ខ្មែរក្រហម ។ យាយលាង បានរៀបរាប់ថា គាត់បានរស់នៅជាមួយឪពុកម្ដាយ និងបងប្អូនចំនួនដប់ពីរនាក់នៅខេត្តកំពង់ចាម ។



ជុង លាង នៅក្រោមផ្ទះរបស់គាត់ ក្នុងស្រុកអន្លង់វែង

នៅឆ្នាំ១៩៧០ ប្រទេសចាប់ផ្ដើមកើតសង្គ្រាម បងប្អូនរបស់គាត់ខ្លះបានរត់ចូលព្រៃ ហើយខ្លះទៀតត្រូវបានខ្មែរក្រហមចាត់ឲ្យធ្វើការងារតាមសហករណ៍ ។ ចំណែកគាត់ពេលនោះទើបតែសម្រាលកូនខ្ចី ខ្មែរក្រហមបានចាត់តាំងឲ្យកាប់ដីទប់ភ្លឺស្រែ ។ គាត់ធ្វើការជាមួយក្រុមអ្នកមានកូនខ្ចី និងអ្នកមានផ្ទៃពោះ ហើយយូរៗទើបត្រូវបានអនុញ្ញាតឲ្យជួបជុំប្ដីម្ដង តែធ្វើយ៉ាងណាកុំឲ្យបាក់ ប្រដាប់ទំនប់ ។ របបអាហារពេលនោះ ខ្មែរក្រហមចែកឲ្យគាត់ហូបក្នុងមួយថ្ងៃពីរពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច ប៉ុន្តែអង្ករការកំណត់ក្នុងមួយខ្ទះឲ្យចុងភៅដាក់អង្ករតែពីរកំប៉ុងប៉ុណ្ណោះ ដោយមនុស្សម្នាក់ទទួលបានរបបបបរមួយកូនចាន ។

នៅពេលនោះ ប្រធានកងបានបញ្ជាឲ្យក្រុមអ្នកមានកូនខ្ចីនិងមានផ្ទៃពោះ គាស់គល់ឈើបន្ថែមទៀតដើម្បីរានដីធ្វើស្រែ ។ ការគាស់គល់ឈើ ប្រធានកងបានកំណត់ក្នុងមួយថ្ងៃ ធ្វើយ៉ាងណាឲ្យរួចរាល់ក្នុងទំហំដីទទឹង១៥ម៉ែត្រ និងបណ្ដោយ២៥ ម៉ែត្រក្នុងមួយក្រុម ប្រសិនក្រុមណាធ្វើមិនហើយ ខ្មែរក្រហមមិនអនុញ្ញាតឲ្យហូបបាយឡើយ ។ បើទោះជាបានដឹងថាការងារធ្ងន់យ៉ាងណាក៏ដោយ ក៏យាយ លាង ខិតខំធ្វើដែរ ។ តែបើនរណាហ៊ានតវ៉ានោះអង្គការនឹងឲ្យឡើងសារភាពក្នុងពេលធ្វើមីទ្ទីងមិនខាន ។

ពេលខែវស្សាចូលមកដល់ យាយលាង ត្រូវបានប្រធានកងនិងប្រធានក្រុមចាត់ឲ្យទៅលើកភ្លឺស្រែ ដកសំណាប និងស្ទូងស្រូវ ។ តែដោយសារគាត់មានកូនតូច ដូច្នេះអង្គការយកកូនគាត់ទៅដាក់ឲ្យ

យាយចាស់ម្នាក់ដែលមានភារកិច្ចថែទាំក្មេងលើព្រះវិហា ជាអ្នកមើលថែ ។ យាយលាង បានបន្តថា ពេលនោះកូនរបស់គាត់ទៅបន្ទោរបង់លើព្រះ ហើយពេលដែលគាត់ត្រឡប់មកពីធ្វើការវិញ ស្រាប់តែកូនរបស់គាត់ឈឺជាទម្ងន់ ។ គាត់បានទៅបន់ព្រះដោយនិយាយខមាលទោសថា បើកូនគាត់ជាសះស្បើយ គាត់នឹងថ្វាយនូវស្វាធម៌ដូងមួយគូ ។

បន្ទាប់ពីបន់ស្រន់រួច ស្រាប់តែកូនរបស់គាត់ជាដូចបំណងទើបគាត់ប្រញាប់ទៅជួបប្រធានកងនារីដើម្បីសុំដូងយកទៅថ្វាយព្រះ ។ ប្រធានកងនារីមិនបានបដិសេធទេ ហើយសន្យានឹងជួយរកដូងឲ្យគាត់ថែមទៀត ។ ឪពុកយាយ លាង បានយកដូងធ្វើជាស្វាធម៌ រួចហើយប្រគល់ទៅឲ្យប្តីរបស់គាត់ឈ្មោះ ហៀង យកទៅថ្វាយព្រះ ។ ខណៈនោះ មានមនុស្សវិកលចរិតម្នាក់ឃើញដូងនោះ ក៏យកទៅកាប់ហូបនៅនឹងមុខប្រធានកងបុរស ។ ប្រធានកងនោះខឹងយ៉ាងខ្លាំង រួចហើយក៏សួរអ្នកដែលយកដូងទៅសែន ដែលនៅតែមានជំនឿដូច្នេះទៀត ។ ប្រធានកងបានបញ្ជាឲ្យសមាជិកកងហៅប្តីគាត់ទៅសួរនាំ រួចដាក់ទណ្ឌកម្មឲ្យធ្វើការងារដោយមិនឲ្យអាហារហូប ។ យាយលាង បានទៅសុំអង្វរប្រធានកងឲ្យលើកលែងទោសដល់ប្តីរបស់គាត់ ដោយប្រាប់ពីរហេតុផលផ្សេងៗ ។ ប៉ុន្តែទោះជាខំអង្វរយ៉ាងណា ក៏ប្រធានកងមិនអនុគ្រោះដែរ ។

ប្រធានកងបានចាត់តាំងប្តីរបស់គាត់ឲ្យកាប់ដីទប់ទំនប់ បន្ទាប់មកឲ្យទៅវាយព្រះនៅក្នុងវត្តចោលថែមទៀត ។ ចំណែកអាហារគឺអង្គការឲ្យហូបតែទឹកបបរប៉ុណ្ណោះក្នុងរយៈពេលមួយខែកន្លះ ។ នៅពេលនោះ ជារដូវធ្វើស្រូវប្រាំង និងមានកណ្តុរច្រើនទើបប្រធានកងបាននិយាយចំអកទៅកាន់គាត់ថា បើពូកែបន់បាត់អីចឹងម៉េចមិនទៅបន់កុំឲ្យកណ្តុរស៊ីស្រូវទៀតទៅ ។ ក្នុងសម័យនោះ ប្រសិនបើមាននរណាម្នាក់ហ៊ានទៅបែបន់អ្វី ក្រៅពីការធ្វើការងារជាក់ស្តែងប្រាកដជាអង្គការដាក់ទណ្ឌកម្មឲ្យធ្វើការ ឬបង្អត់បាយមិនខាន ។

ថ្ងៃមួយនោះ យាយ លាង ឃើញប្រធានកងដោះលែងបុរសម្នាក់ដែលជាប់ទណ្ឌកម្ម ដូចប្តីគាត់ដែរ ពេលដើរមកដល់ក្នុងភូមិបុរសនោះបានប្រទះឃើញដំឡូងមីមួយដុំក៏រើសហូបទាំងសម្បករួចហើយក៏ហូបផ្លែខ្វិតខ្វីថែមទៀតដោយសេចក្តីស្រេចឃ្លាន ធ្វើឲ្យបុរសនោះអួលប្រកាច់ស្លាប់នៅនឹងកន្លែងតែម្តង ។

ក្នុងសម័យនោះ គាត់មានការលំបាកយ៉ាងខ្លាំង តែគាត់គ្មានមធ្យោបាយរត់គេចឡើយ ។ មធ្យោបាយដែលអាចជួយគាត់ និងកូនៗឲ្យរស់បាន គឺមានតែការលួចទៅគាស់ក្តួច គាស់គល់ចេក គល់ល្ហុង និងរើសត្នោតទុំយកមកទុកឲ្យកូនៗហូបប៉ុណ្ណោះ តែបើសិនជាអង្គការដឹងនឹងយកទៅវាយចោលមិនខាន ។

នៅឆ្នាំ១៩៧៧ មានគ្រួសារមន្ត្រីស័ក្តិ៥មួយគ្រួសារត្រូវបានខ្មែរក្រហមបណ្តើរយកទៅសម្លាប់ចោល ដោយនៅសល់កូនពីរនាក់ (ប្រុសម្នាក់ និងស្រីម្នាក់) ហើយគាត់ក៏សម្រេចចិត្តសុំយកក្មេងទាំងពីរនោះមកចញ្ចឹម ។ ដោយសារតែគ្រួសារយាយ លាង មានក្មេងច្រើន ទើបបណ្តាលឲ្យប្រធានកងសង្ស័យ ហើយស៊ើបអង្កេតសកម្មភាពរបស់គាត់ ។

គាត់បានបញ្ជូនក្មេងស្រីម្នាក់ទៅឲ្យអ្នកជិតខាងចិញ្ចឹម ដោយទុកក្មេងប្រុសរស់នៅជាមួយគាត់ ។ បន្ទាប់ពីនោះ គ្រួសារយាយត្រូវបានអង្គការជម្លៀសឲ្យទៅរស់នៅភូមិថ្នល់កែង ។ នៅទីនោះប្រធានកងនារីបានចាត់ឲ្យគាត់ចូលក្នុងកងនារី និងចាត់តាំងឲ្យលើកភ្លឺស្រែ ។ ពេលនោះ យាយ លាង មានផ្ទៃពោះកូនបន្ទាប់ និងចាញ់កូនយ៉ាងខ្លាំង ទើបគាត់សុំប្រធានកងសម្រាក ។ តែប្រធានកងបានចោទថា គាត់ខ្ជិល និងមិនយល់ព្រមឲ្យគាត់ឈប់សម្រាកឡើយ ។ មិនតែប៉ុណ្ណោះអង្គការបានលើកឡើងថា យើងមិនដែលនិយាយរឿងដែលធ្វើការមិនកើតទេ ។ បើនរណាហ៊ាននិយាយពាក្យធ្វើមិនកើតអ្នកឯង គឺជាខ្មាំងត្រូវតែកម្ចាត់ចោលឲ្យអស់កុំឲ្យខូចដល់គេផ្សេងទៀត ។ យាយលាង តូចចិត្តយ៉ាងខ្លាំងពេលបានឮពាក្យនេះ ទើបគាត់ឆ្លើយទាំងកំហឹងតបទៅវិញថា «ចាស! ខ្ញុំនឹងធ្វើបើមិត្តមិនជឿថាខ្ញុំឈឺទេ! ខ្ញុំធ្វើរហូតទាល់តែដួលស្លាប់នៅនឹងកន្លែងតែម្តងក៏បាន!» ។

គាត់មិនសង្ឃឹមថា នឹងបានរស់ទេបន្ទាប់ពីនិយាយពាក្យនេះ ហើយបើខ្មែរក្រហមយកគាត់ទៅសម្លាប់ ក៏គាត់សប្បាយចិត្តដែរ ព្រោះគាត់បាននិយាយចេញនូវកំហឹងទាំងអស់មក ។ ជាមួយគ្នានោះ អ្នកនៅក្បែរគាត់ភ័យយ៉ាងខ្លាំង ហើយបាននាំគ្នាជួយឃាត់គាត់កុំឲ្យនិយាយបន្តទៀត ។ ផ្ទុយទៅវិញ ប្រធានកងមិនបានយកគាត់ទៅសម្លាប់ដូចការគិតទេ គ្រាន់តែនិយាយរួចប្រធានកងក៏ដើរចេញទៅ ។

ជារៀងរាល់ថ្ងៃ ក្រោយពីធ្វើការរួច យាយលាង មិនបាន

សម្រាកទេ ព្រោះត្រូវដើរលិចរេជីរកដាតិប្រៃ ។ ប្រសិនគាត់បានប្រទះឃើញដីដែលមានជាតិប្រៃ គាត់នឹងកាយយកទៅត្រាំជាមួយទឹក បន្ទាប់មកទុកឲ្យរងដើម្បីយកទៅរម្ងាស់យកអំបិលហូប ។ អំបិលដែលរម្ងាស់បានហៅថាអំបិលប្រាប ។ អំបិលនោះបើកាលណាហូបហើយ វានឹងធ្វើឲ្យហើមខ្លួនជាមិនខាន ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏គាត់នៅតែទ្រាំហូប ព្រោះប្រសិនបើគាត់មិនហូបក៏គាត់ក៏ដាច់ពោះស្លាប់ដែរ ។ ពេលខ្លះក្រោយពីហូបអំបិលនោះរួច គាត់ត្រូវហើមខ្លួន និងចេញទឹកមកតាមស្បែកថែមទៀត ។ យាយលាង បានបន្តថា គាត់ហូបស្ទើរតែគ្រប់សត្វល្អិតទាំងអស់ដើម្បីចម្អែតក្រពះក្នុងរបបខ្មែរក្រហម ។

នៅយប់មួយ កងឈ្លបខ្មែរក្រហមបានទៅផ្ទះឪពុកម្តាយក្មេករបស់គាត់ ភ្លាមនោះមេក្រុមបញ្ជាឲ្យកូនចៅចូលទៅចាប់សមាជិកគ្រួសារទាំងអស់ លើកលែងតែប្តីគាត់ម្នាក់ប៉ុណ្ណោះ ដែលបានបែកចេញមករស់នៅជាមួយគាត់ ។ ឈ្លបខ្មែរក្រហមបានចាប់សមាជិកគ្រួសារគាត់រុញបញ្ចូលក្នុងឡានរួចបើកចេញទៅបាត់ ។ ចាប់ពីពេលនោះគាត់បាត់ដំណឹងក្រុមគ្រួសារខាងប្តីគាត់រហូត ។ ទោះបីគាត់ឃើញខ្មែរក្រហមចាប់ក្រុមគ្រួសារនឹងភ្នែក ក៏គាត់ និងប្តីមិនអាចជួយឪពុកម្តាយ ហើយគាត់ក៏មិនអាចនិយាយទៅកាន់អ្នកទាំងនោះដែរ ។ គាត់ស្ទើរតែគ្មានព្រលឹងនៅពេលឃើញការចាប់នោះ ។ តែទោះបីបែបណា គាត់នៅតែទ្រាំរស់ ព្រោះតែមិនចង់ឲ្យកូនៗក្លាយជាក្មេងកំព្រា ពេលខ្លះត្រូវអត់បាយអត់ទឹកខ្លួនឯងដើម្បីទុកឲ្យកូនហូប ។ ក្រោយពេលបាត់ដំណឹងឪពុកម្តាយក្មេក គាត់ និងប្តី ត្រូវបានចាត់តាំងឲ្យដាំពោត និងត្រកួន តែគាត់ត្រូវយកទៅដាក់ក្នុងសហករណ៍រួមដើម្បីចែកគ្នា ។

នៅពេលនោះ គាត់បានឃើញអ្នកដែលខ្មែរក្រហមទើបជម្លៀសមកពីក្រុងភ្នំពេញជាច្រើននាក់ត្រូវធ្វើការងារធ្ងន់និងច្រើនម៉ោង ។ ដោយសារឃ្លានខ្លាំង មានប្រជាជនមួយចំនួនបានលួចរកក្តាម និងកំពឹសហូបក្នុងស្រែពេលកំពុងដកស្ទូង ។ មានប្រជាជនខ្លះបានមកសុំត្រកួនថែមទៀត ។ ដោយសារអាណិតខ្លាំង គាត់បានអនុញ្ញាតឲ្យបេះ តែត្រូវប្រយ័ត្នកុំឲ្យប្រធានកងឃើញ ។ អ្នកទាំងនោះបានយកត្រកួនដាក់ក្នុងអាវ ហើយសម្ងំហូបក្នុងស្រែ ។

ថ្ងៃមួយ នៅចុងឆ្នាំ១៩៧៨ យាយលាង មិនស្រួលខ្លួន ក៏សុំសម្រាកមួយថ្ងៃ តែកម្មាភិបាលខ្មែរក្រហមបីនាក់ឈ្មោះ ដាន, ចក់ និង មឹង បានបដិសេធ និងបានគំរាមថា បើមិនធ្វើការទេ នឹងវាយធ្វើទារុណកម្ម ។ ក្រោយខ្មែរក្រហមដួលរលំ អ្នកទាំងបីបានស្លាប់ដោយសារប្រជាជនសម្លាប់ ។ ប្រជាជនបានចាប់អ្នកទាំងបីនោះចង ហើយអាសាច់បន្តិចម្តងៗរហូតដល់ស្លាប់ ព្រោះអ្នកទាំងបីធ្លាប់បានយកធាងត្នោតអារកសម្លាប់មនុស្ស ។

ក្រោយឆ្នាំ១៩៧៩ កូនចិញ្ចឹមរបស់គាត់ម្នាក់ឈ្មោះ ស៊ួយ បានសុំទៅធ្វើការនៅភ្នំពេញ ដើម្បីយកលុយរៀនបន្ត ។ នៅក្នុងឆ្នាំ១៩៨០ គាត់ក៏ចេញពីស្អាង ខេត្តកំពង់ចាម ទៅរស់នៅខេត្តកំពង់ធំវិញ ដោយមិនបានផ្តល់ដំណឹងទៅ ស៊ួយ ឡើយ ។ ក្រោយពេលរៀនចប់ ស៊ួយ បានទៅតាមរកគាត់ដល់កំពង់ធំដោយពឹងពាក់អ្នកជិតខាងឲ្យជួយសើុបសួរដំណឹង ។ រហូតមកដល់ឆ្នាំ១៩៩៧ ដោយសារប្រកបរបរមិនសូវបានផល គាត់ក៏ផ្លាស់មករស់នៅអន្លង់វែង ហើយក៏បាត់ដំណឹងកូនចិញ្ចឹមរបស់គាត់មកដល់សព្វថ្ងៃ ។ **ឌួច ផានិត**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# អៀច រឿន : ការផ្សះផ្សា នៅក្នុងសហគមន៍ គឺការអត់ទោស

អន្លង់វែងគឺជាទីតាំងដែលខ្មែរក្រហម ធ្វើការកាន់កាប់នៅរយៈកាលចុងក្រោយនៃរបបខ្លួន ។ ជាជម្រើសដ៏ល្អរបស់មេដឹកនាំខ្មែរក្រហម ដែលបានរើសទីតាំងនេះ ដើម្បីឈរជើងតស៊ូជាមួយខ្មាំងសត្រូវ ព្រោះតំបន់នេះជាតំបន់ដាច់ស្រយាល ឆ្ងាយពីការគ្រប់គ្រងរបស់រដ្ឋាភិបាល និងជាពិសេសតំបន់នៅជាប់នឹងព្រំដែនថៃ ងាយស្រួលក្នុងការទំនាក់ទំនងកិច្ចការផ្សេងៗជាមួយប្រទេសជិតខាង ។

បច្ចុប្បន្នអន្លង់វែង ជាស្រុកមួយស្ថិតក្នុងខេត្តឧត្តរមានជ័យ ទោះបីជាតំបន់នេះនៅដាច់ស្រយាលក៏ដោយ តែយើងឃើញថា មានការអភិវឌ្ឍច្រើន ។ អន្លង់វែងបានបន្សល់ទុកនូវស្លាកស្នាមប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឲ្យយើងជាអ្នកជំនាន់ក្រោយអាចធ្វើការសិក្សាស្វែងយល់កាន់តែច្បាស់ និងចាត់ទុកជាឯកសារដើមសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ ។

របបកម្ពុជាប្រជាធិបតេយ្យ ឬស្គាល់ជាទូទៅថា របបខ្មែរក្រហម ជារបបមួយដែលបានធ្វើឲ្យប្រជាជនកម្ពុជាស្លាប់ត្រង់ជាងពីរលាននាក់បាត់បង់ជីវិត ដោយការអត់អាហារ ការបង្ខំឲ្យធ្វើការលើសកម្លាំង ជំងឺ និងការសម្លាប់ ។ ជាក់ស្ដែង អៀច រឿនគឺជាយុវជនម្នាក់ដែលត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើទ័ពបន្ទាប់ពីរបបមួយនេះជិតដួលរលំនៅចុងឆ្នាំ១៩៧៨ ។ គាត់មានស្រុកកំណើតនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ រឿន បានរៀបរាប់ថា នៅរបបខ្មែរក្រហមគាត់ត្រូវបានអង្គការចាត់តាំងឲ្យចូលកងចល័តយុវជន ដែលតម្រូវឲ្យលើកទំនប់ ជីកប្រឡាយ ធ្វើស្រែ និងធ្វើដី ។ រឿន ធ្វើកិច្ចការទាំងនេះ រហូតដល់ចុងឆ្នាំ១៩៧៨ ទើបត្រូវបានអង្គការបញ្ជូនឲ្យទៅធ្វើយោធាប្រយុទ្ធនឹងការឈ្លានពានរបស់កងទ័ពវៀតណាម ។ រឿន មិនហ៊ានបដិសេធទេ ព្រោះបើហ៊ានប្រឆាំងការចាត់តាំងរបស់អង្គការនឹងត្រូវកម្ទេចទាំងគ្រួសារមិនខាន ។

ក្រោយមានវត្តមានរបស់កងទ័ពវៀតណាមក្នុងប្រទេសកម្ពុជា រឿន និងក្រុមគ្រួសារ ព្រមទាំងអ្នកដទៃទៀត បាននាំគ្នារត់ចូលព្រៃ ។ រយៈពេលរស់នៅក្នុងព្រៃ ទាំងអស់គ្នាបានរស់នៅជាក្រុមតូចៗដែលមានចំនួនពី១០ទៅ២០នាក់ ហើយមានតែមើមក្ដួច មើមដំឡូងប៉ុណ្ណោះសម្រាប់ជាអាហារ ។ រឿន បានព្យាយាមស្វែងរកផ្លូវចេញពីព្រៃដើម្បីរកស្បៀងពីភូមិ ។ ប៉ុន្តែ រឿន ក៏ដូចជាអ្នកឯទៀត មិនហ៊ានចូលទៅក្នុងភូមិទេ ព្រោះខ្លាចវៀតណាមចាប់ ។ ខ្មែរក្រហមបានឃោសនាថា អ្នកណាហ៊ានចូលភូមិ វៀតណាមនឹងចាប់កាត់ក ដាក់ជាមិនខាន ។

រឿន បានរៀបការនៅក្នុងព្រៃជាមួយនារីឈ្មោះ ឡុង វិន ជាអ្នកស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដែលរត់ទៅព្រៃជាមួយគ្នា ។ ការរៀបការនេះ មិនមានពិធីអ្វីនោះទេ គឺគ្រាន់តែធ្វើការព្រមព្រៀងយកគ្នាជាប្ដីប្រពន្ធប៉ុណ្ណោះ ។ វិន បានឲ្យដឹងថា ការរស់នៅក្នុងព្រៃពិតជាពិបាកខ្លាំងណាស់ ហើយក្នុងចិត្តរបស់គាត់ពិតជាចង់ត្រឡប់ចូលភូមិវិញណាស់ ។ ថ្ងៃមួយ វិន ធ្លាក់ខ្លួនឈឺ ដោយសារនៅក្នុងព្រៃគ្មានថ្នាំសង្កូវ រឿន ក៏បានបបួលអ្នកឯទៀតចូលទៅភូមិក្នុងបំណងពីរ គឺរកថ្នាំព្យាបាលប្រពន្ធ និងចុះចូលជាមួយរដ្ឋាភិបាល ។ ដោយសារតែមានការខ្សឹបខ្សៀវពីផែនការនេះ ពីម្នាក់ទៅម្នាក់ បានធ្វើឲ្យបែកការណ៍ ។ តាម៉ុក ដែលជាអ្នកគ្រប់គ្រងនៅពេលនោះបានបញ្ជាឲ្យចាប់អ្នកដែលមានបំណងចុះចូលទាំងអស់ ដោយចោទថា ជាសាច់ហើម សាច់ស្អុយ ។ រឿន ត្រូវបានឃុំខ្លួននៅអូរកេងកងរហូតដល់ឆ្នាំ១៩៨១ រឿន និងអ្នកឯទៀតត្រូវបានដោះលែង ។ បន្ទាប់មក កងទ័ពទាំងអស់ក៏បានចេញពីព្រៃមករស់នៅជំរំនៅអូរត្រាវ ជិតព្រំដែនថៃ ។ លុះដល់ឆ្នាំ១៩៨៨ បន្ទាប់ពីសភាពការណ៍ស្ងប់ស្ងាត់ រឿន និងប្រពន្ធ បានចុះមករស់នៅអន្លង់វែង ។ រឿន បានចាប់ដីមួយកន្លែងដើម្បីសាងសង់ផ្ទះ ប៉ុន្តែការសាងសង់នេះមិនទាន់រួចស្រួលបួលផង រឿន និងគ្រួសារ ត្រូវរត់ទៅជំរំម្ដងទៀត ដោយសារកងទ័ពរដ្ឋាភិបាលមកវាយតំបន់អន្លង់វែង ដើម្បីបង្ខំឲ្យ

តាម៉ុក ចុះចាញ់ ។

ក្រោយសមាហរណកម្ម រឿន និងប្រពន្ធ បានត្រឡប់ពីជំរំមករស់នៅអន្លង់វែងជាលើកទីពីរ ។ រឿន បានចាប់ដី កាប់ឆ្ការ និងសាងសង់ផ្ទះជាថ្មី ។ រឿន បានចាប់ផ្តើមជីវិតជាថ្មីដោយបាទដៃទទេ ។ បច្ចុប្បន្ន រឿន មានកូនប្រុសស្រី៦នាក់ និងប្រកបរបរធ្វើស្រែចម្ការ ដើម្បីផ្គត់ផ្គង់ក្នុងជីវភាពគ្រួសារ ។

ជាចុងក្រោយ រឿន បានផ្តល់ទស្សនៈផ្ទាល់របស់គាត់ប្រាប់ខ្ញុំថា អ្នកដែលធ្លាប់រស់នៅ និងឆ្លងកាត់របបខ្មែរក្រហម គឺពិតជាទទួលរងទុក្ខ ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ។ ផ្លូវកាយ អាចនឹងព្យាបាលជាសះស្បើយ ដោយឱសថ ប៉ុន្តែផ្លូវចិត្ត ពិបាកនឹងរកវិធីរំងាប់ណាស់ លុះត្រាតែយើងស្វែងរកសេចក្តីសុខក្នុងចិត្តឲ្យឃើញ ពោល គឺការអត់ទោស ។ រឿន បានសង្កត់ធ្ងន់ថា ការអត់ទោស គឺជាវិធីផ្សះផ្សាមួយដ៏ល្អ ដែលដឹកនាំយើងឲ្យមានសន្តិភាពផ្លូវចិត្ត ។ មានវិធីជាច្រើនក្នុងការផ្សះផ្សា អ្នកខ្លះយល់ថា ការរស់នៅផ្សេងពីគ្នារវាងជនរងគ្រោះនិងជនដៃដល់ជាការប្រសើរ ហើយក៏មានអ្នកខ្លះយល់ថា ទោះបីជារស់នៅឆ្ងាយពីគ្នា បើមិនអត់ទោស និងនៅចងកំហឹងនឹងគ្នាទេ ក៏គ្មានសេចក្តីសុខដែរ ។

រឿន ក៏បានលើកយកទ្រឹស្តីព្រះពុទ្ធសាសនាដែលបានចែងថា "ផ្លូវដែលស្ងប់ជាផ្លូវដែលរំលត់ទុក្ខ" ។ ហេតុនេះ គាត់យល់ថា សាសនាក៏បានចូលរួមចំណែកមួយក្នុងការផ្សះផ្សាឲ្យមានសន្តិភាព និងសេចក្តីសុខសាន្តដែរ ។

**ឡឿន ស្រីភ័ស្ត្រ**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើបសហរដ្ឋអាមេរិក ប្រទេសអូទ្រីស បែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង អ៊ូច មករា តាមរយៈទូរស័ព្ទលេខ: ០ ១៧ ៦៦៥ ៦៧៥ ។ អ៊ីម៉ែល : truthmakara@dccam.org

គេហទំព័រ : www.ariverchangescourse.com





# អតីតយុទ្ធជនខ្មែរក្រហម

ស្ថិតក្នុងអាយុ៦១ឆ្នាំ បុរសវ័យចំណាស់ម្នាក់ដែលមានសម្បុរស្រអែមសណ្តែកបាយ ប្រមុះរាងស្រួចបន្តិច និងមានកម្ពស់ខ្ពស់ មានឈ្មោះថា គីម យ៉ាន ដែលធ្លាប់ជាយុទ្ធជននាសម័យកម្ពុជាប្រជាធិបតេយ្យ បាននិយាយបង្ហើបពីប្រវត្តិរូបសង្ខេប និងរៀបរាប់ពីដំណើរជីវិតដែលឥតកោះឥតគ្រើយក្រោមការដឹកនាំរបស់ ប៉ុល ពត ដែលធ្វើឲ្យគាត់មានឧបសគ្គយ៉ាងច្រើន និងរសាត់អណ្តែតដូចខាងក្រោមនេះ៖

គីម យ៉ាន មានស្រុកកំណើតនៅឃុំក្រយា ស្រុកស្ទោង ខេត្តកំពង់ធំ ។ ដោយសារមិនពេញចិត្តនឹងរបបដឹកនាំលន់ នល់ យ៉ាន ក៏បានសម្រេចចិត្តចូលរួមចលនាបដិវត្តន៍នៅស្រុកស្ទោងនាឆ្នាំ១៩៧២ ។ បន្ទាប់ពីនោះមក យ៉ាន បានចាកចេញពីស្រុកភូមិដើម្បីធ្វើដំណើរទៅប្រយុទ្ធនៅឯសមរភូមិនៅក្នុងខេត្តកំពង់ចាម ។ លុះក្រោយមកទៀត គាត់បានត្រឡប់ទៅឈរជើងនៅឯខេត្តកំពង់ធំដែលជាស្រុកកំណើតរបស់ខ្លួនវិញក្នុងអំឡុងឆ្នាំ១៩៧៤ ។ ឆ្នាំ១៩៧៥ យ៉ាន ត្រូវបញ្ជូនទៅភ្នំពេញដោយធ្វើជាពលទាហាននៃកងពលទី៣ ក្រោមការគ្រប់គ្រងរបស់ ឌឿន ជាមេកងពល ។ នាឆ្នាំដដែល យ៉ាន ត្រូវបានបញ្ជូនបន្តទៅខេត្តកំពង់សោមទៀត ។

នៅឆ្នាំ១៩៧៧ យ៉ាន បានផ្លាស់ទៅធ្វើការក្នុងទ័ពចល័តជាកម្មករលីសែងនៅឃ្លាំងរដ្ឋវិញ ។ ជាកម្មករលីសែង យ៉ាន ធ្វើការហត់លើសពីកម្លាំង ដោយលីសែងរបស់ធ្ងន់ៗ តែគាត់ទទួលបានអាហារគ្រប់គ្រាន់ គឺមួយថ្ងៃទទួលបានអាហារបីពេល ដែលមានតែសណ្តែកបាយចំហុយជំនួសបាយប៉ុណ្ណោះ ។

ទោះបីជា យ៉ាន ត្រឹមតែជាយុទ្ធជនធម្មតាមិនមែនជាកម្មាភិបាល ឬមានតំណែងធំក៏ពិតមែន ប៉ុន្តែគាត់បានអះអាងថា គាត់ធ្លាប់បានជួបផ្ទាល់ជាមួយ ប៉ុល ពត នៅក្នុងឱកាសដែល ប៉ុល ពត បានចុះសួរសុខទុក្ខ រួមទាំងចុះពិនិត្យស្ថានការណ៍តាមកងពលនីមួយៗចៀសវាងមានក្រុមក្បត់ ។ យ៉ាន បាននិយាយសរសើរពីបុគ្គលិកលក្ខណៈរបស់ ប៉ុល ពត ថាមានភាពរួសរាយ រាក់ទាក់ ចិត្តល្អ



រូបខាងឆ្វេង ៖ គីម យ៉ាន កំពុងកិនម្សៅនៅក្រោមផ្ទះរបស់គាត់ ស្ថិតនៅក្នុងឃុំថ្នាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានរៀបរាប់ពីប្រវត្តិរបស់គាត់ក្នុងសម័យខ្មែរក្រហម ប្រាប់ ដាវ៉ែន (រូបខាងស្តាំ) និស្សិតស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង



ដារ៉ែន (រូបទីពីររាប់ពីស្តាំ) ជាមួយក្រុមនិស្សិតស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ចុះទស្សនកិច្ចសិក្សានៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

និងគិតគូរដល់អ្នកក្រោមឱវាទដែលស្មោះស្ម័គ្រនឹងខ្លួន តែគាត់ក៏អាក្រក់ជាមួយអ្នកណាដែលមិនស្មោះនឹងគាត់ដែរ ។

ក្រោយរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ យ៉ាន បានគេចខ្លួនរត់ចូលព្រៃជាមួយនឹងខ្មែរក្រហមដទៃទៀត ។ គួរបញ្ជាក់ដែរថា នៅពេលប្រយុទ្ធជាមួយកងទ័ពរណសិរ្សសង្គ្រោះជាតិ យ៉ាន បានរបួសគ្រាប់ធ្វើឲ្យគាត់ពិការភ្នែករហូតដល់បច្ចុប្បន្ន ។ គាត់បានតស៊ូរស់នៅក្នុងព្រៃយ៉ាងលំបាក ខ្វះអាហារ ជួនកាលមានហូបព្រឹកខ្វះល្ងាច ទៀតផង ។ រហូតដល់ឆ្នាំ១៩៨២ យ៉ាន បានរត់មកដល់តំបន់មុំ៣ លើភ្នំ១០០១ ដែលស្ថិតនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅទៅទីនោះ គាត់បានជួបនឹងនារីម្នាក់ដែលធ្វើឲ្យគាត់ចាប់ចិត្តស្រឡាញ់ ហើយក៏បានក្លាជាប្តីប្រពន្ធរហូតដល់បច្ចុប្បន្ន ។

មួយរយៈក្រោយ បន្ទាប់ពីរៀបការរួច យ៉ាន និងប្រពន្ធបានផ្លាស់ប្តូរទៅរស់នៅ និងធ្វើជាទាហាននៅឯខេត្តប៉ៃលិន ។ ក្រោយមកទៀត គាត់បន្តទៅឈរជើងនៅខេត្តបាត់ដំបង ស្ថិតនៅជាប់ព្រំប្រទល់ថៃវិញ ។

នៅទីនោះ(បាត់ដំបង) យ៉ាន បានជួបយាយម្នាក់ដែលវង្វេងបាត់កូន បងប្អូន ហើយរស់នៅតែម្នាក់ឯង យ៉ាន ក៏បានយកគាត់មករស់នៅជាមួយ ។ យាយបានរស់នៅជាមួយគាត់បានមួយរយៈ ក៏ត្រូវបានសាច់ញាតិតាមរកឃើញ និងបានសុំយាយយកទៅវិញ ។

នៅឆ្នាំ១៩៩៣ គាត់បានទៅរស់នៅភូមិអូររុន ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យរហូតមកដល់សព្វថ្ងៃ ។ យើងអាចនិយាយបានថាទីនោះ គឺជាកោះត្រើយសុខសាន្តនៃជីវិតរបស់គាត់ បន្ទាប់ពីជីវិតរបស់គាត់រសាត់អណ្តែតអស់រយៈពេលជាង១ទសវត្សរ៍មក ។ ទាំងនេះគឺជាដំណើរផ្សងព្រេងរបស់ យ៉ាន ក្នុងនាមជាយុទ្ធជនខ្មែរក្រហមអស់រយៈពេលជិត២ទសវត្សរ៍ ។ ដោយឡែកកាលពីពេលថ្មីៗនេះ យ៉ាន ក៏បានធ្វើដំណើរទៅលេងឪពុកម្តាយបងប្អូនរបស់គាត់នៅឯស្រុកកំណើត ដោយមានសេចក្តីនឹករឭកសាច់ញាតិខ្លាំងពេក ។ នៅពេលទៅដល់ គាត់សង្កេតឃើញថា មិនមានអ្នកភូមិណារើសអើង ឌឺងសម្បារ ឬគុំគួននឹងរូបគាត់ ដោយសារតែអតីតភាពរបស់គាត់នោះទេ ។ ផ្ទុយទៅវិញ អ្នកស្រុក អ្នកភូមិមានភាពរួសរាយរាក់ទាក់ និងរាប់រកគាត់ធម្មតា ។

ក៏ប៉ុន្តែនៅពេលដែលសួរគាត់ថា "តើលោកពូយល់យ៉ាងណាចំពោះការផ្សះផ្សារវាងជនរងគ្រោះ និងអតីតខ្មែរក្រហមដទៃទៀត? យ៉ាន ឆ្លើយថា គាត់នឹងបកស្រាយពន្យល់ពីមូលហេតុថា ហេតុអ្វីបានជាពួកគាត់ធ្វើយ៉ាងនេះ ប្រាប់ដល់ប្រជាជន ។ ការធ្វើបែបនេះ អាចធ្វើឲ្យជនរងគ្រោះអាចស្ងប់ចិត្ត ឬអាចថាមានសន្តិភាពផ្លូវចិត្តដោយបំបាត់មន្ទិលសង្ស័យរបស់ខ្លួន ។

**សែម ដារ៉ែន**

# ដៃ នន និងការបង្ខំឱ្យធ្វើជាយោធា

ការធ្វើដំណើរដ៏វែងឆ្ងាយឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយ មើលទៅតាមដងផ្លូវ ឃើញព្រៃភ្នំក្រំថ្ម និងវាលស្រែល្វឹងល្វើយ ធ្វើឲ្យខ្ញុំនឹករលឹកដល់ស្រុកកំណើតជាខ្លាំង ។ អ្វីដែលធ្វើឲ្យនឹកគិតនៅពេលនេះ គឺខ្ញុំគិតពីតំបន់អន្លង់វែងដែលខ្ញុំកំពុងតែធ្វើដំណើរទៅជាមួយនឹងក្រុមនិស្សិតមួយចំនួនទៀតក្នុងដំណើរទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ដែលរៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ អន្លង់វែង ជាតំបន់មួយដែលដាច់ស្រយាលមួយ ហើយក៏ជាតំបន់តស៊ូចុងក្រោយរបស់របបខ្មែរក្រហមដែរ ដូច្នេះហើយខ្ញុំតែងតែគិតពីទិដ្ឋភាពនៅតំបន់នោះ មុនពេលដែលខ្ញុំបានទៅដល់ ។ ខ្ញុំគិតថាប្រជាជនដែលនៅអន្លង់វែងប្រហែលជាជួបការលំបាកខ្លាំង ។

ប៉ុន្តែផ្ទុយទៅវិញអ្វីដែលខ្ញុំបានត្រឹមតែគិតនោះ គឺវាខុសស្រឡះ ព្រោះនៅពេលខ្ញុំបានទៅដល់ស្រុកអន្លង់វែង នោះអ្វីៗផ្ទុយពីការគិតរបស់ខ្ញុំ ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ និងក្រោយការធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ជីវភាពរបស់ប្រជាជននៅតាមតំបន់នេះ គឺមានសភាពធូរធារ ទាំងស្ថានភាពគ្រួសារ ក៏ដូចជាមុខរបរប្រចាំថ្ងៃ ។

បន្ទាប់ពីបានធ្វើដំណើរឆ្លងកាត់តាមភូមិឃុំជាច្រើនមក ខ្ញុំបានចូលទៅសាលារៀន និងអតីតមន្ទីរពេទ្យចាស់ ដែលបានបន្សល់ទុកពីរបបគ្រប់គ្រងរបស់ តាម៉ុក ។ ក្រោយមកទៀតខ្ញុំបានធ្វើដំណើរឆ្លងកាត់បឹងតាម៉ុក ហើយបានធ្វើដំណើរឡើងលើភ្នំដងរែកដែលជាកន្លែងបញ្ជាការរបស់ តាម៉ុក ។

ក្នុងដំណើរទស្សនកិច្ចសិក្សានេះ ក្រៅពីខ្ញុំបានទៅទស្សនាតំបន់ប្រវត្តិសាស្ត្រ ខ្ញុំក៏មានឱកាសសម្ភាសផ្ទាល់ជាមួយអតីតយោធាខ្មែរក្រហម ពីបទពិសោធន៍ជីវិតរបស់អ្នកទាំងនោះ ដែលធ្លាប់បានឆ្លងកាត់ ។ កំពុងតែមមាញឹកនឹងកិច្ចការផ្ទះ អ៊ំប្រុសញញឹមមកកាន់ខ្ញុំដោយក្តីរាក់ទាក់ និងបានអញ្ជើញខ្ញុំឲ្យអង្គុយលេង ។ គាត់ឈ្មោះ ដៃ នន ជាប្រជាជនរស់នៅឃុំថ្លាត ស្រុកអន្លង់វែង ។ ផ្អាកការងារផ្ទះ មកអង្គុយសំណេះសំណាលជាមួយខ្ញុំ នន បាន



រូបទីពីររាប់ពីឆ្វេង ៖ គន្ធា ជួបសម្ភាសជាមួយ ដៃ នន (រូបទីពីររាប់ពីស្តាំ) នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ



គន្ធា (ជួរខាងមុខ រូបទីពីររាប់ពីស្តាំ) ជាមួយនឹងក្រុមនិស្សិតស្ម័គ្រចិត្ត នៅមុខការិយាល័យ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅលើភ្នំដងរែក

ប្រាប់ថា គាត់មានស្រុកកំណើតនៅឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។ គាត់ និងគ្រួសារបានផ្លាស់មករស់នៅអន្លង់វែង បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ។

និយាយដល់របបខ្មែរក្រហម ខ្ញុំបានសួរគាត់ពីបទពិសោធន៍ជីវិតរបស់គាត់ដែលធ្លាប់បានឆ្លងកាត់ពីរបបមួយនេះ ។ នន បានរម្លឹកថា គាត់បានបែកពីប្រពន្ធ និងគ្រួសារចាប់តាំងពីឆ្នាំ១៩៧២ មកម្ល៉េះ ។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់ព្រះនរោត្តម សីហនុឆ្នាំ១៩៧០ ខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិស្រុកដែល នន រស់នៅ និងបានចាប់បង្ខំយុវជន យុវនារីឲ្យចូលធ្វើទ័ព ក្នុងនោះក៏មានគាត់ម្នាក់ដែរ ។

ក្រោយឆ្នាំ១៩៧២ នន បានទៅប្រយុទ្ធនៅសមរភូមិជាបន្តបន្ទាប់ និងមិនសូវបានត្រឡប់មកជួបប្រពន្ធ និងគ្រួសារទេ ។ ប្រសិនបើចង់ជួបប្រពន្ធ គឺត្រូវសរសេរសំបុត្រផ្ញើតាមអ្នកដែលត្រូវត្រឡប់មកភូមិ ទើបប្រពន្ធរបស់គាត់ទៅជួបបាន ។ បន្ទាប់ពីជ័យជម្នះទូទាំងប្រទេស កងរបស់ នន ត្រូវអង្គការបញ្ជាឲ្យទៅឈរជើងការពារតាមព្រំដែន ។ ជីវិតជាយុទ្ធជនរបស់គាត់ ពិតជាលំបាកខ្លាំងណាស់ ។ ក្រៅពីការពារ គាត់ត្រូវធ្វើស្រែ គាស់គល់ឈើ ធ្វើជីដាក់ស្រែ មិនមានពេលទំនេរនោះទេ ហើយរបបអាហារក៏មិនសូវគ្រប់គ្រាន់ដែរ ។ ម្នាក់ៗ បានរបបបាយដាំលាយពោតមួយចានចង្កឹះក្នុងមួយពេល ។ លើសពីនេះទៀត សមាជិកកងរបស់គាត់ម្នាក់ៗ ត្រូវបិតចម្រូងឲ្យបានម្នាក់ៗ៥០០ចម្រូង ។ តែប្រសិនបើធ្វើមិនគ្រប់ផែនការថ្នាក់លើនឹងហៅទៅស្តីបន្ទោសមិនខាន ។

នន បានធ្វើការតស៊ូជាមួយបដិវត្តន៍រហូតដល់ចលនាមួយនេះ ត្រូវបានដួលរលំនៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ។ ពេលនោះ នន បានជួបជាមួយប្រពន្ធ ហើយបានភៀសខ្លួនមកដល់អន្លង់វែង ។ មួយរយៈក្រោយ អន្លង់វែងមានការប្រយុទ្ធជាញឹកញាប់រវាងខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាល ។ ហេតុនេះហើយ នន និងប្រពន្ធ បាននាំគ្នាភៀសខ្លួនទៅនៅជំរំភូណយ ក្នុងទឹកដីថៃបន្តទៀត ។ ប៉ុន្មានឆ្នាំក្រោយមក ស្ថានការណ៍នៅអន្លង់វែងមានសភាពស្ងប់ស្ងាត់ នន និងប្រពន្ធ បានត្រឡប់ពីជំរំភូណយ មករស់នៅអន្លង់វែងវិញ ។

ប្រាប់ខ្ញុំបន្តលាយឡំដោយសំណើចថា ការមករស់នៅអន្លង់វែងដែលគ្រប់គ្រងដោយ តាម៉ុក នៅពេលនោះ គឺគ្រាន់បើជាងពេលដែលគាត់ធ្វើជាយោធា ។ គ្រួសាររបស់គាត់ ក៏ដូចជាប្រជាជនដទៃទៀត ទទួលការផ្គត់ផ្គង់គ្រប់គ្រាន់ពី តាម៉ុក ។ ក្រោយសមាហរណកម្ម តំបន់អន្លង់វែងមានសុខសន្តិភាពពេញលេញ ហើយក៏មានអ្នកចំណូលថ្មីមករស់នៅ និងរកស៊ីយ៉ាងច្រើនកុះករ ។ អន្លង់វែងលែងជាតំបន់ដាច់ស្រយាល និងស្ងប់ស្ងាត់ទៀតហើយ ។ ចំពោះ នន ផ្ទាល់ពិតជាពេញចិត្តនឹងការរស់នៅសព្វថ្ងៃណាស់ ហើយគាត់ក៏មិនចង់ទៅរស់នៅស្រុកកំណើតគាត់ដែរ ព្រោះគាត់យល់ថា អន្លង់វែងរស់នៅសុខស្រួលណាស់ ។

សព្វថ្ងៃ នន និងប្រពន្ធ លឹម គឹម រស់នៅដោយក្តីរីករាយជាមួយនឹងកូនប្រុសស្រី៨នាក់ ។ ទោះជាយ៉ាងណាក៏ដោយ នន ជារឿយៗតែងតែលើកយកបទពិសោធន៍ជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហម និងក្រោយរបបនេះប្រាប់ដល់កូនៗគាត់ជានិច្ច ។ គាត់ចង់ឲ្យកូនៗរបស់គាត់ដែលជាក្មេងជំនាន់ក្រោយបានយល់ និងដឹងពីប្រវត្តិសាស្ត្រដ៏ជូរចត់មួយនេះ និងផលវិបាកនៃសង្គ្រាមផង ។

**មាឃ គន្ធា**

# ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្ម អំពីការបាត់បង់សមាជិកគ្រួសារ

ថ្ងៃនេះ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីនាក់ លើកឡើងពីជីវិតរបស់ខ្លួននៅចំពោះមុខតុលាការ មានម្នាក់ក្នុងចំណោមអ្នកទាំងបី បានផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោទស្សន៍ពីប្រទេសបារាំង ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីនាក់ ប្រាប់តុលាការអំពីការរងទុក្ខវេទនា ដែលខ្លួនបានទទួលនៅក្នុងរបបខ្មែរក្រហម ដែលមានការទាក់ទងនឹងសំណុំរឿង០០២ ។ សក្ខីកម្មដែលត្រូវផ្តល់នៅសវនាការពេលនេះ គឺអំពីការបាត់បង់សមាជិកគ្រួសារដែលទាក់ទងទៅនឹងមន្ទីរសន្តិសុខ និងការបោសសំអាតផ្ទៃក្នុង ។

***ដើមបណ្តឹងរដ្ឋប្បវេណីទី១ ផៃ ហ៊ាប***


ដើមបណ្តឹងរដ្ឋប្បវេណីទី១ ផៃ ហ៊ាប

លោកចៅក្រម យ៉ា សុខន ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា គ្រប់ភាគីទាំងអស់មានវត្តមាន ដោយឡែក នួន ជា មានវត្តមាននៅក្នុងបន្ទប់ខាងក្រោមសាលសវនាការ ។ ប្រធានអង្គជំនុំជម្រះ និល ណុន នៅតែអវត្តមាន និងត្រូវបានជំនួសដោយលោកចៅក្រម យ៉ា សុខន បន្តដឹកនាំសវនាការ ។ លោកចៅក្រមបានប្រកាសថា នៅថ្ងៃនេះ និងថ្ងៃចន្ទ ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវមកផ្តល់សក្ខីកម្មអំពីទុក្ខសោកវេទនា និងស្ថានភាពដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ដែលទាក់ទងទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល, មន្ទីរសន្តិសុខអូរកន្សែង, គុកទួលស្លែង និងការបោសសំអាតផ្ទៃក្នុង (2-TCCP- 275; 2- TCCP-1047 2-TCCP-1049) ឲ្យតាមរយៈប្រព័ន្ធសោទស្សពីប្រទេសបារាំង) ។ នៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការលើឯកសារគន្លឹះ ដែលដាក់ដោយសហព្រះរាជអាជ្ញា ហើយការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបន្តនៅថ្ងៃចន្ទ ។


ប្រធានអង្គជំនុំជម្រះ យ៉ា សុខន

លោកប្រធានអង្គជំនុំជម្រះ យ៉ា សុខន បានរំឭកដល់ភាគីទាំងអស់ថា ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី គួរតែមានការទាក់ទងនឹងសេចក្តីថ្លែងការណ៍ទូទៅនៃគ្រោះថ្នាក់ ការរងទុក្ខវេទនា និងគួរតែមានការទាក់ទងនឹងការពិតនៅក្នុងសំណុំរឿង០០២ វគ្គ០២នេះ តែថានឹងមិនបង្កើតនូវការរំលោភសិទ្ធិក្នុងការកាត់សេចក្តីដោយត្រឹមត្រូវ ប្រសិនបើសេចក្តីថ្លែងការណ៍នេះបានហួសវិសាលភាពនៃការជំនុំជម្រះនៅក្នុងផ្នែកនេះ ហើយក៏គ្មានឱកាសដើម្បីបដិសេធ ។


សហមេធាវីជាតិនាំមុខដើមបណ្តឹង ពេជ្រ អង្គ

លោក ពេជ្រ អង្គ សហមេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បានស្វែងរកការបំភ្លឺអំពីការផ្តល់សក្ខីកម្មនេះ ដោយលើកឡើងថា អ្វីដែលគាត់បានដឹងគឺ ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុនៅក្នុងសំណុំរឿង០០២ទាំងមូល និងផ្តោតជាពិសេសទៅលើសំណុំរឿង០០២វគ្គ០២, ខណៈពេលការពន្យល់របស់លោកប្រធានអង្គជំនុំជម្រះ យ៉ា សុខន ហាក់ដូចជាបង្ហាញថា មានតែការពិតដែលទាក់ទងសំណុំរឿង០០២ វគ្គ០២ នឹងត្រូវបានទទួលយក ។ លោកប្រធានអង្គជំនុំជម្រះ យ៉ា សុខន បានរំឭកពីអង្គហេតុដែលទាក់ទងនឹងសំណុំរឿងនេះជាទូទៅ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ផៃ ហ៊ាប កើតនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៦១ មានស្រុកកំណើតនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ លោកប្រធានអង្គជំនុំជម្រះ សុខន បានប្រាប់ ផៃ ហ៊ាប ថា គាត់អាចធ្វើឲ្យសេចក្តីថ្លែងការណ៍ទាក់ទងនឹងផលប៉ះពាល់រាងកាយ ផ្លូវចិត្ត និងផ្នែកសម្ភារ ដែលជាលទ្ធផលផ្ទាល់របស់បទឧក្រិដ្ឋ ដែលគាត់ធ្លាប់បានឆ្លងកាត់កន្លងមក ។


មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហុន គីមសួន

ហុន គីមសួន មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានចោទសំណួរមួយចំនួនជីវប្រវត្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ផៃ ហ៊ាប រស់នៅក្នុងភូមិដែលគ្រប់គ្រងដោយខ្មែរក្រហម ស្ថិតនៅខេត្តកំពង់ធំ មុនពេលការដួលរលំទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ ។ ផៃ ហ៊ាប មានបងប្អូនបង្កើត៨នាក់ (ស្រី៤នាក់ និងប្រុស៤នាក់) ។ បន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញ ហ៊ាប ត្រូវបានខ្មែរក្រហមបញ្ជូនទៅរស់នៅស្រុកកំណើតរបស់ខ្លួនវិញ ប៉ុន្តែបងប្អូនរបស់ ហ៊ាប មិនបានត្រឡប់មកទាំងអស់ទេ ។ បងប្អូនចំនួនបីនាក់របស់ ហ៊ាប បានចូលរួមតស៊ូចលនាជាមួយខ្មែរក្រហម ។ "បងប្អូនរបស់ ផៃ ហ៊ាប ចំនួន៤នាក់ បានបាត់ខ្លួន រួមទាំងបងប្រុសថ្លៃផង" ។ បងប្អូនដែលបាត់ខ្លួននោះមានឈ្មោះដូចជា ផៃ ហេង និងប្រពន្ធរបស់គាត់, ហ៊ុល ណុង, ផៃ ទូច និង ផៃ ម៉ុន ។

### ផៃ ហេង

លោក ហុន គីមសួន មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចង់ដឹងពីកន្លែងដែល ផៃ ហេង រស់នៅក្រោយឆ្នាំ១៩៧៥ ។ ផៃ ហ៊ាប បានឆ្លើយថា ក្រោយឆ្នាំ១៩៧៥ ហេង មករស់នៅក្នុងក្រុងភ្នំពេញ ជាសមាជិកនៅក្នុងកងពល៣១០ ។ ហេង ធ្លាប់បានទៅលេងស្រុកកំណើត នៅពេលភ្នំពេញបានដួលរលំ ។ ផៃ ហេង បានរៀបការ និងវិលត្រឡប់ទៅភូមិកំណើត ដើម្បីយកប្អូនប្រុសរបស់គាត់ម្នាក់ទៅរស់នៅក្នុងកងកុមារនៅទីក្រុងភ្នំពេញ ។ ពេលទៅលេងស្រុកកំណើតជាលើកទី៣ ហេង បានយក ខ្ញុំ (ហ៊ាប) ទៅដាក់នៅកងកុមារ នៅក្នុងកងពល៣១០ដែរ ។ កងពល៣១០នេះ ជាផ្នែកមួយនៃកងទ័ពមជ្ឈិម និងឈរជើងនៅខេត្តកំពង់ស្ពឺ ។ បងប្អូនពីរនាក់របស់ ហ៊ាប ដែលបាត់ខ្លួនមានឈ្មោះ ផៃ ទូច ហៅ ហ៊ាង និងផៃ ម៉ុន ។ ផៃ ទូច បានចូលធ្វើការនៅកងវរសេនាតូចដឹកជញ្ជូនកងពល៣១០ ។ ឪពុករបស់ ហ៊ាប បានប្រាប់គាត់ថា បងប្រុសរបស់គាត់ឈ្មោះ ផៃ ហេង បានចូលរួមចលនាបដិវត្តន៍នៅឆ្នាំ១៩៧០ ។

ផៃ ហ៊ាប មករស់នៅទីកន្លែងផ្សេងៗពីគ្នានៅភ្នំពេញ ប៉ុន្តែកន្លែងដែលគាត់រស់នៅបានយូរជាងគេ គឺនៅក្បែរមន្ទីរពេទ្យកាល់ម៉ែតនៅជិតវត្តស្រះចក ។ នៅពេលនោះ ហ៊ាប មិនបានរស់នៅជាមួយបងប្រុសរបស់គាត់ទេ ដោយសារគាត់ត្រូវទៅរស់នៅក្នុងកងកុមារ ។

ចំពោះការងារប្រចាំថ្ងៃរបស់បងប្រុស ផៃ ហ៊ាប បានលើកឡើងថា គាត់បានឃើញបងប្រុសរបស់គាត់ប្រើប្រាស់ម៉ាស៊ីនវាយអង្គុលីលេខនៅក្នុងការិយាល័យ ។ "ហ៊ាប បានឃើញសៀវភៅជាច្រើននៅក្នុងការិយាល័យរបស់បងប្រុស" ។ លើសពីនេះទៅទៀត ផៃ ហ៊ាប ក៏ចាំបានថា បងប្រុសរបស់គាត់មានកាំភ្លើងខ្លីមួយដើមទៀតផង ។

បងប្រុសរបស់ ផៃ ហ៊ាប ឈ្មោះ ផៃ ទូច ហៅ ហ៊ាង បានប្រាប់ឲ្យបងប្រុសម្នាក់ទៀតឈ្មោះ ផៃ ម៉ុន "ឲ្យត្រឡប់ទៅផ្ទះវិញ" ។ ហ៊ាប បានឃើញបងប្រុសរបស់គាត់កំពុងវាយអង្គុលីលេខ ។ ក្រោយមក តា ហ៊ិន បានប្រាប់ ហ៊ាប ថា បងប្រុសរបស់គាត់បានបាត់ខ្លួនហើយ ។ មានបុរសម្នាក់ផ្សេងទៀតបានឃើញ ហ៊ាប ដោយបានចង្អុល និងនិយាយថា អូ! នេះជាប្អូនប្រុសរបស់អាក្បត់ ។

ដូច្នេះ ផៃ ហ៊ាប បានព្យាយាមលាក់ប្រវត្តិរបស់ខ្លួន រហូតដល់ពេលដែលអង្គការចាប់ផ្តើមធ្វើប្រវត្តិរូបថ្មី ។ ប៉ុន្តែ ផៃ ហ៊ាប បានព្យាយាមលាក់ពីទំនាក់ទំនងរបស់គាត់ជាមួយបងប្រុសចាប់តាំងពីខ្មែរក្រហមដឹងថា គាត់មានបងប្រុសជាជនក្បត់ ។ ក្មេងៗមួយចំនួននៅក្នុងកងពល៣១០ បានបាត់ខ្លួន ។ នៅពេលដែល ហ៊ាប ស្វែងរកបងប្រុស គាត់មិនបានឃើញបងប្រុសរបស់គាត់ទេ ។ សូម្បីតែបន្ទប់របស់បងប្រុសរបស់គាត់ ក៏ត្រូវបានបិទ និងបានចាក់សោដែរ ។

តា ហ៊ិន បានប្រាប់ ហ៊ាប ថា បងប្រុសរបស់គាត់ បានឡើងឡានទៅបាត់ហើយ ដែលមាន តា ហាវ ជាតៃកុងឡាន ។ នៅពេល

ឡានឈប់ចាក់សាំង តា ហ៊ិន បានជួបបងប្រុសរបស់ ហ៊ាប និងបានផ្ដែផ្ដាំ តា ហ៊ិន ឲ្យជួយមើលថែរក្សាក្រុមគ្រួសាររបស់គាត់ផង ។ តា ហ៊ិន បានប្រាប់ ហ៊ាប ថា តា ហ៊ួរ និងតា វឿង ជាអនុប្រធានកងពល ក៏ត្រូវបានចាប់ខ្លួនដូចបងប្រុសរបស់គាត់ដែរ ។

ឆែ ហ៊ាប ត្រូវបានអង្គការស្នើសុំឲ្យចូលរួមកិច្ចប្រជុំនៅឆ្នាំ ១៩៧៥ ។ តា ហ៊ិន និយាយប្រាប់ថា បងប្រុសរបស់ ហ៊ាប ត្រូវបានយកទៅទិសខាងត្បូង ហើយបានបញ្ជាក់ទៀតថា អ្នកដែលត្រូវបានយកទៅទិសខាងត្បូង មិនដែលត្រឡប់មកវិញទេ ។

ឆែ ហ៊ាប បានលើកឡើងថា មានឯកសារនៅក្នុងគុកទួលស្លែង ។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាតិ ហុង គឹមសួន បានបង្ហាញរូបថតអ្នកទោសឈ្មោះ ឆែ ហេង ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ។ ដោយមានកំហុសបច្ចេកទេស ដូច្នេះរូបថតមិនអាចបង្ហាញនៅលើកញ្ចក់កុំព្យូទ័របានទេ ។

ឆែ ហ៊ាប បានរំពឹកថា គាត់បានឮដំណឹងបងប្រុសរបស់គាត់តាមរយៈការផ្សាយវិទ្យុ ប៉ុន្ដែគាត់មិនមានថវិកាគ្រប់គ្រាន់ ដើម្បីធ្វើដំណើរមកទីក្រុងភ្នំពេញ ។ ក្រោយមក មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) បានយករូបថតបងប្រុសរបស់គាត់ ទៅសួរនាំអ្នកភូមិ ។ នៅពេលឃើញរូបថត ហ៊ាប បានយំពេញមួយថ្ងៃ ដោយសារតែ ហ៊ាប បានឃើញរូបថតបងប្រុសឈ្មោះ ឆែ ហេង មានសភាពស្គមស្គាំង ។ ហ៊ាប បានប្រាប់ឲ្យដឹងថាបងប្រុសរបស់គាត់ បានទទួលរងទុក្ខជាច្រើន ។ បន្ទាប់មក រូបថតត្រូវបានចាក់បង្ហាញទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី និងត្រូវបានបញ្ជាក់ថា រូបថតនេះ ពិតជារូបបងប្រុសរបស់គាត់ ។

## ប្រពន្ធ និងកូន របស់ ឆែ ហេង

ប្រពន្ធរបស់ ហេង ធ្វើការក្នុងកងកាត់ដេរនៅម្ដុំទួលគោក ។ តា ហ៊ិន បានប្រាប់ ហ៊ាប ថានៅពេលទៅដឹកសំណាប គាត់បានឃើញប្រពន្ធរបស់ ហេង និងប្រពន្ធរបស់កម្មាភិបាលផ្សេងទៀត ត្រូវបានដឹកតាមឡានយកទៅដាក់នៅក្នុងវត្ត ។ ហ៊ាប បានឲ្យដឹងថា តា ហ៊ិន នៅរស់សព្វថ្ងៃនេះ ។ តាមរយៈអ្វីដែល តា ហ៊ិន បានប្រាប់គឺ ប្រពន្ធ និងកូនរបស់ ឆែ ហេង ត្រូវបានចាប់ខ្លួន បន្ទាប់ពីមានការចាប់ខ្លួន ឆែ ហេង ។ តា ហ៊ិន បានប្រាប់ ហ៊ាប ថា នៅពេលមានប្ដីក្បត់ ប្រពន្ធ និងកូន ក៏ត្រូវចាប់ខ្លួនដែរ ។ បងប្រុសរបស់ ហ៊ាប មានកូនស្រីម្នាក់ និងកូនក្នុងផ្ទៃម្នាក់ទៀត ។ ហ៊ាប មិនដែលទទួលបានដំណឹងអ្វីសោះពីគ្រួសារបងប្រុស សូម្បីតែនៅពេលត្រឡប់ទៅស្រុកកំណើតនៅខេត្តកំពង់ចាម ក៏មិនឃើញដែរ ។

## ឆែ ទូច និង ឆែ ម៉ុន

កាលពីដើម ហ៊ាប នៅកងកុមារជាមួយ ឆែ ទូច និង ឆែ ម៉ុន ។ ប្រុស និងស្រី ត្រូវរស់នៅផ្សេងពីគ្នា ។ ឆែ ទូច និង ហ៊ាប ដំបូងឡើយរស់នៅជាមួយគ្នារហូត ។ ទូច និង ហ៊ាប ត្រូវបានសួរនាំអំពីប្រវត្តិរូប ។ ហ៊ាប បានប្រាប់កម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ ដា ថា ខ្លួនមិនដែលធ្វើជាកងទ័ព ឬប៉ូលីសទេ ។

ក្រោយមក ប្អូនប្រុសឈ្មោះ ឆែ ទូច ត្រូវបានយកចេញទៅឆ្ងាយ ។ ក្រោយមកទៀត ត្រូវបានអង្គការពីទំនាក់ទំនងរបស់គាត់និងឆែ ទូច ហើយគាត់ឆ្លើយថា គាត់មិនមែនជាប្អូនរបស់ ឆែ ទូច ទេ គឺគ្រាន់តែជាបងប្អូនជីដូនមួយប៉ុណ្ណោះ ។ ពីរបីថ្ងៃក្រោយមក ហ៊ាប ត្រូវបានអង្គការហៅឲ្យទៅប្រជុំជួរដែលមានគ្នា១៧នាក់ នៅក្នុងកង ។ អ្នកណាឮឈ្មោះចេញមកក្រៅជួរ ហើយអ្នកដែលអត់ឮឈ្មោះត្រូវនៅក្នុងអង្គភាព ។ ហ៊ាប បានបញ្ជាក់ថាបងប្រុសឈ្មោះ ឆែ ទូច ត្រូវបានចាប់ខ្លួនយកទៅបាត់មែន ។ ប្អូនស្រីរបស់គាត់ឈ្មោះ ឆែ ម៉ុន គឺនៅកងកុមារនៅក្នុងកងពល ។ បន្ទាប់ពីរដូវដាំដុះស្រូវ គាត់បានវិលត្រឡប់ទៅនៅកងកុមារវិញ ខណៈពេលប្អូនរបស់គាត់ឈ្មោះ ឆែ ទូច ត្រូវបានបញ្ជូនទៅឆ្ងាយ ។ រឿងនេះបានកើតឡើងប្រហែលជានៅក្នុងឆ្នាំ១៩៧៨ ។

ឆែ ទូច រស់នៅជាមួយ ហ៊ាប នៅពេលគាត់ត្រូវបានចាប់ខ្លួន ។ ហ៊ាប ត្រូវបានបញ្ជូនទៅកន្លែងផ្សេងទៀត ដែលមានទីតាំងស្ថិតនៅជិត ឆែ ម៉ុន ។ ហ៊ាប បានជួយលាងរបួសឲ្យកងទ័ព ដែលបញ្ជូនមកពីសមរភូមិខេត្តកំពង់ចាម ។

សរុបមក បងប្អូនចំនួន៥នាក់បានបាត់ខ្លួនមានឈ្មោះ ឆែ ហេង និងប្រពន្ធរបស់គាត់, ហុល ណុង, ឆែ ទូច និង ឆែ ម៉ុន ហើយគ្មាននរណាម្នាក់វិលត្រឡប់មកវិញទេ រួមទាំងក្មួយប្រុស និងបងប្អូនជីដូនមួយផង ។

ខ្ញុំមានអារម្មណ៍ ក្ដុកក្ដួលអាណិតដល់បងប្អូនទាំងអស់ ហើយនេះជាមូលហេតុដែលខ្ញុំបានមកទីនេះដើម្បីផ្ដល់សក្ខីកម្មអំពីផលប៉ះពាល់ និងការទទួលរងទុក្ខរបស់ក្រុមគ្រួសារខ្ញុំដែរ

ហ៊ាប មកផ្ដល់សក្ខីកម្មនៅក្នុងតុលាការ ដោយសារតែបងប្រុសរបស់គាត់បានខិតខំតស៊ូជាមួយខ្មែរក្រហម តែបែរជាត្រូវចាប់ខ្លួន និងយកទៅសម្លាប់ទៅវិញ ។ នេះជាការមិនត្រឹមត្រូវទេ សម្រាប់គាត់ ព្រោះអ្នកទាំងនោះបានចូលរួមចំណែក និងខិតខំប្រឹងប្រែងក្នុងការធ្វើចលនាតស៊ូ

ដើមបណ្ដឹងរដ្ឋប្បវេណី នែ ហ៊ាប ប្រាប់ទៅអង្គជំនុំជម្រះថា គាត់មិនមានលទ្ធភាព រៀបចំពិធីបុណ្យសម្រាប់បងប្អូនរបស់គាត់ទេ ។ ជាការពិតណាស់ អ្នកអាចសួរសមាជិកក្នុងគ្រួសាររបស់ខ្ញុំ ។ រាល់ពេលដែលយើងគិតអំពីរឿងនេះ គឺយើងតែងតែហូរទឹកភ្នែក ។

## ការចាប់ខ្លួនកម្មាភិបាល

បន្ទាប់ពីសម្រាក វេទិកាត្រូវបានផ្ដល់ទៅសហព្រះរាជអាជ្ញា ដើម្បីសួរសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ។ ជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញាអន្តរជាតិលោក វិនសិន ដឺ វ៉ាល់ បានសួរពីការចាប់ខ្លួនរបស់ អឿន និង វឿង នៅក្នុងកងពល៣១០ ។ ហ៊ាប បានឆ្លើយថា តា ញ៉ូ បានមកជំនួស តា អឿន ។ គាត់មិនបានដឹងថា តា អឿន បាត់ខ្លួនទេ ។ ហ៊ាប បានប្រាប់ពីមូលហេតុដែលចាប់ខ្លួនថា មកពី អឿន និង វឿង បានព្យាយាមបះបោរ ។ អ្នកទាំងពីរត្រូវបានបញ្ជូនទៅធ្វើការអប់រំ ។ គាត់មិនអាចចាំពេលនៃការចាប់ខ្លួននេះបានទេ ។

តាហ៊ិន មកដល់មន្ទីរបងប្រុសរបស់ ហ៊ាប ហើយប្រាប់ថា គាត់អំពីបងប្រុសរបស់គាត់ដែលបាត់ខ្លួន ។ ចាប់ពីថ្ងៃនោះមក គាត់បានព្យាយាមលាក់ជីវប្រវត្តិ ។ ពេលខ្លះ គាត់ត្រូវបានអង្គការហៅទៅសួរនាំរៀងរាល់សប្ដាហ៍ ឬក៏ពីរសប្ដាហ៍ម្ដង ។

"ខ្ញុំបានកុហកនៅក្នុងជីវប្រវត្តិរបស់ខ្ញុំ"

លោក វិនសិន ដឺ វ៉ាល់ បានសួរពីកាលបរិច្ឆេទនៃការចាប់ខ្លួនបងប្រុសរបស់ ហ៊ាប ជាមួយនឹងការលើកបង្ហាញឯកសារមួយដែលចុះកាលបរិច្ឆេទថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៧ ដើម្បីរម្លឹកការចងចាំរបស់ ហ៊ាប ឡើងវិញ ។


សហព្រះរាជអាជ្ញាអន្តរជាតិ វិនសិន ដឺវ៉ាល់

គាត់បានឆ្លើយថា នេះជាការត្រឹមត្រូវ ។

គាត់និយាយថា ការចាប់ខ្លួនរបស់បងប្រុស គឺដោយសារបងប្រុសមានការទំនាក់ទំនងជាមួយ អឿន និង វឿង ។ ក្នុងអំឡុងកិច្ចប្រជុំមួយអង្គការបានប្រាប់អ្នកទាំងនោះថា មិនអាចត្រឡប់មកវិញទេ ត្រូវតែចូលរួមជាមួយកងទ័ព ។

បន្ទាប់មកលោក ដឺ វ៉ាល់ បានលើកបង្ហាញឯកសារមួយដែលមានចំណងជើងថាបញ្ជីឈ្មោះរបស់អ្នកទោស ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ និងបានគូសចំណាំនៅលេខ៦៨ ។ ហ៊ាប បានឲ្យដឹងថា គាត់មិនបានដឹងថ្ងៃពិតប្រាកដថា គាត់ត្រូវបានគេសម្លាប់នោះទេ ។ បន្ទាប់មកលោក ដឺ វ៉ាល់ បាននិយាយថា ឈ្មោះនេះហាក់ដូចមាននៅបញ្ជីរបស់ការិយាល័យសហព្រះរាជអាជ្ញា និងការធ្វើវិសោធនកម្មបញ្ជីឈ្មោះរបស់សហចៅក្រមស៊ើបអង្កេត ។ ម្យ៉ាងទៀតប្រពន្ធរបស់លោក ហេង ឈ្មោះ វ៉ិន ស្រឿន ហៅ នី ក៏មាននៅក្នុងបញ្ជីនេះដែរ ។

សម្រាប់ពេលវេលានៃការចាប់ខ្លួន ហ៊ាប ចាំបានថា តាញ៉ូ បានប្ដូរទៅកងពល នៅពេលដែល ហ៊ាប ត្រូវផ្ទេរឲ្យទៅរស់នៅក្នុងខណ្ឌទួលគោក ។ អ្នកទាំងអស់គ្នាបានទៅមើលខ្សែភាពយន្តនៅឯពហុកីឡដ្ឋានអូឡាំពិក ។ ត្រង់ចំណុចនេះ ប្រធានកងពលរបស់គាត់បានបាត់ខ្លួនរួចទៅហើយ ។ ក្រោយមកទៀត នីរសារឈ្មោះ គ្រឿង ត្រូវបានបញ្ជូនទៅអង្គភាពរបស់គាត់ និងនៅពេលដែលគាត់ទៅដល់ ខ្ញុំបានធ្វើការយ៉ាងលំបាក ។ គ្រឿង បានប្រាប់ ហ៊ាប ថានឹងត្រូវបានផ្លាស់ទៅកន្លែងផ្សេងទៀត ។ ហ៊ាប ត្រូវបានផ្លាស់ទៅនៅទីស្នាក់ការកណ្ដាល ។ មានឡាននៅចាំទទួលជាច្រើន ហើយអ្នកទាំងអស់គ្នាត្រូវបានប្រាប់ថា នឹងបញ្ជូនទៅកងពលផ្សេងទៀត ។ ពេលទៅដល់អ្នកទាំងអស់គ្នា ត្រូវបានអង្គការដឹកទៅដាក់នៅផ្ទះមួយដែលធ្ងំពីបេតុង ។ បន្ទមក អ្នកទាំងអស់គ្នាត្រូវបានហៅមកប្រជុំ ។ អំឡុងពេលប្រជុំ អង្គការបានសួរថា តើមាននរណាម្នាក់ខ្ជិលធ្វើការឬទេ? ហើយក្នុងចំណោមនោះ មានអ្នករាយការណ៍ថា មានអ្នកខ្លះខ្ជិលធ្វើការ ។ នេះជាអ្វីដែល ហ៊ាប គិតថា តើនឹងមានអ្វីកើតឡើង ប្រសិនជាខ្ញុំខ្ជិលធ្វើការ? ។ គាត់បានដឹងថា មនុស្សចំនួន៣នាក់ ត្រូវបានបញ្ជូនទៅព្រលានយន្តហោះពោធិ៍ចិនតុង ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក ។ គាត់ក៏ត្រូវបានរាយការណ៍ថា មានការជាប់ពាក់ព័ន្ធ

ជាមួយនឹងកងទ័ពមកពីភូមិភាគបូព៌ា ។

លោក ដឺ វ៉ាល់ បានសួរទៅដើមបណ្តឹងរដ្ឋប្បវេណី ពីកំណត់ហេតុនៃការស្តាប់ចម្លើយថា តើវាត្រឹមត្រូវទេ មានមនុស្សចំនួន៥០នាក់ បានបាត់ខ្លួន ។ គាត់បានឆ្លើយថា នៅខាងលិចព្រលានយន្តហោះនៅម្តុំក្រាំងលាវ ។ លោកប្រធានអង្គជំនុំជម្រះ សុខន បានជូនដំណឹងដល់សហព្រះរាជអាជ្ញា ថាពេលវេលាបានដល់ពេលកំណត់ ហើយបានផ្តល់វេទិកានេះឲ្យក្រុមមេធាវីការពារជនជាប់ចោទ នួន ជា ។

### កិច្ចប្រជុំ និងកងពល

លោក វិកទ័រ កូប៉េ មេធាវីអន្តរជាតិការពារជនជាប់ចោទ បានសួរថា តើលោកធ្លាប់ឈរជើងនៅមន្ទីរពេទ្យកាល់ម៉ែតដែលស្ថិតនៅក្បែរវត្តភ្នំដែរឬទេ? ហ៊ាប បានឆ្លើយថា មន្ទីរពេទ្យកងពល៣១០ មិនមែនស្ថិតនៅទីនេះទេ ប៉ុន្តែមន្ទីរពេទ្យ៣១០ នេះស្ថិតនៅខាងមុខផ្ទះរបស់ តា វឿង ទល់មុខមន្ទីរពេទ្យកាលម៉ែត្រតែម្តង ។ គាត់បានទៅសិក្សាវគ្គខ្លីៗ នៅខាងជើងវត្តភ្នំ ជាកន្លែងដែលកម្មាភិបាលជាន់ខ្ពស់មួយចំនួនត្រូវបានចាប់ខ្លួន ។ ពួកគេបានចំណាយពេលប្រហែលមួយខែ ក្នុងការចូលរួមវគ្គសិក្សានេះ ។ កិច្ចប្រជុំនេះបានធ្វើឡើងនៅទីស្នាក់ការកណ្តាលកងពល៣១០ នៅខណ្ឌទួលគោក មុនពេលដែលមានការចាប់ខ្លួនមេបញ្ជាការកងពល ។ គាត់មិនដឹងថា ស្ថានីយ៍វិទ្យុ មានទីតាំងស្ថិតនៅកន្លែងណាទេ ។ គាត់មិនបានដឹងថាក្នុងកងពលនេះ មានប៉ុន្មានវរសេនាតូចនោះទេ ។ បន្ទាប់ពីគាត់ចេញពីកងកុមារ គាត់ដឹងតែអំពីមនុស្សដែលធ្វើការនៅកងរបស់គាត់ប៉ុណ្ណោះ ហើយក៏មិនបានដឹងពីកងដទៃទៀតដែរ ។



សហមេធាវីអន្តរជាតិការពារជនជាប់ចោទ វិកទ័រ កូប៉េ

លោកមេធាវី កូប៉េ ចង់ដឹងថា តើកងវរសេនាតូច ៣០៦ គឺ មេបញ្ជាការឈ្មោះ តាឃីម និងឈ្មោះ តាបាន ជាអ្នកគ្រប់គ្រង? ដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា គាត់ធ្លាប់បានឮអំពីឈ្មោះអ្នកទាំងពីរ ។ នៅក្នុងកិច្ចប្រជុំអង្គការបានប្រកាសឈ្មោះ អ្នកដែលនឹងត្រូវមកនិយាយ ។ ហ៊ាប មិនបានដឹងអំពីអ្នកទាំងនោះទេ ។ លោកមេធាវី កូប៉េ សួរអំពីឋានៈរបស់តាឃីម និង តាបាន? ហើយ ហ៊ាប ឆ្លើយតបថា គាត់មិនបានដឹងពីរចនាសម្ព័ន្ធរបស់កងពលនេះទេ ។

លោកមេធាវី កូប៉េ បានសួរថា តើវាជាការត្រឹមត្រូវដែលថាបងប្រុសរបស់លោក ស្ថិតនៅកងទ័ពដែលចំណុះឲ្យភូមិភាគឧត្តរ ដូចដែលលោកបាននិយាយនៅក្នុងការផ្តល់សក្ខីកម្មរបស់លោក ។ ហ៊ាប បានអះអាងថានេះពិតជាត្រឹមត្រូវ ។ លោកមេធាវី កូប៉េ បានសួរថា តើ កុយ ធួន ជាអ្នកណា? ហ៊ាប បានឆ្លើយថា កុយ ធួន ជាអ្នកក្តាប់នៅក្នុងភូមិភាគទាំងមូល ។ ហ៊ាប មិនដឹងថា តើបងប្រុសរបស់គាត់ត្រូវបានចោទប្រកាន់ក្នុងការប្រព្រឹត្តកំហុសអ្វីទេ? ។ លោកមេធាវី កូប៉េ បានសួរថា តើលោកបានដឹងអំពីការព្យាយាមវាយប្រហារស្ថានីយ៍វិទ្យុ ព្រលានយន្តហោះពោធិ៍ចិនតុង ឬការរៀបចំរដ្ឋប្រហារមួយប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? ។ គាត់មិនបានដឹងច្បាស់ពីចំនួនមនុស្សពិតប្រាកដដែលត្រូវបានចាប់ខ្លួននៅក្នុងកងពលនេះទេ ។ មេធាវីកូប៉េ សួរអំពីការលាក់អាវុធនៅក្នុងឃ្លាំង ។ ហ៊ាប បានឆ្លើយថាគាត់មិនដែលឃើញអ្វីទាំងអស់ ។ លោកកូប៉េ ត្រឡប់មកសួរសំណួរចុងក្រោយរបស់គាត់ ថាតើលោកធ្លាប់ឮឈ្មោះ សែម ហឿន ដែលជាយុទ្ធជននៅកងពល៣១០ និងឈ្មោះ ប្រាក់ ខន ហើយក៏ធ្លាប់បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះដែរ? ដើមបណ្តឹងរដ្ឋប្បវេណីបានបដិសេធថា គាត់មិនស្គាល់ទេ ។ លោក កូប៉េ បានបញ្ចប់សំណួររបស់គាត់ក្នុងការសួរដេញដោលនេះ ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន មិនមានសំណួរសួរទៅដើមបណ្តឹងរដ្ឋប្បវេណីទេ ។

បន្ទាប់មក ក្នុងវេទិកានេះត្រូវបានផ្តល់ទៅដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរសំណួរទៅកាន់ជនជាប់ចោទ ។

### សំណួរសួរដោយដើមបណ្តឹងរដ្ឋប្បវេណី

ទីមួយ ខ្ញុំសុំសួរទៅជនជាប់ចោទ ថា “បងប្រុសខ្ញុំខិតខំតស៊ូដោយមានរបួសពេញខ្លួន រហូតដល់ទទួលជ័យជម្នះ ហេតុអ្វីបានជាគាត់ត្រូវចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់ ហេតុអ្វីបងប្អូនរបស់ខ្ញុំ ត្រូវចាប់ខ្លួន និងសម្លាប់ទៀត?

### បន្ទាប់មកគាត់បានចោទសំណួរជាលើកទីពីរ

ហេតុអ្វីបានជាយើងត្រូវធ្វើការជារួម ហូបរួម និងរស់នៅរួម ហើយហេតុអ្វីបានជាបង្កើតសហករណ៍? និងហេតុអ្វីបានជាកង

ទ័ពមិនត្រូវបានអនុញ្ញាតឲ្យទៅលេងស្រុកកំណើតរបស់ខ្លួន?

ជាចុងក្រោយគាត់បានសួរថា «ហេតុអ្វីបានជាបង្កើតរបបនោះឡើង? ហេតុអ្វីបានជាមិនមានវត្តអារាម គ្មានការចាយលុយ ហើយ ហេតុអ្វីមនុស្សគ្មានសិទ្ធិសេរីភាព? គ្មានការចរាចរលុយ, គ្មានទីផ្សារ, គ្មានវត្តអារាម នៅក្នុងអំឡុងរបបនោះ ហើយហេតុអ្វីបានជាធ្វើដូច្នេះ?

ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា គាត់មានសំណួរជាច្រើនដើម្បីសួរទៅជនជាប់ចោទ មុនពេលដែលគាត់បានមកដល់តុលាការនេះ ប៉ុន្តែឥឡូវនេះ គាត់មិនអាចចាំបានទេ។ បន្ទាប់មក លោកប្រធានអង្គជំនុំជម្រះ យ៉ា សុខន បានឲ្យដើមបណ្តឹងរដ្ឋប្បវេណីសម្រាក និងបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការនាំដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ មកកាន់សាលសវនាការ។

**ដើមបណ្តឹងរដ្ឋប្បវេណី ភួង យាត**


ដើមបណ្តឹងរដ្ឋប្បវេណី ភួង យាត

ភួង យាត កើតនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៦០ រស់នៅឃុំក្រឡា ស្រុកកំពង់សៀម។ បន្ទាប់មក លោក ពេជ អង្គ សហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានចាប់ផ្តើមសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។ ភួង យាត រស់នៅជាមួយឪពុកម្តាយ មុនពេលដួលរលំនៅរាជធានីភ្នំពេញ។ យាត ត្រូវបានបំបែកចេញពីបងប្អូនរបស់គាត់ ហើយបងស្រីរបស់ យាត ឈ្មោះ ភួង អ៊ីម ត្រូវបានអង្គការស្នើឲ្យទៅរាជធានីភ្នំពេញ។ យាត មិនបានដឹងអំពីជោគវាសនារបស់បងស្រីទេ ហើយក្រោយមកគាត់បានឮដំណឹងថា បងស្រីត្រូវបានអង្គការស្នើឲ្យរៀបការ និងបញ្ជូនឲ្យទៅធ្វើការនៅក្នុងរោងចក្រតម្បាញមួយ។ ក្រោយមកទៀត គាត់មិនបានឮដំណឹងសោះពីបងស្រីទៀតទេ។ យាត បានឮដំណឹងថា បងប្អូនរបស់គាត់ បានស្លាប់នៅគុកទួលស្លែង ហើយបានឃើញរូបថតដែលដាក់បង្ហាញនៅក្នុងគុកទួលស្លែង។ រូបថតមនុស្សដែលជាប់ឃុំឃាំងនៅស-២១ ត្រូវបានបង្ហាញដល់ យាត មើល។ យាត ឆ្លើយថា គឺពិតជារូបបងស្រីរបស់គាត់មែន ឈ្មោះ ភួង អ៊ីម។

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា បងស្រីរបស់គាត់ធ្វើជាជាងដេរសម្លៀកបំពាក់ ហើយបងប្រុសរបស់គាត់ ជាអ្នកឡើងត្នោត និងប្រមូលទឹកត្នោតកូរធ្វើស្ករយកទៅលក់នៅខេត្តកំពង់ចាម។ «អ្នកទាំងពីរស្រឡាញ់ខ្ញុំខ្លាំងណាស់»។ យាត ប្រាប់ពីអារម្មណ៍របស់គាត់ចំពោះ បងស្រីគាត់ថា «ខ្ញុំស្រឡាញ់បងស្រីខ្លាំងណាស់» ពីព្រោះគាត់បានថែទាំ និងយកចិត្តទុកដាក់ចំពោះបងប្អូន។ ពេលគាត់ទៅណាមកណា គាត់តែងតែយកខ្ញុំទៅជាមួយគ្រប់ទីកន្លែង។ ដើមបណ្តឹងរដ្ឋប្បវេណីបានឃើញរូបថតនេះនៅគុកទួលស្លែង។ គាត់បានរៀបរាប់ពីរូបថតនេះថា «បងស្រីពិតជាត្រូវទទួលទារុណកម្ម ហើយអ្នកអាចមើលឃើញតាមរយៈកែវភ្នែករបស់គាត់។»

ពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានឃើញរូបថតរបស់បងស្រីនៅទួលស្លែង «ខ្ញុំមានការសោកស្តាយខ្លាំងណាស់។ ខ្ញុំស្ទើរតែបាត់បង់ស្មារតី»។

នៅចំណុចនេះ លោកប្រធានអង្គជំនុំជម្រះ យ៉ា សុខន ប្រកាសផ្អាកសវនាការ។

**ការចាប់ខ្លួនបងប្អូន**

បន្ទាប់ពីសម្រាក លោក ពេជ អង្គ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ផ្តោតទៅលើឯកសារមួយដែលបង្ហាញថា ភួង អ៊ីម ត្រូវបានសម្លាប់នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨។ លោកមេធាវី ពេជ អង្គ បានសួរបន្តទៀតថា នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីមានបាត់បង់សមាជិកផ្សេងទៀតទេ ក្រៅពីបងស្រីទេ? ។ យាត បានឆ្លើយថា គាត់បានបាត់ឈ្មោះ ភួង ផុន, ភួង អ៊ីម, ភួង ភេន ដែលបានទៅចូលធ្វើទ័ពនៅស្វាយទាប។ ភួង វេន ធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ច ហើយបានជិះម៉ូតូមកលេង យាត ប្រហែលជា៥ដង។ វេន បានប្រាប់ឪពុកម្តាយគាត់ថា គួរតែឈប់សរសេរសំបុត្រទៅឲ្យគាត់ទៀត ពីព្រោះគាត់បានផ្លាស់មកភ្នំពេញហើយ។ តាំងពីពេលនោះមក ឪពុកម្តាយរបស់គាត់ មិនដែលបានទាក់ទងជាមួយគាត់ទៀតទេ។ ភួង ភេន បានចូលធ្វើទ័ពនៅស្វាយទាប ហើយក៏បានបាត់ខ្លួនតាំងពីពេលនោះមកដែរ។

បន្ទាប់មក រូបថតដែលបានបង្ហាញនៅលើកញ្ចក់កុំព្យូទ័រ ដើមបណ្តឹងរដ្ឋប្បវេណីបានស្គាល់ថា រូបថតនោះគឺជាបងប្រុស

របស់គាត់ឈ្មោះ ភួង ផុន ។ យាត បានរំលឹកថា គាត់បានឃើញរូបថតបងប្អូនរបស់គាត់នៅទួលស្លែង ។ យាត និយាយទៀតថា គាត់មានការតក់ស្លុតយ៉ាងខ្លាំង ហើយអ្នកទាំងអស់គ្នា ច្បាស់ជាត្រូវគេធ្វើទារុណកម្ម ។ ខ្ញុំនឹកអ្នកទាំងអស់គ្នាណាស់ ហើយខ្ញុំគិតថា ប្រសិនបើអ្នកទាំងអស់គ្នានៅរស់ គឺវាពិតជារីករាយខ្លាំងណាស់សម្រាប់ពួកយើងដែលបានជួបជុំគ្នាក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនេះ ប៉ុន្តែ រដូវភ្ជុំបិណ្ឌម្តងៗ ខ្ញុំពិតជាមានអារម្មណ៍ឯកោខ្លាំងណាស់ ។ យាត បានទៅវត្តក្នុងនៅពេលដែលមានបុណ្យសាសនា ហើយបានយកម្ហូបទៅប្រគេនដល់ព្រះសង្ឃ ដើម្បីឧទ្ទិសកុសលដល់ព្រលឹងសាច់ញាតិបងប្អូនរបស់គាត់ ។

ចំពោះភាពឈឺចាប់ដែលគាត់ទទួល យាត បានរម្លឹកពីស្ថានភាពរស់នៅក្នុងអំឡុងពេលធ្វើការងារ ។ ប្រសិនបើគាត់មិនអាចធ្វើគ្រប់ផែនការកំណត់ទេ គាត់នឹងទទួលពិន័យ ។ខ្ញុំមានជំងឺ និងនឿយហត់យ៉ាងខ្លាំង ព្រោះតែខ្ញុំហូបតែទឹកបបររាវៗប៉ុណ្ណោះ ។ ខ្ញុំគ្មានកម្លាំងដើម្បីធ្វើការនោះទេ ។ បងស្រីខ្ញុំម្នាក់នៅពេលនោះ ត្រូវអង្គការបង្ខំឲ្យរៀបការ ។ នាងបានរត់គេចខ្លួនទៅតាមវាលស្រែ និងបុរសពីរនាក់បានដេញចាប់នាង ។ ពួកគេតាមរកនាង តែរកមិនឃើញ ហើយនាងក៏រួចជីវិតមកដល់សព្វថ្ងៃ ។

យាត មានមិត្តម្នាក់ជាជនជាតិចាមឈ្មោះ កាស ។ យប់មួយ កាស ត្រូវបានអង្គការមកហៅ ហើយនៅថ្ងៃបន្ទាប់ ពួកគេបានឲ្យក្រមារបស់ កាស មកឲ្យ យាត ។ គាត់បានបដិសេធមិនយកក្រមានេះ តែ យាត ត្រូវបានគំរាមឲ្យយក ។ នេះគឺជាអ្វីដែលបានកើតឡើងនៅភូមិកោះស្វាយ ។

វគ្គបន្ទាប់ត្រូវបានផ្តល់ទៅឲ្យភាគីសហព្រះរាជអាជ្ញា ។ លោក សេង លាង សហព្រះរាជអាជ្ញារងជាតិ សួរអំពីមនុស្សម្នាក់ដែលបានប្រាប់ យាត ថា បងស្រីរបស់គាត់បានទៅភ្នំពេញហើយ ។ យាត ឆ្លើយថា អ្នកដែលប្រាប់នោះមានឈ្មោះ រ៉េត បានប្រាប់ម្តាយរបស់ យាត កាលពីឆ្នាំ១៩៧៩ថា បងស្រីរបស់ យាត ធ្វើការជាមួយគាត់នៅភ្នំពេញ ហើយ រ៉េត ក៏មានបានប្រាប់អ្វីក្រៅពីនេះដែរ ។ រ៉េត បានប្រាប់ម្តាយគាត់ថា គាត់គឺជាយុទ្ធនារីនៅភ្នំពេញ អំឡុងពេលដែលបងស្រីរបស់ យាត ធ្វើការនៅរោងចក្រកម្បាញ ។ រ៉េត មិនបាននិយាយអំពីប្តីរបស់បងស្រី យាត ទេ ។ បន្ទាប់មក យាត ក៏មិនបានទទួលដំណឹងអ្វីអំពីបងស្រីទៀតដែរ ។

យាត មិនបានដឹងថាបងប្រុសរបស់គាត់ឈ្មោះ ភួង ផុន ធ្វើការអ្វីនោះទេ ហើយគាត់គ្រាន់តែដឹងថាបងប្រុសទាំងពីរនាក់របស់គាត់បានចូលធ្វើទ័ព ។ តាំងពីនោះមក គាត់មិនដែលបានជួបអ្នកទាំងពីរម្តងទៀតទេ ។ មានតែបងប្រុសឈ្មោះ វ៉ែន ប៉ុណ្ណោះ ដែលមកលេងគាត់ម្តង ឆ្នាំ១៩៧៥ និងបានបាត់ខ្លួនតាំងពីពេលនោះមក ។ យាត មិនបានដឹងពីជោគវាសនាបងប្រុសម្នាក់នេះទេ ។

លោក លាង បង្ហាញឯកសារមួយចំនួន ដែលបញ្ជាក់ពីការនាំខ្លួន ភួង អ៊ឹម មកកាន់មន្ទីរ ស-២១ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ។ លោក លាង ក៏បានបង្ហាញឯកសារមួយចំនួនផ្សេងទៀត ដែលទាក់ទងទៅនឹងការចាប់ខ្លួន ភួង ផុន ដែរ ។

បងស្រីរបស់ យាត បានរត់គេចខ្លួន នៅពេលដែលមានការរៀបចំពិធីការឲ្យនាង ។ការរត់គេចនេះ ព្រោះតែនាងខ្លាចគេសម្លាប់ ដោយសារតែមិនព្រមរៀបការជាមួយបុរសដែលនាងមិនពេញចិត្ត ។


មេធាវីការពារក្តីជនជាប់ចោទ នួន ជា លោក លីវ សុវណ្ណា

វេទិកាបន្ទាប់បានប្រគល់ឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ។ លោកមេធាវីជាតិ លីវ សុវណ្ណា បានចោទសួរទៅដើមបណ្តឹងរដ្ឋប្បវេណីថា នៅក្នុងបទសម្ភាសន៍ យាត បានប្រាប់ថា ភួង ភេន ជាជាងធ្វើម៉ាស៊ីន ប៉ុន្តែ លោកស្រីបានឆ្លើយនៅថ្ងៃនេះថា គាត់ធ្វើជាកងទ័ពទៅវិញ ។ យាត ឆ្លើយតបថា គាត់បានទទួលដំណឹងថា ដំបូងអង្គការប្រាប់ថាយកទៅឲ្យធ្វើជាជាងជួសជុលម៉ាស៊ីនភ្លើង ហើយក្រោយមកត្រូវបានអង្គការបញ្ជូនឲ្យទៅធ្វើកងទ័ពវិញ ។ ឈ្មោះ ភួង វ៉ែន បានប្រាប់ យាត ថា បងប្រុសរបស់គាត់បានធ្វើជាកងទ័ព អំឡុងឆ្នាំ១៩៧៥ ឬឆ្នាំ១៩៧៦ ។ លោកមេធាវី សុវណ្ណា បានបញ្ជាក់បន្ថែមទៀតលើការឆ្លើយនេះ ។ យ៉ាត បានឆ្លើយថា ប្រជាជនក្នុងភូមិបានប្រាប់ យាត ថា បងប្រុសគាត់ធ្វើជាជាងជួសជុលម៉ាស៊ីនភ្លើង ស្របពេលដែលបងប្រុសរបស់ យាត បានប្រាប់គាត់ថា គាត់គឺជាទាហាន ។ មេធាវី ពេជ

អង្គ បាននិយាយកាត់ថា នេះជាការកំណត់នៃពេលវេលាសមស្របគ្នានឹងចម្លើយរបស់ដើមបណ្តឹង មិនមែនមានការផ្ទុយគ្នាដូចដែលក្រុមមេធាវីការពារក្តីបានលើកនោះទេ ។ លោកមេធាវី សុវណ្ណ នៅតែប្រកាន់ជំហរថា ពេលវេលាគឺមិនច្បាស់លាស់ ប៉ុន្តែវាគឺជាការចាប់ផ្តើម ។ មេធាវី ពេជ អង្គ ជាថ្មីម្តងទៀត និងបានចង្អុលពេលវេលាគឺមិនមែនមិនច្បាស់លាស់នោះទេ ។

លោកមេធាវី សុវណ្ណ បានសួរថា តើនៅក្នុងរូបថតនីមួយៗ មានឈ្មោះជាប់មកជាមួយទេ ។ យាត បានឆ្លើយថា គាត់មើលមិនច្បាស់ទេ ប៉ុន្តែគាត់ស្គាល់ច្បាស់ណាស់ថា ជារូបថតរបស់បងគាត់ ។ លោកមេធាវី សុវណ្ណបានសួរទៀតថាៈ ហេតុដូចម្តេចបាន លោកស្រី ចំណាំបងប្រុសរបស់លោកស្រីច្បាស់យ៉ាងនេះ? យាត បានឆ្លើយថាបងប្អូនគាត់មានមុខមាត់ដូចៗគ្នា ។ បងៗប្រុសរបស់គាត់មើលទៅដូចពីមុន លើកលែងតែបងប្រុសរបស់គាត់ម្នាក់មានរាងស្គមជាងមុន ។

## ការសួរដេញដោលរបស់មេធាវីការពារក្តី ខៀវ សំផន


មេធាវីការពារក្តី ខៀវ សំផន លោក គង់ សំអុន

វេទិកាបន្ទាប់ ត្រូវបានផ្តល់ឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ប្រាប់អំពីការរៀបការបងស្រីរបស់គាត់ និងនៅពេលដែលគាត់ធ្វើការជាមេចុងភៅ ។ ប្រធានភូមិឈ្មោះ តាហេង ។ បងស្រីរបស់ យាត មិនបានប្រាប់ឲ្យអ្នកណាដឹងពីរឿងរៀបការគាត់ទេ ក្រៅពីប្រធានភូមិ ព្រោះគាត់ខ្លាចអង្គការដឹង ហើយអង្គការយកទៅសម្លាប់ចោល ។ ប្រធានភូមិបានឯកភាពជាមួយបងស្រីរបស់គាត់ ដើម្បីលាក់រឿងនោះ ។ បន្ទាប់មក លោកមេធាវី សំអុន បានបញ្ចប់ការសាកសួរដេញដោលអំពីសាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រឹមនេះ ។

បន្ទាប់មក លោកប្រធានអង្គជំនុំជម្រះ បានផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណី សួរសំណួរទៅកាន់ជនជាប់ចោទៈ

គាត់បានសួរថាៈ “បន្ទាប់ពីបងៗបានធ្វើសង្គ្រាមប្រឆាំងរបប លន់ នល់ ក្នុងឆ្នាំ១៩៧៥-៧៦ ឈ្នះហើយ ហេតុអ្វីបានជាអស់លោកសម្លាប់បងប្អូនរបស់ខ្ញុំទៀត? នេះជារឿងតែមួយគត់ដែលខ្ញុំចង់សួរ ។ បងៗរបស់ខ្ញុំបានជួយរំដោះប្រទេសជាតិ ហើយត្រូវបានខ្មែរក្រហមនាំយកទៅបាត់ និងក្រោយមកយកទៅសម្លាប់ចោល ។”

ប្រធានអង្គជំនុំជម្រះ យ៉ា សុខន បានជម្រាបជូនដើមបណ្តឹងរដ្ឋប្បវេណីថា ជនជាប់ចោទទាំងពីររូប បានអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការនៅស្ងៀមមិនឆ្លើយតប និងបានថ្លែងអំណរគុណដល់លោកស្រី ភួង យាត និងបានឲ្យដើមបណ្តឹងរដ្ឋប្បវេណីសម្រាក ។

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ារី ហ្គីរ៉ូដ បានស្នើសុំឲ្យមានការសម្រាកមុនពេល ១០នាទី ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណី អាចស្តាប់បន្តតាមរយៈវីដេអូខាក់ទង ។ សំណើនេះត្រូវបានឯកភាព ។

## ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី


ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី

បន្ទាប់ពីសម្រាក លោកប្រធានអង្គជំនុំជម្រះបានប្រកាសប្រាប់អង្គសវនាការថា ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1049 នឹងត្រូវផ្តល់សក្ខីកម្មក្នុងសវនាការតាមរយៈប្រព័ន្ធសោទស្សន៍ពីប្រទេសបារាំង ។ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ រស់ ជួរស៊ីអ៊ី កើតនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៣៨ ហើយសព្វថ្ងៃគាត់រស់នៅប្រទេសបារាំង ។ សហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានចាប់ផ្តើមសួរសំណួរទៅកាន់លោកស្រី ។ ប្តីរបស់លោកស្រីបានបាត់ខ្លួន ។ លោកស្រីមេធាវី បានអានសេចក្តីដកស្រង់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងថា ពួកគាត់បានត្រឡប់មកប្រទេសកម្ពុជាវិញ បន្ទាប់ពីប្រទេសនេះ ត្រូវបានរំដោះហើយ ។ តើការបាត់ខ្លួនប្តីលោកស្រី វាបានធ្វើឲ្យប៉ះពាល់យ៉ាងណាខ្លះចំពោះជីវិតរបស់លោកស្រី?

“គ្រួសាររបស់ខ្ញុំ និងខ្ញុំ បានត្រឡប់មកប្រទេសកម្ពុជា នៅ

ថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៧៦ ។ ពេលដែលយើងមកដល់ព្រលានយន្តហោះពោធិ៍ចិនតុង យើងពិតជាស្រងាកចិត្តខ្លាំងណាស់ ដោយសារតែយើងមិនបានឃើញញាតិមិត្តបងប្អូនមកទទួល ។ ពេលដែលយើងធ្វើដំណើរតាមផ្លូវ គឺមានសភាពស្ងាត់ ។ ខ្ញុំពិតជាបារម្ភណាស់ ។ នៅតាមផ្លូវធ្វើដំណើរ ខ្ញុំមានអារម្មណ៍ខ្វល់ខ្វាយ រហូតដល់គេយកយើងមកដល់មន្ទីរក-១៥ ។ មកដល់មន្ទីរក-១៥ ខ្ញុំបានជួបមិត្តភក្តិមួយចំនួន ជាពិសេស បានជួបបុរសចំណាស់ពីរនាក់ ដែលខ្ញុំធ្លាប់បានជួបកាលពីពីរបីខែមុនគាត់ត្រឡប់មកប្រទេសកម្ពុជា ។ ខ្ញុំឃើញពួកគាត់មានរាងកាយស្គមស្គាំង ជាមួយនឹងខោអាវចាស់រហែក និងមើលមកខ្ញុំដោយសេចក្តីទុក្ខព្រួយ ។ នៅពេលដែលពួកគេឃើញយើង ពួកគេញញឹមដោយក្តីក្រៀមក្រំ ។ តាមរយៈផ្ទៃមុខរបស់ពួកគេ ខ្ញុំអាចដឹងពីទុក្ខវេទនារបស់ពួកគេ ។ មួយរយៈក្រោយមក ខ្ញុំបានជួបប្អូនស្រីរបស់ខ្ញុំ ដែលត្រូវគេយកមកដាក់មន្ទីរនេះដែរ ។ ប្អូនស្រីរបស់ខ្ញុំបានត្រឡប់មកប្រទេសកម្ពុជា មុនខ្ញុំ៦-៧ខែ ។ នាងបានញញឹមមកកាន់ខ្ញុំ ជាមួយនឹងស្នាមញញឹមមិនធម្មតា ។ វាបង្ហាញពីការឈឺចាប់ និងរងទុក្ខរបស់នាង ។ ខ្ញុំបានសួរនាងថា នាងបានជួបឪពុកម្តាយ ឬបងប្អូនទេ? នាងក្រវីក្បាលហើយឆ្លើយថា មិនដែលបានជួបនរណាម្នាក់ឡើយ ។

បន្ទាប់មក លោកស្រី ស៊ី បានបន្តថា ខ្លួនត្រូវបានផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ ។

«ខ្ញុំមានការលំបាកវេទនាខ្លាំងណាស់ ។ ខ្ញុំមិនដែលគិតថា ប្រទេសខ្ញុំធ្លាក់ចូលក្នុងស្ថានភាពគួរឲ្យសង្វេគដូច្នេះទេ ។

បន្ទាប់មក លោកស្រី បានរៀបរាប់ប្រាប់តុលាការ អំពីការបែកបាក់គ្រួសារៈ

ពីព្រោះតែគ្រួសាររបស់ខ្ញុំ មានសមាជិក៩នាក់ ហើយសមាជិកនីមួយៗត្រូវស្ពាយវ៉ាលិសសម្លៀកបំពាក់ យើងមិនអាចជិះនៅក្នុងឡានអស់គ្នាទេ ដោយសារតែវាចង្អៀត ។ ដូច្នេះហើយប្រធានមន្ទីរបានប្រាប់យើងថា អ្នកសេលសល់ផ្សេងទៀតនឹងទៅតាមក្រោយ ។ បន្ទាប់មកខ្ញុំបានឃើញមនុស្សម្នាក់ឈ្មោះ ឈិនឌឿន ដែលឈ្មោះគាត់ក្រោយមកក៏មាននៅទួលស្លែងដែរ ។

ខ្លួនរបស់ខ្ញុំឡើងភ័យញ័រ ។ ខ្ញុំបានគិតត្រឡប់ទៅក្រោយវិញថា ប្រសិនបើយើងអាចជិះនៅក្នុងឡានបានទាំង៩នាក់នោះប្រហែលជាយើងទាំងអស់គ្នា នឹងត្រូវបញ្ជូនមកដាក់នៅទួលស្លែងហើយ ។ ខ្ញុំទើបតែបានដឹងពីព័ត៌មាននេះនៅពេលក្រោយមកទៀត

គ្រួសាររបស់លោកស្រី ត្រូវបានជម្លៀសម្តងទៀតនៅក្នុងពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ១៩៧៦ ទៅកន្លែងដែលមានឈ្មោះថា បឹងត្របែក ។

នៅបឹងត្របែក រូបរាងរបស់ប្តីខ្ញុំធ្លាក់ដុនដាបទៅៗ ហើយគាត់កាន់តែខ្សោយទៅៗ ហើយសុខភាពគាត់ក៏កាន់តែទ្រុឌទ្រោមទៅៗ ដោយសារតែកង្វះអាហារ

លោកស្រី បានពន្យល់បន្ថែមទៀតថា តើគាត់បានបែកចេញពីប្តី និងបារម្ភពីប្តីរបស់ខ្លួនយ៉ាងណា? ប៉ុន្តែដំបូងគាត់នៅតែគិតថា នឹងបានជួបប្តីវិញ ។

នៅប្រហែលពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៦ អំឡុងពេលដែលយើងរៀនវគ្គសិក្សានយោបាយ នៅបឹងត្របែក ប្តីរបស់ខ្ញុំបានមករកដោយប្រញាប់ប្រញាល់ ហើយគាត់បានប្រាប់ខ្ញុំថា គាត់ត្រូវអង្គការចាត់តាំងឲ្យធ្វើការងារមួយ ។ ខ្ញុំបានសួរគាត់ថា អង្គការចាត់តាំងឲ្យធ្វើអ្វី? គាត់ឆ្លើយថា វាជាការសម្ងាត់ ហើយអង្គការក៏មិនបានប្រាប់គាត់ដែលថា នឹងទៅធ្វើការនៅកន្លែងណា ។ មុននឹងគាត់ចាកចេញទៅ គាត់បានផ្តែផ្តាំខ្ញុំថា ឲ្យខិតខំធ្វើការ ថែរក្សាខ្លួន ក៏ដូចជាមើលថែកូនៗផង ។ គាត់បន្តទៀតថា កុំបារម្ភ ពួកយើងនឹងជួបគ្នាវិញក្នុងពេលឆាប់ៗ ហើយខ្ញុំក៏សង្ឃឹមថា នឹងជួបគាត់ក្នុងពេលឆាប់ៗដែរ ។ ខ្ញុំពិតជាបារម្ភណាស់ បន្ទាប់ពីគាត់ត្រូវបានបំបែកពីខ្ញុំ ។ ខ្ញុំពិតជាមានអារម្មណ៍ឯកោណាស់ ។ ខ្ញុំសង្ឃឹមថា គាត់នឹងត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការនៅកន្លែងថ្មីដែលមានការហូបចុកគ្រប់គ្រាន់ និងការងារធូរស្រាលជាងមុន ។ ទោះជាយ៉ាងណាស្ថានភាពជាក់ស្តែង គឺខុសពីការគិតរបស់ខ្ញុំ ។ សម្តីចុងក្រោយរបស់គាត់ថា យើងនឹងជួបគ្នាវិញ គឺមិនអាចជាការពិតទេ ។ វាត្រូវបានរសាត់ដូចខ្យល់ ។

លោកស្រី ស៊ីអ៊ី បានប្រាប់ទៅអង្គជំនុំជម្រះ ពីអ្វីដែលគាត់ត្រូវបានប្រាប់ថាមិនចាំបាច់ព្រួយបារម្ភថាអ្វីទេ ហើយនឹងបានជួបប្តីវិញមិនខាន ។

ខ្ញុំមានសង្ឃឹមម្តងទៀតបន្ទាប់ពីបានឮការប្រាប់នេះ ហើយខ្ញុំនៅតែទន្ទឹងរង់ចាំ ចាំហើយចាំទៀត ខណៈពេលដែលកំពុងធ្វើការ ។

*គ្រប់ពេលដែលមានឡានចូលក្នុងជំរំ ខ្ញុំព្យាយាមមើលថា តើប្ដីរបស់ខ្ញុំត្រឡប់មកវិញដែរឬទេ? ខ្ញុំទន្ទឹមរង់ចាំ ប៉ុន្តែនៅក្នុងចិត្តរបស់ខ្ញុំកាន់តែបារម្ភទៅៗ ។*

*ខែកុម្ភៈ ឆ្នាំ១៩៧៧ លោកស្រី នឹងកូនៗ ត្រូវបានជម្លៀសទៅកន្លែងផ្សេង ដែលធ្វើឲ្យគាត់កាន់តែព្រួយបារម្ភឡើងៗ ពីព្រោះគាត់មានអារម្មណ៍ថា ការជម្លៀសមកនេះគឺ ហាក់ដូចជាធ្វើឲ្យគាត់កាន់ឃ្លាតឆ្ងាយពីប្ដីរបស់គាត់ ។ ពេលនោះ គាត់ជឿជាក់ថា ប្ដីរបស់គាត់កំពុងតែធ្វើការ នៅពោធិ៍ចិនតុង ពីព្រោះគាត់ជាអតីតប្រធានព្រលានយន្តហោះពោធិ៍ចិនតុង មុនពេលដែលគាត់ចេញទៅបន្តសិក្សាថ្នាក់បណ្ឌិតនៅប្រទេសបារាំង ។*

*ខ្ញុំខិតខំធ្វើការដូចអ្នកផ្សេងទៀត ហើយព្យាយាមមិនបញ្ចេញអារម្មណ៍សោកសៅក្នុងពេលកំពុងតែធ្វើការ ។ ពេលខ្លះ ខ្ញុំកំពុងជម្រះស្មៅ ខ្ញុំបានឮសំឡេងយន្តហោះ ហោះនៅពីលើ ហើយការឮសំឡេងនេះបានធ្វើឲ្យខ្ញុំស្រក់ទឹកភ្នែក ពីព្រោះវាបានរំឭកខ្ញុំពីពេលដែលយើងបាននៅជាមួយគ្នា ដូចជាពេលដែលយើងនៅលើយន្តហោះជាមួយគ្នាអ៊ីចឹង ។*

*នៅពេលនោះ គាត់ធ្វើការនៅដីក្រហម ហើយមានក្ដីសង្ឃឹមខ្លាំងថា នឹងបានជួបប្ដីរបស់ខ្លួនម្ដងទៀត ពីព្រោះប្រជាជនផ្សេងៗត្រូវបានហៅត្រឡប់មកវិញ ហើយបាននិយាយថា ពួកគេនឹងត្រូវឲ្យទៅជួបជុំគ្រួសារវិញ ។ ខ្ញុំមានអារម្មណ៍សប្បាយរីករាយជំនួសគេ ហើយយើងមានជំនឿជាក់ថា ពួកគេនឹងជួបប្ដីប្រពន្ធគេវិញ ។ ខ្ញុំមិនដឹងថា ពេលណាខ្ញុំនឹងបានជួបប្ដីរបស់ខ្ញុំវិញទេ ។ ខ្ញុំមានអារម្មណ៍ហាក់ដូចជាអស់សង្ឃឹម ពីព្រោះប្រជាជនមួយចំនួនត្រូវបានអង្គការបញ្ជូនឲ្យទៅជួបជុំជាមួយគ្រួសារវិញ ខណៈពេលខ្ញុំនៅតែរង់ចាំការវិលត្រឡប់របស់ប្ដីខ្ញុំ ។*

## ដើមបណ្ដឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី

*លោកស្រីបានសួរប្រធានជំរំដីក្រហមថា តើពេលណាទើបគាត់អាចជួបប្ដីរបស់គាត់វិញ ប៉ុន្តែគាត់ទទួលបានចម្លើយដដែលថា គាត់នឹងទៅជួបជុំប្ដីរបស់គាត់វិញនៅពេលណាមួយ ។*

*ខ្ញុំនៅតែទន្ទឹងរង់ចាំ ហើយខ្ញុំនៅតែមានទុក្ខព្រួយ និងការព្រួយបារម្ភគ្រប់ពេលវេលា ។ ម្ដងនោះនៅក្នុងជំរំដីក្រហម មានឡានដឹកមនុស្សមួយចំនួនបានមកដល់ ហើយគ្រប់ពេល ខ្ញុំតែងមានអារម្មណ៍រំភើបថា ខ្ញុំនឹងបានជួបប្ដីខ្ញុំវិញ ។ កូនៗរបស់ខ្ញុំពិតជាចង់ជួបឪពុកខ្លាំងណាស់ ។ ប៉ុន្តែគ្រប់ពេល ដែលគេចុះពីលើឡាន គឺមិនឃើញប្ដីរបស់ខ្ញុំសោះ ។*

*លោកស្រី ស៊ីអ៊ី បានរំឭកថា ប្អូនស្រីរបស់គាត់បានកើតជំងឺគ្រុនចាញ់ ខណៈពេលនាងកំពុងមានផ្ទៃពោះ ហើយវាកាន់តែធ្វើឲ្យគាត់មានការព្រួយបារម្ភខ្លាំងឡើងៗ ។ នាងបានសម្រាលកូនដោយការវះកាត់ ។ នៅពេលនោះ កូនស្រីពៅរបស់នាង បានលួចរត់មកជួបខ្ញុំ ។ កូនស្រីរបស់នាង បានយកផ្លែឈើ និងម្ហូបអាហារមកជាមួយ ពីព្រោះក្មេងៗនៅកងកុមារទទួលបានរបបអាហារច្រើន ។*

*ក្នុងឆ្នាំ១៩៧៨ ពួកគេត្រូវបានផ្លាស់ទៅនៅបឹងត្របែកវិញ ដែលធ្វើឲ្យគាត់នឹកឃើញពីពេលដែលគាត់ត្រូវបានបញ្ជូនទៅទីនោះជាមួយប្ដីគាត់ ។*

*ខ្ញុំបានចោទសួរខ្លួនឯង ហេតុអ្វីបានជាយើងអាចចាកចេញពីប្រទេសបារាំង ដែលជាកន្លែងដែលយើងរស់នៅសុខស្រួល?*

*លោកស្រី មានអារម្មណ៍សោកស្ដាយចំពោះការឃ្លាតចេញពីឪពុកម្ដាយដែរ ។ តើហេតុអ្វីបានជាជីវិតរបស់ខ្ញុំក្លាយទៅជាវេទនាដូច្នេះ?*

## ការរស់នៅបន្ទាប់ពីបាត់ខ្លួនប្ដី

*បន្ទាប់មក លោកស្រីបានប្រាប់អង្គជំនុំជម្រះថា គាត់មានភាពរឹងប៉ឹង ក៏ព្រោះតែកូនៗរបស់គាត់ ។ ខ្ញុំបានរស់នៅជាមួយកូនទាំងពីររបស់ខ្ញុំ ក្នុងនាមជាស្ត្រីមេម៉ាយម្នាក់ ហើយមានក្ដីសង្ឃឹមថានឹងបានជួបប្ដីដែលបានបាត់ខ្លួនវិញ ។ ខ្ញុំខិតខំធ្វើការងារគ្រប់យ៉ាងដើម្បីអនាគតកូនរបស់ខ្ញុំទាំងអស់*

*ជាចុងក្រោយ លោកស្រី បានចងចាំពីការទស្សនាសារមន្ទីរទួលស្លែងជាលើកដំបូង ពេលដែលខ្ញុំដើរមើលបន្ទប់នីមួយៗ ខ្ញុំបានឃើញសម្ភារសម្រាប់ធ្វើទារុណកម្ម ខ្ញុំបានឃើញវត្ថុជាច្រើននៅទីនោះ ហើយខ្ញុំមិនចង់ឃើញវត្ថុទាំងនោះម្ដងទៀតដែរ ។ ជាចុងក្រោយ ខ្ញុំបានទៅដល់បន្ទប់មួយដែលមានរូបថតអ្នកទោសត្រូវបានដាក់បង្ហាញនៅទីនោះ ។ នៅពេលនោះហើយ ដែលខ្ញុំចាប់ផ្ដើមមានអារម្មណ៍រន្ធត់ ខ្ញុំព្យាយាមមើលរូបថត ដែលគេដាក់បង្ហាញនោះម្ដងមួយៗ ខ្ញុំបានឃើញមនុស្សដែលខ្ញុំធ្លាប់ស្គាល់នៅក្នុងចំណោមរូបថតទាំងនោះ ។ ទីបំផុត ខ្ញុំបានឃើញរូបថតប្ដីរបស់ខ្ញុំ*

មួយសន្ទឹក ។ នៅទីនោះ ខ្ញុំចង់ស្រែកយំឲ្យខ្លាំងៗ ហើយខ្ញុំស្ទើរតែបាត់បង់ស្មារតី ។

ទោះជាយ៉ាងណាក៏ដោយ ហាក់ដូចជាមានសំឡេងមួយមកប្រាប់ថា កុំយំ ហើយខ្ញុំចាប់ផ្តើមពង្រឹងស្មារតីឡើងវិញ ។ បន្ទាប់ពីថ្ងៃនោះ ខ្ញុំបានប្រាប់ខ្លួនឯងថា ខ្ញុំមិនអាចរស់នៅក្នុងប្រទេសនៅក្នុងស្ថានភាពបែបហ្នឹងទេ ។ ខ្ញុំត្រូវតែធ្វើអ្វីៗតាមលទ្ធភាពដែលខ្ញុំអាចធ្វើទៅបានសម្រាប់អនាគតកូនៗរបស់ខ្ញុំ ពីព្រោះពួកគេបានបាត់បង់ឪពុក ដូច្នេះកូនៗទាំងអស់គឺពឹងផ្អែកលើខ្ញុំ ដែលជាម្តាយរបស់គេតែម្នាក់គត់ ។ ខ្ញុំត្រូវតែប្រឹងប្រែងគ្រប់យ៉ាងនៅក្នុងការចិញ្ចឹមកូនទាំងអស់ ។ មនុស្សគ្រប់គ្នាមើលទៅហាក់ដូចជា សោកសង្រេងណាស់បន្ទាប់ពីការទៅទស្សនកិច្ចនៅសារមន្ទីរនោះ ហើយជាពិសេសខ្ញុំកាន់តែមានស្ថានភាពអាក្រក់ទៅៗ ។ ខ្ញុំលែងមានសង្ឃឹមទៀតហើយ ។ ខ្ញុំបានធ្វើការសម្រេចចិត្តថា ខ្ញុំត្រូវតែធ្វើអន្តោប្រវេសន៍ទៅរស់នៅកន្លែងផ្សេង ឬទៅប្រទេសបារាំង


សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហ្គីរ៉ូ

ដោយសារតែគុណភាពការផ្សាយតាមកញ្ចក់កុំព្យូទ័រមិនមានដំណើរការល្អ ធ្វើឲ្យការបកប្រែមានភាពលំបាក ។ តមក សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរផ្ទាល់ទៅដើមបណ្តឹងរដ្ឋប្បវេណី ។ ឯកសារមួយបានបង្ហាញនៅលើកញ្ចក់កុំព្យូទ័រ ដោយបង្ហាញនូវរូបថតបុរសចំនួន៨សន្លឹក ។ លោកស្រីបាននិយាយថា ប្តីរបស់គាត់គឺជារូបបុរសទី២រាប់ពីខាងឆ្វេងនៅជួរទីពីរ ។ លោកស្រី ហ្គីរ៉ូដ បានបង្ហាញសម្រង់ផ្សេងទៀតដែលមានក្នុងបញ្ជី ។ លោកស្រី ស៊ីអ៊ី បានបញ្ជាក់បន្ថែមថា នេះគឺជាឈ្មោះរបស់ប្តីគាត់ឈ្មោះ រស់ ស៊ិរិន ។ លោកស្រី ហ្គីរ៉ូដ បានសួរថា តើលោកស្រីបានដឹងព័ត៌មានអ្វីខ្លះ ដែលថាប្តីលោកស្រីត្រូវបានបញ្ជូនមកដល់មន្ទីរ ស-២១ នៅខែធ្នូឆ្នាំ១៩៧៦? ដែលវាកើតឡើងពីរបីសប្តាហ៍ បន្ទាប់ពីលោកស្រីបានឃើញប្តីជាលើចុងក្រោយ? លោកស្រី ស៊ីអ៊ី បានឆ្លើយថា គាត់មិនមានសង្ឃឹមអ្វីទាំងអស់ បន្ទាប់ពីគាត់បានដឹងថា ប្តីរបស់គាត់ត្រូវបានចាប់បញ្ជូនមកមន្ទីរស-២១ ពីព្រោះនេះ គឺជាកន្លែងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃ ។

លោកស្រី ហ្គីរ៉ូដ បានបញ្ចប់ការសួរសំណួរ ហើយបានផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ។ សំណួរចំពោះលោកស្រី ស៊ីអ៊ី អំពីការស្នាក់នៅរបស់គាត់នៅក្នុងប្រទេសបារាំង ។ លោកស្រី ស៊ីអ៊ី និយាយថា គាត់បានជួបប្តីរបស់គាត់នៅឆ្នាំ១៩៧២ ។ ប្តីគាត់ទទួលបានអាហារូបករណ៍ពីរដ្ឋាភិបាលភ្នំពេញ ដើម្បីបន្តការសិក្សាថ្នាក់បណ្ឌិតនៅប្រទេសបារាំង ។ ប្តីរបស់គាត់ធ្វើការជាមួយនឹងអាកាសចរណ៍បារាំង និងអាកាសចរណ៍ខ្មែរ ។ ពួកគាត់បានត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ព្រោះពួកគាត់សង្ឃឹមថា កម្ពុជានឹងមានសន្តិភាពឡើងវិញបន្ទាប់ពីភ្នំពេញដួលរលំ ។ ពួកគាត់ត្រឡប់មកដើម្បីជួយកសាងប្រទេសឡើងវិញ ។ ប្តីរបស់គាត់មិនបានជួបអៀង សារី ផ្ទាល់ទេ ។ នៅពេលដែលពួកគាត់ ចុះពីយន្តហោះ ពួកគាត់មិនមានសិទ្ធិផ្លាស់ទៅនៅកន្លែងផ្សេងទេ ។ ពួកគាត់គ្មានសិទ្ធិសេរីភាពទៅកន្លែងផ្សេងក្រៅពីមន្ទីរឡើយ ដែលមើលទៅហាក់បីដូចជាមន្ទីរឃុំឃាំង ។ ប្តីរបស់គាត់បានចូលរួមប្រជុំមួយនៅបឹងត្របែក ។ គាត់បានជួបតែប្រធានដែលនៅគ្រប់គ្រងនៅមន្ទីរបឹងត្របែកប៉ុណ្ណោះ ។ មនុស្សមួយចំនួនត្រូវបានយកទៅជាមួយប្តីរបស់គាត់ ។ លោក ដឺវ៉ាល់ បានយោងទៅលើសៀវភៅដែលសរសេរដោយលោក អ៊ុង ចុងហៀង ដែលបានសំដៅទៅលើមនុស្សពីរបីនាក់ផ្សេងទៀត ។ លោកស្រី ស៊ីអ៊ី និយាយថា គាត់នៅចាំជាងគេគឺ ជឿន ម៉េងម៉ៅ ។

លោក ដឺវ៉ាល់ បានសំដៅទៅលើបញ្ជីទូលស្លែងមួយដែលមានចំណងជើងថា បញ្ជីឈ្មោះអ្នកទោសដែលត្រូវបានកម្ទេចនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ។ បញ្ជីនេះ បានបង្ហាញអំពីថ្ងៃសម្លាប់របស់ប្តីគាត់ គឺនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ។ លោក ដឺវ៉ាល់ បានសួរថាតើលោកស្រីទទួលបានព័ត៌មានទាំងនេះ មុនពេលដែលលោកស្រី ទៅដល់មន្ទីរស-២១? លោកបាននិយាយថា គាត់មិនយល់នឹងសំណួរនេះ ។ លោកស្រីបានបញ្ជាក់ថា មិត្តភក្តិមួយចំនួនហៅគាត់ថា ម៉ៅ ហើយលោកស្រីក៏មិនដឹងថា អ្នកណាខ្លះត្រូវបានគេសម្លាប់នោះទេ ។

## ការសួរដេញដោលរបស់មេធាវីការពារក្តី នួន ជា

ក្រុមមេធាវីការពារក្តីរបស់ នួន ជា ត្រូវបានផ្តល់ឱកាសដើម្បីសួរសំណួរលោកស្រី ស៊ីអ៊ី ។ មេធាវីអន្តរជាតិ លោក វិចទ័រ កូប៉េ បានសួរថា តើលោកស្រីស្គាល់មនុស្សម្នាក់ឈ្មោះថា សួង ស៊ីគៀន ទេ? លោកស្រី គាត់បានឆ្លើយថា គាត់បានឮឈ្មោះនេះ ប៉ុន្តែមិនបានស្គាល់មុខទេ ។ មេធាវី កូប៉េ បានអានប្រតិចារឹក ដែលបានបង្ហាញថា លោក សួង ស៊ីគៀន បាននិយាយថា ប្តីរបស់គាត់បានសហការជាមួយនឹងរបប លន់ នល់ ដែលត្រូវបានអង្គការចាត់ទុកថាគឺជាជនចម្រើន ។ មេធាវី កូប៉េ បានសួរទៅទៀតថា តើប្តីរបស់គាត់ជាអ្នកគាំទ្រ ស៊ីង ង៉ុកថាញ់ មែនទេ? ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់មិនបានដឹងពីអតីតកាលរបស់ប្តីគាត់ទេ ។ គាត់ធ្វើការជាមួយរដ្ឋាភិបាល លន់ នល់ ។ មេធាវី កូប៉េ បានសួរថា តើលោកស្រីបានស្គាល់ ហោ ណាំហុង ទេ? ហោ ណាំហុង ជារដ្ឋមន្ត្រីការបរទេសរហូតដល់ខែមេសា ឆ្នាំនេះ ហើយក៏ជាអ្នកធ្លាប់ធ្វើការនៅបឹងត្របែកដែរ ។ លោកស្រីបានបញ្ជាក់ថា ហោ ណាំហុង នេះគឺប្រធានមន្ទីរបឹងត្របែក ។ គាត់បានបែងចែកការងារ និងចាត់តាំងទៅតាមក្រុម ។ គាត់មិនមែនជាអ្នកទោសទេ ។ មេធាវី កូប៉េ ចង់ដឹងថា តើ ហោ ណាំហុង មានតួនាទីបញ្ជូនប្តីគាត់ទៅមន្ទីរស-២១ ទេ? លោកស្រី ស៊ីអ៊ី ឆ្លើយថា គាត់មិនបានដឹងទេ ហើយក៏មិនដឹងថា គាត់ត្រូវបានគេចោទដូច អៀង សារី ឬអត់?

នៅចំណុចនេះ លោកកូប៉េ ផ្តល់វេទិកាឲ្យទៅមេធាវីការពារក្តី ខៀវ សំផន បន្ត ។ សួរដោយសង្ខេប លោកស្រីមេធាវី អាន់តាហ្គីហ្វេ បាននិយាយថា គាត់បានឮថា លេខារបស់ អៀង សារី ត្រូវបានគេហៅឈ្មោះថា សួរ ហុង? អ្នកស្រី ស៊ីអ៊ី ឃើញគាត់ម្តងនៅបឹងត្របែក ។

### សំណួរសួរដោយដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់មកអ្នកស្រី ស៊ីអ៊ី ត្រូវបានផ្តល់ឱកាសឲ្យសួរសំណួរទៅកាន់ជនជាប់ចោទ លោកស្រី ស៊ីអ៊ី បាននិយាយថា គាត់មានបំណងសួរទៅ លោក អៀង សារី ។

«តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះមានដំណើរការយឺតយ៉ាវ លទ្ធផលគឺធ្វើឲ្យជនជាប់ចោទបានស្លាប់មុនពេលដែលតុលាការមិនទាន់បានកាត់ទោស ។ អៀង សារី ផ្ទាល់ បានធ្វើដំណើរឃោសនាឲ្យប្រជាជនខ្មែរដែលរស់នៅបរទេសឲ្យវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ ដោយយកលេសថា មកជួយកសាងប្រទេសឡើងវិញ ដែលទទួលរងគ្រោះដោយសារតែសង្គ្រាម ។ ខ្ញុំមានអារម្មណ៍បានធូរស្រាលបន្តិច បន្ទាប់ពីខ្ញុំបានធ្វើសេចក្តីថ្លែងការណ៍នេះ ។ នៅពេលដែលខ្ញុំត្រឡប់មកប្រទេសកម្ពុជាវិញ គោលបំណងរបស់ខ្ញុំគឺ ដើម្បីជួបជាមួយឪពុកម្តាយរបស់ខ្ញុំ ។ ប៉ុន្តែទីបំផុត ខ្ញុំមិនទាំងដឹងសូម្បីតែកន្លែងដែលកប់សពរបស់លោកទាំងពីរនោះ និងគោលបំណងទីពីរ របស់ខ្ញុំគឺចង់ផ្តាំទៅដល់ក្មេងៗជំនាន់ក្រោយទាំងអស់ថា គួរតែរៀនពីបទពិសោធន៍មួយនេះ ។

គាត់បាននិយាយថា ក្មេងៗគួរតែមានការប្រុងប្រយ័ត្នចំពោះវិធីសាស្ត្រដែលបានប្រើ និងមិនត្រូវចាញ់បោកអ្នកនយោបាយ ដែលបាននិយាយតែពាក្យកុហក ។

នៅក្នុងប្រទេសនេះ ឃាតករអាចធ្វើដំណើរដោយសេរី និងមនុស្សមួយចំនួន ក្នុងចំណោមអ្នកទាំងនោះ កាន់មុខតំណែងជាន់ខ្ពស់នៅក្នុងប្រទេសទៀតផង ។ ដោយសារតែវប្បធម៌និទណ្ឌភាពនេះហើយ ដែលធ្វើឲ្យប៉ះពាល់ដល់ការរស់នៅដោយសុខសន្តិភាពរបស់ប្រជាជន ។ វាក៏ជាការដាក់ខបសគ្គមួយសម្រាប់ជំរុញទៅរកសន្តិភាព ។ ជាលទ្ធផល សេដ្ឋកិច្ចរបស់យើងមិនមានការរីកចម្រើន ។ ទេសចរណ៍មានការភ័យខ្លាចនឹងមកប្រទេសរបស់យើង ហើយកាលពីពេលថ្មីៗនេះ បណ្ឌិត កែម ឡី ត្រូវបានសម្លាប់ ។»

បន្ទាប់មក លោកប្រធានអង្គជំនុំជម្រះបានប្រាប់ដើមបណ្តឹងរដ្ឋប្បវេណីថា សំណួរគួរតែសួរដោយផ្ទាល់ទៅជនជាប់ចោទទាំងពីរ ។ គាត់បានសំដៅដល់ស្ថានភាពនៅក្នុងឆ្នាំ១៩៧៥ ដែល អៀង សារី បានទៅអំពាវនាវឲ្យខ្មែរវិលត្រឡប់មកកម្ពុជា ដោយយកលេសថា ដើម្បីជួយការកសាងប្រទេសឡើងវិញ ។

«តើគាត់មានដឹងទេថា ក្នុងចំណោមប្រជាជនខ្មែរដែលបានវិលមកប្រទេសខ្មែរវិញ ភាគច្រើនត្រូវបានខ្មែរក្រហមសម្លាប់នៅគុកទួលស្លែង? ហើយសំណួរទីពីរ ខ្ញុំចង់សួរទៅលោកទាំងពីរគឺ នួន ជា និងខៀវ សំផន ថា តើអ្នកទាំងពីរដែលជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ តើលោកទាំងពីរយល់យ៉ាងម៉េចចំពោះការស្លាប់របស់ប្រជាជនខ្មែររាប់លាននាក់ និងតើលោកមានការទទួលខុសត្រូវអ្វីខ្លះចំពោះអ្នកស្លាប់រហូតមកដល់សព្វថ្ងៃនេះ?

**អាលីស មើហ្គើរ**

# ប្រវត្តិសាស្ត្រតំបន់អន្លង់វែង : តម្លៃនៃសន្តិភាព

កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំដំឡើងស្លាកសញ្ញាសម្គាល់ការិយាល័យរបស់ខ្លួននៅលើខ្នងភ្នំដងរែក ជាប់ព្រំដែនថៃ ដែលជាអតីតទីបញ្ជាការចុងក្រោយរបស់ តាម៉ុក ។ មជ្ឈមណ្ឌលនេះនឹងមានតួនាទីចូលរួមចំណែកដើម្បីថែរក្សាប្រវត្តិសាស្ត្រដែលនៅសេសសល់ក្នុងតំបន់អន្លង់វែងទាំងមូល និងជំរុញឲ្យមានការផ្សះផ្សានៅក្នុងសហគមន៍ទាំងមូល ។



រូបភាពពីស្តាំ : លោក លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងក្រុមការងារចុះដាំបង្គោលស្លាកសញ្ញាសម្គាល់ការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និង ផ្ទះរបស់ ប៉ុល ពត និង ខៀវ សំផន នៅលើភ្នំដងរែក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ដោយមានការសហការជាមួយក្រសួងទេសចរណ៍ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលជាគម្រោងមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំការដាក់តាំងពិព័រណ៍ពីព្រឹត្តិការណ៍សំខាន់ៗក្នុងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម រៀបចំដំឡើងស្លាកសញ្ញាសម្គាល់នៅតាមទីតាំងប្រវត្តិសាស្ត្រទាំង១៤កន្លែង ព្រមទាំងរៀបចំណើរទស្សនកិច្ចសម្រាប់សិស្ស និស្សិតជាតិ និងអន្តរជាតិ ដើម្បីសិក្សា និងស្រាវជ្រាវអំពីតំបន់អន្លង់វែងជាបន្តបន្ទាប់ ។

នៅថ្ងៃខាងមុខ មជ្ឈមណ្ឌលសន្តិភាព និងក្រសួងទេសចរណ៍ រៀបចំគម្រោងបើកវគ្គបណ្តុះបណ្តាលមគ្គុទ្ទេសទេសចរណ៍ស្តីពីប្រវត្តិសាស្ត្រអន្លង់វែង និងផ្ទេរបទបង្ហាញពីប្រវត្តិសាស្ត្រក្នុងតំបន់នេះដល់សាស្ត្រាចារ្យ និងសិស្សនិស្សិតនៅទូទាំងប្រទេសថែមទៀត ។ ទោះបីយ៉ាងណា ដើម្បីសម្រេចកិច្ចការទាំងនេះ និងដើម្បីឲ្យកិច្ចការដំណើរការទៅដោយរលូន មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនេះ ក៏ទាមទារឲ្យមានការការចូលរួមចំណែកពីប្រជាជននៅក្នុងសហគមន៍ទាំងមូលដែរ ។

ជូ លន់ អតីតយោធាខ្មែរក្រហមនៅក្នុងកងពល៩១២ និងជាមេភូមិនៅស្រុកអន្លង់វែងបន្ទាប់ពីការធ្វើសមាហរណកម្ម មានប្រសាសន៍ថា លោកគាំទ្រដល់កិច្ចការអភិវឌ្ឍតំបន់អន្លង់វែង និងចង់ឲ្យមានការចុះមកស្រាវជ្រាវច្រើនថែមទៀត និងជួបផ្ទាល់ជាមួយអតីតខ្មែរក្រហម និងមេខ្មែរក្រហមដើម្បីស្តាប់ ស្វែងយល់ និងវិភាគទៅលើអ្វីដែលអ្នកទាំងនេះបានជួបប្រទះនៅក្នុងសម័យនោះ ។ ជាពិសេស លោកចង់ឲ្យក្មេងជំនាន់ក្រោយយល់ដឹងកាន់តែច្បាស់ពីប្រវត្តិខ្មែរក្រហម ។ លោកក៏សំណូមពរឲ្យអង្គការអន្តរជាតិ ក្រសួង និងរាជរដ្ឋាភិបាល អភិរក្សស្រុកអន្លង់វែង ដែលជាអតីតតំបន់សង្គ្រាម និងជាសមរភូមិចុងក្រោយ ទុកសម្រាប់អ្នកសិក្សាស្រាវជ្រាវ និងអ្នកទេសចរណ៍បានមកទស្សនា ។

ញឹម សុជាត គ្រូបង្រៀននៅវិទ្យាល័យអន្លង់វែង ហាក់គាំទ្រការលើកឡើងរបស់ លោក ជូលន់ ។ ប៉ុន្តែ លោក សុជាត បានសង្កេតឃើញថា អតីតខ្មែរក្រហមភាគច្រើននៅក្នុងតំបន់អន្លង់វែងមិនចង់រំឭករឿងរ៉ាវអតីតកាលទេ ។ ដូច្នេះ កូនៗរបស់អ្នកទាំងនេះក៏

មិនបានយល់ដឹងច្រើនពីរបបខ្មែរក្រហមដែរ ។ អតីតយោធាខ្មែរក្រហមមួយចំនួននៅតែភ័យខ្លាចពីអតីតកាលរបស់ខ្លួន ។ អាស្រ័យហេតុនេះហើយ លោកយល់ឃើញថា ការអភិរក្សតំបន់ប្រវត្តិសាស្ត្រ និងការផ្សះផ្សានៅក្នុងតំបន់អន្លង់វែង នឹងធ្វើឲ្យមានការសម្រុះសម្រួលរវាងអតីតយោធាខ្មែរក្រហម និងជនរងគ្រោះដែលឆ្លងកាត់របបនេះ ។ លោកសំណូមពរឲ្យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងផ្តល់ឯកសារទាក់ទងនឹងរបបខ្មែរក្រហមដល់សាលាសម្រាប់សិស្សានុសិស្ស ដើម្បីអាន និងស្វែងយល់បន្ថែមទៀត ។

កញ្ញា ចាន់ ឡេត សិស្សថ្នាក់ទី១២ វិទ្យាល័យអន្លង់វែង បានរៀបរាប់ថា ការថែរក្សាតំបន់ប្រវត្តិសាស្ត្ររបស់ខ្លួននៅអន្លង់វែង នឹងធ្វើក្មេងៗយល់ដឹងកាន់តែច្បាស់ថែមទៀតពីតំបន់នេះ ។ ជាក់ស្តែង កញ្ញា ឡេត ផ្ទាល់បានដឹងរឿងរ៉ាវបន្តិចបន្តួចពីរបបខ្មែរក្រហមតាមរយៈឪពុកម្តាយ ។ កញ្ញា ឡេត សំណូមពរមជ្ឈមណ្ឌលសន្តិភាពអន្លង់រៀបចំកម្មវិធីបណ្តុះបណ្តាលពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់សិស្សានុសិស្សរយៈពេលវែង ដើម្បីឲ្យសិស្សយល់ដឹងច្បាស់លាស់ពីប្រវត្តិសាស្ត្រនេះ ។ កញ្ញា ឡេត ក៏បន្ថែមថា នៅពេលណាទំនេរពីការសិក្សា កញ្ញាតែងតែមកទស្សនកិច្ចដោយផ្ទាល់នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដើម្បីយល់ដឹងពីកិច្ចការរបស់មជ្ឈមណ្ឌល ជាពិសេសពីរឿងរ៉ាវប្រវត្តិសាស្ត្រ ។

លោក ខេមរ៉ា រស់នៅលើភ្នំដងរែករយៈពេលប្រមាណជិត ២០ឆ្នាំមកហើយ មានប្រសាសន៍ថា លោកគាំទ្រឲ្យមានការអភិរក្សទីតាំងប្រវត្តិសាស្ត្រក្នុងតំបន់អន្លង់វែង ។ បន្ថែមពីលើនេះ លោកចង់ឲ្យមានការដាក់តាំងឡើងវិញនូវយុទ្ធោបករណ៍ដែលជាកេរ្តិ៍ដំណែលនៃសង្គ្រាម ដូចជា រថក្រោះ និងរថពាសដែក របស់យោធាខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាលក្នុងសម័យសង្គ្រាមនៅទីតាំងចាស់ៗក្នុងស្រុកអន្លង់វែង ។ គួរបញ្ជាក់ថា យុទ្ធោបករណ៍ទាំងនេះត្រូវបានដឹកចេញពីតំបន់អន្លង់វែងនេះ បន្ទាប់ពីអតីតយោធាខ្មែរធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល នៅឆ្នាំ១៩៩៩ ។ លោកបានបន្តថា ការថែរក្សាសម្ភារទាំងនេះ នឹងធ្វើឲ្យប្រវត្តិសាស្ត្រកាន់តែមានភាពទូលំទូលាយថែមទៀត ។ **សោម ប៊ុនថន**




ការិយាល័យរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅលើភ្នំដងរែក ជាប់ព្រំដែនថៃ ស្ថិតក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

# រថភ្លើងរំឭកពីអតីតកាល

កាលពីខែសីហា ឆ្នាំ២០១៦កន្លងទៅនេះ ខ្ញុំបានចូលរួមដំណើរកំសាន្តប្រចាំឆ្នាំជាមួយមិត្តរួមការងាររបស់ខ្ញុំនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ ឆ្ពោះទៅខេត្តព្រះសីហនុ និងខេត្តកំពត ដោយធ្វើដំណើរតាមរថភ្លើង ។ ដំណើរកំសាន្តប្រចាំឆ្នាំនេះត្រូវបានឧបត្ថមដោយ អ្នកឧកញ៉ា គិត ម៉េង ។ ចំពោះយើងទាំងអស់គ្នា ការធ្វើដំណើរតាមរថភ្លើងគឺជាបទពិសោធន៍ដំបូងរបស់យើង ។ ទាំងនេះដោយសារតែរថភ្លើងបានខកខានប្រើប្រាស់សម្រាប់អ្នកដំណើរអស់រយៈពេលជាងពីរទៅបីទសវត្សរ៍មកហើយ ។

នៅយប់ដំបូងមុនពេលដែលដំណើរកំសាន្តចាប់ផ្តើម ខ្ញុំគេងមិនលក់ទាល់តែសោះ ។ ខ្ញុំបាននឹកគិតទៅដល់រឿងរ៉ាវដែលឪពុកម្តាយរបស់ខ្ញុំបាននិយាយប្រាប់តាំងពីយូរណាស់មកហើយ ។ គាត់បាននិយាយប្រាប់ខ្ញុំពីការចាប់ជម្រិតជនបរទេសនៅឯភ្នំវល្លិ៍ដែលភ្នំនេះនៅមិនឆ្ងាយពីស្រុកកំណើតរបស់ខ្ញុំប៉ុន្មានទេ ។ ហេតុការណ៍ទាំងនោះនៅតែបន្តធ្វើឲ្យខ្ញុំមានអារម្មណ៍មិនល្អទាល់តែសោះរហូតដល់សព្វថ្ងៃ ។ នៅយប់នោះ ខ្ញុំបានគិតអំពីការធ្វើដំណើរតាមរថភ្លើងនៅព្រឹកបន្ទាប់ ។ ខ្ញុំមានអារម្មណ៍ច្របូកច្របល់ណាស់ថាតើខ្ញុំកំពុងតែរំភើបឬក៏កំពុងតែខ្លាច? ។ ខ្ញុំបានចាប់ផ្តើមយល់ពីអារម្មណ៍ខ្ញុំច្បាស់នៅពេលដែលខ្ញុំបានចូលដល់ក្នុងស្ថានីយរថភ្លើង ។ នៅពេលដែលខ្ញុំបានឈានជំហានដំបូងរបស់ខ្ញុំទៅលើកាំជណ្តើររថភ្លើង ខ្ញុំពិតជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងទៅលើការពេញនិយមនៃការធ្វើដំណើរតាមរថភ្លើងឡើងវិញ ។ នៅក្នុងទូរថភ្លើងពិតជាមានអនាម័យ ត្រជាក់ ដែលមានកន្លែងអង្គុយពោរពេញទៅដោយផាសុខភាព ។ តាមរយៈការមើលទឹកមុខអ្នកដំណើរទាំងអស់ហាក់បីដូចជាអន្ទះអន្ទែងរង់ចាំរថភ្លើងចេញដំណើរ ជាពិសេសរង់ចាំគយគន់ទេសភាពនៅតាមដងផ្លូវ ។ នៅពេលដែលម៉ាស៊ីនចាប់ផ្តើមបញ្ឆេះ អ្នកដំណើរទាំងអស់ចាប់ផ្តើមច្រៀងកំសាន្តជាមួយមិត្តភក្តិដែលគ្នាលេង និងគយគន់ទេសភាពតាមដងផ្លូវយ៉ាងសប្បាយរីករាយ ។

អារម្មណ៍របស់ខ្ញុំបានផ្លាស់ប្តូរភ្លាមៗក្នុងខណៈពេលដែលខ្ញុំកំពុងគយគន់ទេសភាពតាមដងផ្លូវ ។ រំពេចនោះ ខ្ញុំបានគិតទៅដល់ការជម្លៀសនៅក្នុងសម័យខ្មែរក្រហម ។ ការគិតទាំងនេះបានគ្រប



រថភ្លើងនៅពេលបច្ចុប្បន្ន។ រថភ្លើងនេះដាក់ឲ្យដំណើរការឡើងវិញដោយក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប ដើម្បីផ្តល់សេវាដឹកជញ្ជូនភ្ញៀវពីភ្នំពេញ ទៅខេត្តតាកែវ កំពត និងកំពង់សោម បន្ទាប់ពីបានផ្អាកដំណើរការអស់ជាច្រើនទសវត្សរ៍មក ។



រូបទីពីររាប់ពីឆ្វេង ៈ អៀង សារី ឧបនារដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ អមដំណើរដោយកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ និងក្រុមប្រឹក្សាបច្ចេកទេសចិន បាបចុះត្រួតពិនិត្យផ្លូវរថភ្លើងដែលកំពុងត្រូវបានជួសជុលឡើងវិញ បន្ទាប់ពីបានទទួលជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ដណ្តប់អារម្មណ៍របស់ខ្ញុំដោយទឹកស្មានមិនដល់ ។ ខ្ញុំពិតជាឆ្ងល់ណាស់ថាតើរថភ្លើងដែលខ្ញុំកំពុងតែជិះនេះ វាបានផ្តល់ភាពងាយស្រួលដូចដែលខ្ញុំកំពុងជិះដែររឺទេ នៅពេលដែលវាបានជម្លៀសប្រជាជនចេញពីទីក្រុងនៅក្នុងសម័យខ្មែរក្រហម ។ តើទេសភាពនៅតាមផ្លូវនៅពេលនោះមានលក្ខណៈស្រស់ស្អាតដូចដែលខ្ញុំឃើញពេលនេះដែររឺទេ? តើប្រជាជនដែលត្រូវបានខ្មែរក្រហមជម្លៀសនោះអាចច្រៀង និងរីករាយចំពោះការធ្វើដំណើររបស់ខ្លួនដូចខ្ញុំដែរឬទេ? តើប្រជាជនទាំងអស់ដែលត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំចេញពីស្រុកកំណើតតាមរថភ្លើងនៅពេលនោះមានអារម្មណ៍យ៉ាងណា?

ទោះបីជាខ្ញុំបានដឹងខ្លះថា ស្ថានភាពប្រជាជននៅពេលនោះមានលក្ខណៈខុសគ្នាស្រឡះពីខ្ញុំពេលនេះក៏ដោយ ប៉ុន្តែមានសំណួរជាច្រើនបានកើតឡើងនៅក្នុងអារម្មណ៍របស់ខ្ញុំ ។ ជាការពិត ខ្ញុំកំពុងតែធ្វើដំណើរទៅកំសាន្ត និងសម្រាកលំហែកាយ ចំណែកឯប្រជាជនកម្ពុជាទាំងនោះត្រូវបានបង្ខំឲ្យធ្វើដំណើរតាមរថភ្លើងទៅកាន់ខេត្តផ្សេងៗគ្នាដើម្បីចាត់ចែងឲ្យធ្វើការងារយ៉ាងលំបាកលំបិន ។ ដូចច្នេះ ទោះបីខ្ញុំមិនច្បាស់ពីអារម្មណ៍របស់ប្រជាជនក៏ដោយ តែខ្ញុំច្បាស់ថាវាជាពេលដែលលំបាកបំផុតសម្រាប់ពួកគេ ។ បន្ទាប់មកការប្រៀបធៀបដែលពោរពេញទៅដោយចម្ងល់ជាច្រើន បានបញ្ឈប់ការគិតរបស់ខ្ញុំ ។ ខ្ញុំកំពុងធ្វើដំណើរតាមរថភ្លើងនៅខណៈពេលដែលប្រទេសរបស់យើងមានសន្តិភាពហើយពួកគេទាំងអស់បានធ្វើដំណើរតាមរថភ្លើងក្នុងពេលដែលប្រទេសមានសង្គ្រាម ។

ការធ្វើដំណើរតាមរថភ្លើងពិតជាបទពិសោធន៍មួយដ៏រំភើប និងរីករាយបំផុតក្នុងជីវិតរបស់ខ្ញុំ ។ បទពិសោធន៍នេះបានធ្វើឲ្យខ្ញុំមានមោទកភាពចំពោះប្រទេសកម្ពុជាយ៉ាងខ្លាំង ដែលបានវិលត្រលប់មកវិញ និងមានការរីកចម្រើនបន្ទាប់ពីបានឆ្លងកាត់សង្គ្រាមអស់រយៈពេលយូរលង់មកហើយ ។ ខ្ញុំពិតជារីករាយណាស់នៅពេលបានឃើញការដំណើរការរបស់រថភ្លើងឡើងវិញ បន្ទាប់ពីសម័យខ្មែរក្រហម និងបន្ទាប់ពីការផ្អាកដំណើរការដឹកអ្នកដំណើរអស់រយៈពេលជាច្រើនឆ្នាំ ។ វាបានចូលរួមចំណែកបង្ហាញឲ្យឃើញអំពីការអភិវឌ្ឍរបស់ប្រទេសកម្ពុជាបន្ទាប់ពីសង្គ្រាមផងដែរ ។ ទោះបីជារថភ្លើងមានសភាពយឺតបន្តិចក៏ដោយ វាពិតជាមានសុវត្ថិភាព ហើយខ្ញុំប្រាកដណាស់ថាវានឹងមានប្រសើរជាងនេះមិនយូរមិនឆាប់ ។

ខ្ញុំពិតជារីករាយណាស់ក្នុងការចែករំលែកបទពិសោធន៍ដ៏អស្ចារ្យនេះជាមួយនឹងមិត្តភក្តិ ក៏ដូចជាសាច់ញាតិរបស់ខ្ញុំ ។ ដំណើរកំសាន្តនេះបានធ្វើឲ្យខ្ញុំនឹកឃើញពីអតីតកាលក៏ដូចជាបទពិសោធន៍ដ៏ជូរចត់របស់ប្រទេសកំណើតរបស់ខ្ញុំនៅខណៈពេលដែលខ្ញុំកំពុងរីករាយជាមួយស្ថានភាពរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន ។

**អ៊ុន សុជាទី**

# អន្លង់វែង និងការផ្លាស់ប្តូរទស្សនៈអវិជ្ជមាន

របបខ្មែរក្រហមបានដួលរលំនៅខែមករា ឆ្នាំ១៩៧៩ ទោះបីជាយ៉ាងណា ក៏ចលនាខ្មែរក្រហមមិនទាន់បរាជ័យទាំងស្រុងដែរ ។ ខ្មែរក្រហមបានប្រមូលកម្លាំងដែលនៅសេសសល់តាមព្រំដែនថៃ ដើម្បីធ្វើការប្រឆាំងនឹងកងទ័ពរដ្ឋាភិបាលវិញ ។ អន្លង់វែង គឺជាមូលដ្ឋានតស៊ូរឹងមាំចុងក្រោយរបស់ខ្មែរក្រហម បន្ទាប់តំបន់ផ្សេងៗធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ។ ចលនាតស៊ូរបស់ខ្មែរក្រហម បានបន្តសកម្មភាពរបស់ខ្លួននៅអន្លង់វែង រហូតដល់តាម៉ុក ត្រូវបានចាប់ខ្លួន ។ ទោះបីជាយ៉ាងណា ប្រជាជនមួយចំនួននៅតែមានចិត្តភ័យខ្លាចពេលដែលធ្វើដំណើរមកកាន់តំបន់នេះ ។

សម្រាប់ក្មេងៗជំនាន់ក្រោយ ដែលបានដឹងពីអន្លង់វែងតាមរយៈចាស់ទុំ ឬឪពុកម្តាយតែងគិតថា អន្លង់វែងជាតំបន់ដាច់ស្រយាលមួយដែលមិនសូវមានមនុស្ស និងលំបាករស់នៅប៉ុណ្ណោះ ។ ខាងក្រោមនេះ គឺជាទស្សនៈផ្ទាល់ខ្លួនរបស់សិស្ស និស្សិតដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែងក្រោមកិច្ចរៀបចំរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងៈ

**◆ ផល មី និស្សិតឆ្នាំទី៣ ផ្នែកអក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**


ផល មី ថតនៅពើយតារ៉ូន ស្ថិតលើ ខ្នងភ្នំដងរែក

តំបន់អន្លង់វែង ពេលដែលខ្ញុំឮដំបូង ខ្ញុំគ្រាន់តែគិតថា ជាតំបន់ដាច់ស្រយាលមួយដែលស្ថិតក្បែរព្រំដែនថៃប៉ុណ្ណោះ ។ ប៉ុន្តែពេលដែលខ្ញុំមកឃើញផ្ទាល់ អន្លង់វែងមិនដូចការគិតរបស់ខ្ញុំទេ តំបន់នេះមានការអភិវឌ្ឍល្អ មានភ្លើងអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ។

**◆ ណែម ណុំ និស្សិតឆ្នាំទី៣ ផ្នែកអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**


ណែម ណុំ ដាំកូនឈើនៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ពេលដែលខ្ញុំឮពីតំបន់អន្លង់វែងដំបូង ខ្ញុំយល់ថា វាប្រហែលជាតំបន់មួយដាច់ស្រយាល មិនសូវមានមនុស្សរស់នៅ គ្មានការអភិវឌ្ឍ ជាពិសេស គឺតំបន់នេះជាតំបន់ដែលធ្វើការបង្រួបបង្រួមក្រោយគេ ។ ម្យ៉ាងទៀត ភាគច្រើនអ្នកដែលរស់នៅតំបន់នេះជាទាហានដែលសេសសល់ពីរបបខ្មែរក្រហម ។ បន្ទាប់ពីខ្ញុំបានមកឃើញផ្ទាល់ គឺវាផ្ទុយស្រឡះពីការគិតរបស់ខ្ញុំ ។ ភាពជាក់ស្តែងតំបន់នេះជាតំបន់មួយដែលមានការអភិវឌ្ឍ មនុស្សរស់នៅកុះករ និងជាទីប្រជុំជនមួយដែលមានផ្លូវខ្វាត់ខ្វែង ប្រៀបបាននឹងទីក្រុងមួយនៅកណ្តាលព្រៃអឺចឹង ។

**◆ ទាន ចង និស្សិតឆ្នាំទី៣ ផ្នែកអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

អ្វីដែលខ្ញុំគិតអំពីអន្លង់វែងដំបូង គឺខ្ញុំគិតថា អន្លង់វែង ជាតំបន់ដាច់ស្រយាល មានអូរធំៗជាច្រើន ហើយមិនសូវមានមនុស្សរស់នៅទេ ។ វាក៏ជាតំបន់ដែលគួរឲ្យភ័យខ្លាចទៀតផង ។ ប៉ុន្តែ ពេលដែលខ្ញុំមកឃើញផ្ទាល់ គឺវាមិនដូចពីអ្វីដែលខ្ញុំបានគិតពីមុនមកនោះទេ ។ តំបន់មួយនេះ មានការអភិវឌ្ឍស្ទើរគ្រប់វិស័យ ទាំងវិស័យកសិកម្ម និងឧស្សាហកម្ម ។ ជាងនេះទៅទៀត មានមនុស្ស

រស់នៅ និងរកស៊ីយ៉ាងច្រើនកុះករ មិនមែនជាតំបន់ដែលគួរឲ្យភ័យខ្លាចនោះឡើយ ។

**◆ ឡាយ សុគុន និស្សិតឆ្នាំទី៣ ផ្នែកអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**


សុគុន ថតជាមួយ តា ម៉ា សឿន នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ដំបូងខ្ញុំគិតថា អន្លង់វែង គឺជាតំបន់ធម្មជាតិមួយដែលពុំសូវមានមនុស្សរស់នៅ ពុំមានហេដ្ឋារចនាសម្ព័ន្ធល្អ និងគ្មានអ្វីគួរជាទីចាប់អារម្មណ៍ឡើយ ។ ផ្ទុយមកវិញ បន្ទាប់ពីខ្ញុំបានមកដល់តំបន់នេះមានមនុស្សរស់នៅយ៉ាងច្រើន មានភោជនីយដ្ឋាន សណ្ឋាគារសំណង់ធំៗ ផ្សារលក់ទំនិញគ្រប់ប្រភេទ ។ ជាពិសេស មានសាលារៀន មន្ទីរពេទ្យ និងផ្លូវក្រាលកៅស៊ូខ្វាត់ខ្វែង ។ ចំពោះបញ្ហាសន្តិសុខគឺល្អ ខ្ញុំឃើញ មានប៉ុស្តិ៍យាមរបស់មន្ត្រីប៉ូលីស អាវុធហត្ថ ដែលផ្តល់ការការពារដល់ប្រជាជននៅក្នុងតំបន់ ។

**◆ រស់ ចាន់ថុល និស្សិតឆ្នាំទី៣ ផ្នែកអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**


ចាន់ថុល ថតជាមួយ ប៉ាត់ ទាវ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

សម្រាប់ខ្ញុំពេលដែលមិនទាន់មកឃើញ ខ្ញុំគិតថាអន្លង់វែងគឺជាស្រុកមួយដែលហ៊ុមព័ទ្ធដោយព្រៃឈើ និងភ្នំជាច្រើន ។ វាជាតំបន់ដាច់ស្រយាលមួយ និងពុំមាននរណាម្នាក់ចង់រស់នៅឡើយ ។ បន្ទាប់ពីខ្ញុំបានមកឃើញផ្ទាល់ ទើបដឹងថា ខុសពីអ្វីដែលខ្ញុំធ្លាប់គិតពីតំបន់នេះ ។ អន្លង់វែងមានការអភិវឌ្ឍ មានសុខសន្តិភាព និងប្រជាជនរស់នៅដោយសុខសាន្ត ។ ចំពោះហេដ្ឋារចនាសម្ព័ន្ធវិញ ខ្ញុំសង្កេតឃើញថា មានការស្ថាបនាផ្លូវថ្នល់ ស្ពាន សាលារៀន វត្តអារាម មន្ទីរពេទ្យ គួរជាទីកត់សម្គាល់ ។

**◆ វ៉េង រ៉ាន់នី និស្សិតឆ្នាំទី៤ ផ្នែកអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**


រ៉ាន់នី ដាំកូនឈើនៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

គំនិតដំបូងរបស់ខ្ញុំ បានគិតថា អន្លង់វែង គឺជាតំបន់ដែលគ្រោះថ្នាក់ និងជាជំរំទាហាន ហើយសម្បូរដោយលេណដ្ឋាន ។ ប៉ុន្តែពេលដែលខ្ញុំមកឃើញតំបន់អន្លង់វែងផ្ទាល់នៅខែវស្សានេះ គឺមានធម្មជាតិស្រស់បំព្រង ។ បន្ទាប់ពីបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានេះ ទើបខ្ញុំដឹងថា អន្លង់វែង គឺជាតំបន់តស៊ូរឹងមាំចុងក្រោយរបស់ខ្មែរក្រហម ហើយខ្ញុំក៏បានទៅទស្សនាតំបន់ប្រវត្តិសាស្ត្រជាច្រើនកន្លែងទៀតផង ។

**◆ ស៊ឹម សុខហេង និស្សិតឆ្នាំទី៤ ផ្នែកអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

នៅពេលដែលខ្ញុំឮពីអន្លង់វែងដំបូងខ្ញុំគិតថា វាជាតំបន់ដាច់ស្រយាល ប្រជាជនមិនមានជីវភាពធូរធា និងអាចមិនមានផ្សារសម្រាប់លក់ដូរផង ។ ខ្ញុំគិតថាប្រជាជនរស់នៅតំបន់នេះ មានការលំបាកច្រើន គឺលំបាកទាំងការរកទទួលទាន និងធ្វើដំណើរ ។ ផ្ទុយពីអ្វីដែលធ្លាប់គិត ពេលដែលមកដល់ ខ្ញុំបានឃើញប្រជាជនរស់នៅតំបន់នេះ មានជីវភាពសមរម្យ មានផ្សារលក់ដូរទំនិញគ្រប់ប្រភេទ ។ម្យ៉ាងទៀត ខ្ញុំបានដឹងថា តំបន់នេះជាតំបន់ទេសចរណ៍ប្រវត្តិ



សុខហេង ដាំកូនឈើនៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

សាស្ត្រមួយ ដែលទាក់ទងនឹងចលនាខ្មែរក្រហមទៀតផង ។

**◆ ហេង អ៊ី និស្សិតឆ្នាំទី៤ ផ្នែកអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**



រូបខាងឆ្វេង ៖ ហេង អ៊ី ថតជាមួយប្រជាជនក្នុងស្រុកអន្លង់ពេលចុះសម្ភាស

សម្រាប់ខ្ញុំ ពេលដែលបានឮអំពីអន្លង់វែងដំបូង ខ្ញុំគិតថា វាគឺជាតំបន់មួយដែលដាច់ស្រយាល មិនមានការអភិវឌ្ឍ ផ្លូវលំបាកក្នុងការធ្វើដំណើរ គ្មានផ្សារ សាលារៀន និងមន្ទីរពេទ្យជាដើម ។ ខ្ញុំយល់ថា តំបន់នេះ មានប្រជាជនរស់នៅតិច សម្បូរទៅដោយព្រៃ និងគ្រាប់មីន ព្រោះតំបន់នេះជាតំបន់ដែលធ្លាប់មានការប្រយុទ្ធពីមុនមក ។ បន្ទាប់ពីបានមកឃើញផ្ទាល់ភ្នែក ទើបខ្ញុំដឹងថា អន្លង់វែង គឺជាតំបន់ដែលគួរឲ្យចង់រស់នៅ ហើយប្រជាជនមានភាពរាក់ទាក់ ។ អន្លង់វែង មានផ្លូវក្រាលកៅស៊ូខ្វាត់ខ្វែង មានមន្ទីរពេទ្យ សាលារៀន និងផ្សារទំនិញ ។ ជាពិសេស អន្លង់វែងក៏ជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រទាក់ទងនឹងរបបខ្មែរក្រហម ដែលអ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាទេសចរណ៍ ទៅទស្សនា ឬស្វែងយល់បាន ។

**◆ រដ្ឋា សុខឡែន និស្សិតឆ្នាំទី៤ ផ្នែកអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**



សុខឡែន នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

តំបន់អន្លង់វែង ពេលដែលខ្ញុំបានឮដំបូង ខ្ញុំគិតថា ជាតំបន់ដែលសម្បូរដទៅដោយព្រៃឈើ និងសត្វព្រៃ ។ ជាតំបន់ដែលអសន្តិសុខ ព្រោះជាតំបន់ដែលមានអតីតខ្មែរក្រហមរស់នៅច្រើន និងជាកន្លែងដែលធ្លាប់មានសង្គ្រាមពីមុនមក ។ ហេតុនេះ តំបន់នេះអាចនឹងបន្សល់នូវគ្រាប់មីនជាច្រើន ដែលអាចបង្កគ្រោះថ្នាក់ជាយថាហេតុ ។ ពេលដែលបានមកដល់ ខ្ញុំយល់ថា វាមិនដូចជាអ្វីដែលខ្ញុំធ្លាប់គិតទេ ទោះបីជាតំបន់នេះមានអតីតខ្មែរក្រហម រស់នៅច្រើន ប៉ុន្តែក៏មានអ្នកចំណូលថ្មីមករកស៊ី និងរស់នៅជាច្រើនដែរ ។ លើសពីនេះទៅទៀត ផ្ទះតាម៉ុក ដែលជាអតីតមេបញ្ជាការ និងអ្នកគ្រប់គ្រងតំបន់អន្លង់វែង ត្រូវបានរៀបចំជាកន្លែងទេសចរណ៍សម្រាប់ប្រជាជនចូលទស្សនា ។

**◆ សួនសុភ័ក្ត្រ និស្សិតឆ្នាំទី៣ ផ្នែកអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

ពេលដែលខ្ញុំឮពីតំបន់អន្លង់វែងដំបូង ខ្ញុំគិតថា វាគ្រាន់ជាតំបន់ដាច់ស្រយាលមួយដែលមិនមានមនុស្សរស់នៅច្រើន ហើយខ្ញុំមិនទាំងដឹងថា អន្លង់វែង ស្ថិតនៅក្នុងខេត្តណាផង ។ ខ្ញុំគិតថា ប្រជាជនរស់នៅទីនេះ ប្រហែលជាទីទាល់ក្រ ហើយមិនមានសាលារៀន មន្ទីរពេទ្យ ឬផ្សារទំនិញផង ។ ផ្ទុយមកវិញ ពេលដែលខ្ញុំបានមកដល់អន្លង់វែង គឺបានផ្លាស់ប្តូរនូវគំនិតអវិជ្ជមានរបស់ខ្ញុំពីមុនមកភ្លាម ។ នៅអន្លង់វែង មានគ្រប់សព្វ ដូចជា សាលារៀន មន្ទីរពេទ្យ ស្ពាន ថ្នល់ ភ្លើងអគ្គិសនី ផ្សារទំនិញជាដើម ។ លើសពីនេះទៀត អន្លង់វែងជាតំបន់ប្រវត្តិសាស្ត្រមួយពីរបបខ្មែរក្រហម ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនាទៀតផង ។

**ឆាយ សារៈមុនិន្ទ**

# នៅតែចងចាំ



ឪពុករបស់ វិបុល

នៅថ្ងៃដែលកងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ឪពុករបស់ខ្ញុំ ប្រាក់ វិបុលជ័យ មានទីលំនៅមុំទួលទំពូង ក្នុងជីវភាពគ្រួសារធូរធា ដែលមានបងប្អូន៧នាក់ (ស្រី៥នាក់ និង ប្រុស២នាក់) ។ ឪពុករបស់ខ្ញុំជាកូនទី៤ ហើយលោកតារបស់ខ្ញុំជាមន្ត្រីយោធាមួយរូប របស់របបសាធារណរដ្ឋខ្មែរ ។

បន្ទាប់ពីទទួលជ័យជម្នះ និងការអបអររបស់ប្រជាជនប៉ុន្មានម៉ោងមក យោធាខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនដោយបង្ខំចេញពីផ្ទះដោយប្រាប់ថា អាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅទីក្រុង ហើយខ្មែរក្រហមថា មិនចាំបាចយកទ្រព្យសម្បត្តិតាមខ្លួនច្រើនទេ ។ ដោយជឿតាមការណែនាំនេះ គ្រួសារឪពុករបស់ខ្ញុំបានធ្វើតាមដោយវេចខ្ចប់អាហារ និងសម្លៀកបំពាក់បន្តិចប៉ុណ្ណោះ ហើយបានចាកចេញពីទីក្រុងដោយរថយន្តទៅតាមផ្លូវក្បាលថ្នល់តម្រង់ទៅកៀនស្វាយ ។ ធ្វើដំណើរមិនបានប៉ុន្មានផង យោធាខ្មែរក្រហមបានដកយករថយន្តដោយឲ្យធ្វើដំណើរដោយថ្មើរជើង ។

គ្រួសារឪពុកខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅខេត្តតាកែវជាមួយនឹងប្រជាជនដទៃទៀត ។ ប៉ុន្មានថ្ងៃមកទៀត ឪពុករបស់ខ្ញុំបានបែកពីលោកតា ដោយសារលោកតាទៅមើលកូនទាហានរបស់គាត់នៅខេត្តតាកែវ ។ នៅពេលនោះ គ្រួសារឪពុកខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅកោះក្របីតាមកាណូត ។ គ្រួសារឪពុកខ្ញុំបានធ្វើដំណើរទៅដល់ទីនោះ បានទទួលដំណឹងថាលោកតាត្រូវបានអង្គការហៅទៅរៀនសូត្រ ។ ក្រោយមក ខ្មែរក្រហមបានបញ្ជូនគ្រួសារឪពុករបស់ខ្ញុំបន្តទៅឃុំត្រពាំងធំវិញ ។

នៅទីនោះអង្គការចាត់តាំងឲ្យធ្វើការផ្សេងៗពីគ្នា លោកយាយ ត្រូវអង្គការចាត់តាំង ឲ្យធ្វើស្រែចម្ការ ចំណែកឪពុករបស់ខ្ញុំទៅរើសអាចម៍គោ និងដកស្ទូង ។ លោកយាយបានខិតខំធ្វើការផង និងមើលថែគ្រួសារផង ។ បន្ទាប់ពីធ្វើការនៅទីនោះបានមួយឆ្នាំ គណៈឃុំចិត្តល្អម្នាក់បានមកប្រាប់លោកយាយថា មានអ្នករាយការណ៍ពីប្រវត្តិរបស់គ្រួសារគាត់ថា ជាប្រពន្ធរបស់អតីតទាហានរបបសាធារណរដ្ឋខ្មែរ ។ គ្រួសារឪពុករបស់ខ្ញុំជាប់ឈ្មោះជា ពួកសក្តិភូមិ ដែលអង្គការចាត់ទុកជាខ្មាំង និងត្រូវកម្ទេចចោល តែដោយសារកូនក្មួយរបស់លោកតា បានប្រាប់ដំណឹងដល់មេឃុំ ទើបមេឃុំជួយបញ្ជូនគ្រួសារឪពុករបស់ខ្ញុំឲ្យទៅរស់នៅឃុំផ្សេងដើម្បីលាក់ប្រវត្តិ ។

មកនៅឃុំថ្មី អង្គការបានបំបែកគ្រួសារឪពុករបស់ខ្ញុំចេញពីគ្នា គាត់បានបែកពីម្តាយ និងបងប្អូនជាទីស្រលាញ់ ទៅធ្វើការនៅកន្លែងផ្សេង ។ អង្គការបានឲ្យគាត់ចូលកងចល័តកុមារ ហើយធ្វើការបានកន្លះឆ្នាំទើបគាត់អាចសុំអង្គការមកជួបម្តាយបានម្តង តែមិនបានជួបជុំបងប្អូនទេ គ្រាន់តែទទួលដំណឹងថា បងស្រីធ្វើនៅកងចល័តយុវនារី ។ ពេលដែលឪពុករបស់ខ្ញុំត្រឡប់ទៅធ្វើការវិញ អង្គការបានដកគាត់ឲ្យចូលកងចល័តយុវជន ដោយត្រូវធ្វើការធ្ងន់ជាងមុន គឺត្រូវកាប់ដីជីកប្រឡាយ និងលើកទំនប់ ។

ថ្ងៃ៧ មករា ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជារួមជាមួយកងទ័ពវៀតណាមបានរំដោះប្រជាជនចេញពីរបបខ្មែរក្រហម ។ ឪពុករបស់ខ្ញុំបានធ្វើដំណើរមកស្រុកកំណើតរបស់លោកតា និងបានជួបជុំម្តាយ និងបងប្អូនរបស់គាត់វិញ ។

ឪពុកខ្ញុំប្រាប់ថា គាត់ពិតជាសំណាងខ្លាំងដែលបងប្អូនគាត់មិនបាត់បង់ជីវិតដោយសារតែចេះសម្របខ្លួនទៅតាមជីវភាព តែជាអកុសលមិនបានជួបនឹងឪពុករបស់គាត់ទេ ។ ឪពុករបស់ខ្ញុំតែងតែប្រាប់ខ្ញុំថា គាត់តែងតែនឹកឃើញជានិច្ចពីអ្វីដែលគាត់ធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហម ជាពិសេសការបាត់ខ្លួនឪពុកទោះបីជារបបឃោរឃៅមួយនេះកន្លងហួសទៅជាង៣០ឆ្នាំហើយក្តី និងមានបទចំរៀងមួយបទ ដែលនៅដក់ជាប់ជានិច្ចក្នុងចិត្តរបស់គាត់ គឺបទ «ឱ! ភ្នំពេញអើយ» ។ **ប្រាក់ ជ័យវិបុល**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ ញាណ សុជាតិ ទូរស័ព្ទលេខ ០៧០ ៩៨៨ ៦៦៦ ឬ អ៊ីម៉ែល ៖ truthsocheat@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ

ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.



A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 201, 2016 ◆ Funded by USAID.

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.